សមាគមបុគ្គលិកសិក្សាខ្មែរ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការរួបរួមគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សម្ភារៈ

៤៤

# ទស្សនាវដ្ដី គ្រូបង្រៀន



**សាលាបឋមសិក្សាត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ**

**ត្រីមាសទី៣ ឆ្នាំ ២០១៤**

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤_០១២ ៦៣៨ ៨៨៩
អ៊ីម៉ែល : kta.amcek@gmail.com

# មាតិកា

## គណៈកម្មការរៀបរៀង និង និពន្ធ

- លោក ជ័យ សយ្យនា
- លោក ថោង ម៉ូរ៉ាន់
- លោកស្រី គុយ ផល្លា
- លោកស្រី ប្រាក់ សូលីដា
- លោក ជន ឈាងលី
- លោក ស្វាយ និត្យ
- លោកស្រី អ៊ឹម ប៊ុណ្ណារី
- លោក ព្រុំ សាមិត
- លោកស្រី ថាច់ ធីសារ៉ែន
- លោក អ៊ឹម ដា
- សមាជិកសមាជិកា ស. ប. ស.ខ

## គណៈកម្មការត្រួតពិនិត្យ

- លោក យស់ អ៊ាង
- លោកស្រី ទន់ សាអ៊ឹម
- លោក អ៊ិន ថេរ
- លោក វ័ត្ត ហួត
- លោក សួង សារុណា
- លោក ស៊ុង វ៉ាន់ថន
- លោក ស៊ិន ស៊ីម

## ការីកុំព្យូទ័រ

កញ្ញា មឿងចាន់ផល្លី

## គ្របខាងក្រៅ

- ពីមុខ : សាលាបឋមសិក្សាត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ
- ពីក្រោយ : បង់ហ្គាឡូ ខេត្តស្វាយរៀង


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា | ១ |
| **រាជកិច្ច** | | |
| ២ | ច្បាប់ស្តីពីការអប់រំ (ត) | ២ |
| | **វប្បធម៌ទូទៅ** | |
| ៣ | ចម្រៀងនិងប្រយោជន៍ (តចប់) | ៥ |
| ៤ | ប្រភពនៃការអប់រំក្នុងពិភពលោក (ត) | ៨ |
| ៥ | បុរេប្រវត្តិប្រទេសកម្ពុជា មនុស្សដើមដូនតាខ្មែរ | ១០ |
| **ចិត្តវិទ្យាអប់រំ** | | |
| ៦ | សម្បទា និង សម្បទាគរុកោសល្យរបស់គ្រូបង្រៀន | ១២ |
| ៧ | មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុកតែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា (ត) | ១៤ |
| **ការអប់រំ និង គរុកោសល្យ** | | |
| ៨ | អភិវឌ្ឍចំណេះដឹងនិងបំណិន (តចប់) | ១៦ |
| ៩ | វេយ្យាករណ៍៖ របៀបប្រើពាក្យ (ត) | ១៩ |
| ១០ | សាលារៀនជាមជ្ឈដ្ឋានផ្សាយនូវវិជ្ជាទូទៅ(តចប់) | ២១ |
| ១១ | គណិតវិទ្យា៖ រកឃើញសំណួរត្រឹមត្រូវ | ២២ |
| **កំណាព្យ និង កំសាន្ត** | | |
| ១២ | វិធីអាន | ២៦ |
| ១៣ | សីលប្រាំងាយចាំមិនភ្លេច សីលប្រាំជានិច្ចអ្នកសាងកុសល(តចប់) | ២៨ |
| **វេទិកាស្មេរិន** | | |
| ១៤ | ពុទ្ធសាសនា និង សង្គមខ្មែរ (តចប់) | ២៩ |
| ១៥ | ឋានានុក្រមបព្វជិតពុទ្ធសាសនាខ្មែរ (តចប់) | ៣១ |
| ១៦ | វេទិកាស្ត្រី៖ រឿងព្រេង ជ័យ សូស្តី | ៣៣ |
| **ព័ត៌មាន** | | |
| ១៧ | តើលោកគ្រូ អ្នកគ្រូដឹងទេពីរង្វាស់រង្វាល់អន្តរជាតិ | ៣៥ |
| ១៨ | ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១២ (ត) | ៣៦ |
| ១៩ | ស្ថិតិសពខែ កញ្ញា - ធ្នូ ឆ្នាំ ២០១៣ | ៣៩ |


## ទូរស័ព្ទផ្ទះគ្រូបង្រៀន

| | | |
|---|---|---|
| **ភ្នំពេញ** | : | ០៨៩ ៦៨៤ ០៨១ |
| **ព្រះសីហនុ** | : | ០១២ ៦៥៩ ៥៦០ |
| **សៀមរាប** | : | ០១២ ៦៧៥ ៦៤០ |
| **កំពង់ចាម** | : | ០១១ ៧៤២ ២២៤ |
| **ស្វាយរៀង** | : | ០៩៧ ២ ៦៥៥ ៩៨៧ |
| **ព្រៃវែង** | : | ០១២ ៦៧១ ៦៤០ |
| **កំពត** | : | ០១២ ៨៥៦ ៧២២ |
| **កែប** | : | ០៩៧ ៨៧២១ ៨៨០ |
| **តាកែវ** | : | ០៩៧ ៩៧៦១ ៥៨៨ |
| **រតនគិរី** | : | ០៩៧ ៩០៤២ ៥៨៤ |
| **ព្រះវិហារ** | : | ០១២ ២១៨ ២៨១ |

# វិចារណកថា

របាយការណ៍ពិភពលោកអំពីការពិនិត្យ «ការអប់រំសម្រាប់ទាំងអស់គ្នា» បង្ហាញពីការវិវត្តឈានឡើងដែលប្រទេសនីមួយៗបានបំពេញភារកិច្ចឆ្ពោះទៅគោលដៅពិភពលោក ទាក់ទងនឹងការអប់រំនៅឆ្នាំ២០០០។ របាយការណ៍បានផ្ដល់ទឡ្ហីករណ៍មានទម្ងន់ដើម្បីអនុវត្តការអប់រំ ក្នុងកម្មវិធីពិភពលោកនៃការអភិវឌ្ឍក្រោយឆ្នាំ២០១៥ ។ របាយការណ៍បានចោទសួរថា តើយើងទៅដល់គោលដៅដែរឬទេ? មកដល់ពេលនេះ យើងនៅសល់មិនដល់ពីរឆ្នាំទៀតទេតែរបាយការណ៍ក៏បានប៉ាន់ប្រមាណដែរថា « យើងប្រហែលមិនសម្រេចគោលដៅទេ » ។ ដូចនេះ រដ្ឋាភិបាលទាំងអស់ត្រូវបង្កើនការខិតខំប្រឹងប្រែងទ្វេដងដើម្បីអាចឱ្យកុមារដែលងាយរងគ្រោះ ដោយភាពក្រីក្រ ភេទ ទីកន្លែងរស់នៅ និងកត្តាដទៃទៀតបានចូលរៀនដូចកុមារទូទៅដែរ ។

យើងវាយតម្លៃប្រព័ន្ធអប់រំតាមរយៈសមត្ថភាពរបស់គ្រូបង្រៀន។ ដូចនេះការលើកកម្ពស់សក្ដានុពលគ្រូបង្រៀនដើម្បីធ្វើឱ្យប្រសើរគុណភាពអប់រំជាការងារចាំបាច់ ។ ប៉ុន្តែគ្រូបង្រៀនតែម្នាក់ឯងមិនមែនជាកត្តាដើម្បីទទួលខុសត្រូវភារកិច្ចនេះទេ។ របាយការណ៍បានបញ្ជាក់ថា គ្រូបង្រៀនអាចសម្រេចការងារដោយជោគជ័យតែក្នុងបរិបទអនុគ្រោះ គឺកម្មវិធីសិក្សា បៀវត្សសមរម្យ ... ។

ដើម្បីសម្រេចគោលដៅការអប់រំនៅបឋមសិក្សាក្នុងឆ្នាំ២០១៥ រដ្ឋាភិបាលទាំងអស់ត្រូវជ្រើសរើសគ្រូបង្រៀនបន្ថែមទៀត ។ របាយការណ៍បានលើកយុទ្ធសាស្ត្រ៤យ៉ាង ដើម្បីជ្រើសរើសគ្រូបង្រៀនល្អ ដែលនាំឱ្យមានគុណភាពអប់រំគឺ ៖

១. ចាំបាច់ជ្រើសរើសគ្រូដើម្បីឆ្លុះបញ្ចាំងពីភាពដោយឡែកៗរបស់កុមារដែលគេត្រូវបង្រៀន ។

២. បណ្ដុះបណ្ដាលគ្រូបង្រៀនជាពិសេសសម្រាប់ជួយសិស្សខ្សោយនៅឆ្នាំសិក្សាទី១ ។

៣. ជម្នះភាពខុសគ្នាក្នុងការបង្រៀន ដោយចាត់តាំងគ្រូបង្រៀនពូកែ ឱ្យទៅកាន់សាលារៀនឆ្ងាយ និង សាលារៀនជួបការលំបាក ។

៤. ផ្ដល់ឱ្យគ្រូបង្រៀននូវការលើកទឹកចិត្ត ដើម្បីឱ្យគេស្ថិតនៅក្នុងវិជ្ជាជីវៈជាគ្រូ ឱ្យគេគិតតែបង្រៀនសិស្សដោយគ្មានទាក់ទងនឹងស្ថានភាពដទៃទៀត ។

ការកែទម្រង់គោលនយោបាយទាមទារឱ្យមានថវិកា ។ នេះជាហេតុផលដែលការងារអប់រំជួបការលំបាកព្រោះកង្វះហិរញ្ញប្បទានក្នុងពេលដែលជំនួយបន្តធ្លាក់ចុះដោយដៃគូអភិវឌ្ឍខកខានបំពេញការសន្យា និងរដ្ឋាភិបាលក៏កាត់បន្ថយថវិកាលើផ្នែកអប់រំផងដែរ។ ស្ថានភាពនេះតម្រូវឱ្យអំពាវនាវរកមធ្យោបាយហិរញ្ញវត្ថុដើម្បីដោះស្រាយសមភាពនៃការចូលរួម ដែលត្រូវស្ថិតក្នុងគោលដៅច្បាស់លាស់ អាចវាស់វែងបាន និងអនុញ្ញាតឱ្យរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍអាចតាមពិនិត្យវាយតម្លៃនិងបំពេញបង្គ្រប់ឱនភាពថវិកា ។

ឆ្នាំ២០១៥ ជាឆ្នាំបញ្ចប់នៃផែនការអភិវឌ្ឍសហសវត្សលើគោលដៅ « ការអប់រំសម្រាប់ទាំងអស់គ្នា » ដែលរដ្ឋាភិបាលទាំងអស់បានសន្យា ព្រោះការអប់រំជាគន្លឹះពន្លឿនគ្រប់គោលដៅនៃការអភិវឌ្ឍ ។ ដោយឡែកគោលដៅនៃការអប់រំសម្រាប់ទាំងអស់គ្នា កម្ពុជាត្រូវបានវាយតម្លៃនិងសង្ឃឹមថា នឹងសម្រេចតាមការរំពឹងទុកនៅឆ្នាំ ២០១៥ ។

« អប់រំមាតាគឺផ្ដល់ស្វ័យភាពជូនស្ត្រីនិងជួយសង្គ្រោះជីវិតកុមារ » ។ « អប់រំសហគមន៍ គឺកែប្រែសង្គម និង ធានាកំណើនសេដ្ឋកិច្ច » ។ នេះជាសាររបស់របាយការណ៍ពិភពលោក អំពីការពិនិត្យ « ការអប់រំសម្រាប់ទាំងអស់គ្នា » ។

**គណៈកម្មាធិការកណ្ដាល**

# ច្បាប់ស្តីពីការអប់រំ(ត)

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

**មាត្រា ៤៦.- ការបង្កើតគ្រឹះស្ថានសិក្សាដោយគ្មានអាជ្ញាប័ណ្ណ**

អំពើបង្កើត ឬ បើកឱ្យដំណើរការនូវគ្រឹះស្ថានសិក្សា និងថ្នាក់បណ្តុះបណ្តាលដោយគ្មានអាជ្ញាប័ណ្ណអប់រំជាមុន ដូចមានបញ្ញត្តិនៅក្នុងមាត្រា ១១ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ។

**មាត្រា ៤៧.- ការប្រើប្រាស់ប្រភេទគ្រឹះស្ថានសិក្សាមិនសមស្រប**

គ្រប់អំពើប៉ះពាល់ដល់ការប្រើប្រាស់ប្រភេទគ្រឹះស្ថានសិក្សា ដែលផ្ទុយទឹងបេសកកម្មអប់រំរបស់ខ្លួនដូចមានបញ្ញត្តិក្នុងមាត្រា ១២ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ហើយត្រូវប្តូរជាបណ្តោះអាសន្ន ឬ ដកហូតជាស្ថាពរនូវអាជ្ញាប័ណ្ណអប់រំរបស់គ្រឹះស្ថានសិក្សាទាំងនោះ ។

**មាត្រា ៤៨.- បទល្មើសពាក់ព័ន្ធនឹងការផ្តល់វិញ្ញាបនបត្រ ឬ សញ្ញាបត្រ**

គ្រប់ការផ្តល់វិញ្ញាបនបត្រ ឬ សញ្ញាបត្រ ដែលមានភាពមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា ១៤ នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ទៅ៦.០០០.០០០(ប្រាំមួយលាន)រៀល និងដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣(បី)ឆ្នាំ ។

**មាត្រា ៤៩.- ការបន្លំក្នុងការប្រឡង**

សាមីខ្លួន ឬ ជនណាដែលប្រឡងជំនួស ឬ បន្លំគ្រប់រូបភាពក្នុងការប្រឡងដូចមានបញ្ញត្តិក្នុងមាត្រា ២៦ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ៥.០០០.០០០ (ប្រាំលាន) រៀល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងករណីមិនរាងចាល សាមីខ្លួនត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ហើយត្រូវព្យួរការប្រឡងសម្រាប់រយៈពេល ២(ពីរ)ឆ្នាំ ឬ ហាមឃាត់មិនឱ្យចុះឈ្មោះក្នុងបញ្ជីប្រឡងជាស្ថាពរ ។ ចំពោះជនដែលប្រឡងជំនួស ឬ បន្លំគ្រប់រូបភាពក្នុងការប្រឡង ត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៥០.- បទល្មើសពាក់ព័ន្ធនឹងដំណើរការនៃការប្រឡង**

គ្រប់ទង្វើដែលប្រព្រឹត្តឡើងដោយបុគ្គលិកអប់រំ មានភាពមិនត្រឹមត្រូវក្នុងដំណើរការនៃការប្រឡងដូចបានបញ្ញត្តិក្នុងមាត្រា ២៦ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ចំពោះបុគ្គលិកអប់រំសាធារណៈ ត្រូវទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី ១ ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ។ ចំពោះបុគ្គលិកអប់រំសាធារណៈ ត្រូវទទួលទណ្ឌកម្មខាងវិន័យថ្នាក់ទី ២ បន្ថែមទៀត ។ ចំពោះបុគ្គលិកអប់រំឯកជន ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៥១.- ការប៉ះពាល់ដល់សេរីភាពខាងជំនឿសាសនាក្នុងការអប់រំ**

គ្រប់អំពើប៉ះពាល់ដល់សេរីភាពខាងជំនឿសាសនាក្នុងការអប់រំ ដែលប្រព្រឹត្តផ្ទុយនឹងបទបញ្ញត្តិនៃមាត្រា ៣៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០(ពីរលាន)រៀល និងដាក់ពន្ធនាគារពី ១ (មួយ)ខែ ទៅ ១(មួយ)ឆ្នាំ ។

**មាត្រា ៥២.- ការប៉ះពាល់ដល់អព្យាក្រឹតភាពរបស់ស្ថាប័នអប់រំ និងគ្រឹះស្ថានសិក្សា**

គ្រប់សកម្មភាពនយោបាយ ឬ ការឃោសនានយោបាយ ឱ្យគណបក្សនយោបាយណាមួយនៅក្នុងស្ថាប័នអប់រំ ឬ គ្រឹះស្ថានសិក្សាដែលផ្ទុយនឹងមាត្រា ៣៤ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០ (ប្រាំលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ។

(តៅមានទៀត)



# ចម្រៀង និងសារប្រយោជន៍(តចប់)

## ទំនុកច្រៀងក្នុងពិធីមង្គលការ

បណ្ដាចម្រៀងប្រជាប្រិយខ្មែរទាំងអស់ ចម្រៀងដែលមានទំនុកច្រើនជាងគេ គឺចម្រៀងក្នុងពិធីមង្គលការ បន្ទាប់មកចម្រៀងលៀងអារក្ស និងឡើងអ្នកតា ចម្រៀងក្រៅពីនេះមានទំនុកបន្ទាប់បន្សំ ។

របៀបរារៈមង្គលការដែលមានច្រើនថ្នាក់គឺ ថ្នាក់ចូលរោង កាត់សក់ ឡើងអ្នកតា លើកជំនូន រៀងផ្លែឈើ ក្រុង-ពាលី សំពះរោង ចម្រើនបរិត្ត រាំខ្មែរ បុកល័ក្ត ធ្វើធ្មេញ ដោតផ្កាស្លា សំពះរានពេលា ហូតផ្កាស្លា សុំកូនចេញផ្ទឹម បើកបាយខុន (ឱ្យពរចងដៃ) គោងស្បៃចូលក្នុង សាកន្ទេល (ក្រោយផ្ទឹមរួច) រៀបស្លក លើកស្លក សំពះអាចារ្យ មហា និងផ្សំដំណេក(បញ្ចុកចេកនំ) សុទ្ធតែត្រូវច្រៀងគ្រប់ថ្នាក់ទាំងអស់ ហើយមានទំនុកនិងបទជាច្រើនសម្រាប់ច្រៀងក្នុងថ្នាក់ទាំងនោះ តាមលំដាប់ គឺបទសារោងមេ ហោមរោង សំពោង ផាត់ជាយ អង្គរាជ ស្ដេចផ្ទុំ លោមនាង ថ្មមនាង ព្រះថោងនាងនាគ នាគព័ន្ធ កន្លង់គ្រែឬជុំគ្រែ កន្លង់រ័ត្ន កាត់ត្រើយ សារាយអណ្ដែត កន្សែងក្រហម កន្សែងសូត្រ ដំរីសក្លោងឬក្លាងបណ្ដែត រៀងផ្លែឈើ បំពេរ អុំទូក កាត់សក់ បុកល័ក្ត ដោតផ្កាស្លា ឬជាវផ្កាស្លា សំពះពេលា បើកបាយខុន សាកន្ទេល ក្រាំងដោះក្រាល ស្ដេចដើរ លលេ ម្លប់ដូង អន្លក់រាំង ចន្លោ សំពៅថយ និងកងសោយ ។

ចម្រៀងក្នុងមង្គលការដែលមានច្រើនទំនុក ប្រើបទដូចពោលមកនេះ តាមសង្កេតសព្វគ្រប់ទៅឃើញទំនុកខ្លះជាទំនុកសម្ដែងសេចក្ដីសប្បាយ ខ្លះសម្ដែងសេចក្ដីគោរព ខ្លះសម្ដែងសេចក្ដីទូន្មាន ។ល។ ហើយខ្លះមានប្រយោជន៍ច្រើនខ្លះមានប្រយោជន៍តិច ដែលមិនអាចស្រង់យកមកពោលឱ្យសព្វគ្រប់ក្នុងទីនេះបានព្រោះពេលខ្លី ប៉ុន្តែទោះបីមានច្រើនដូច្នេះ ក៏ជារួមគឺសេចក្ដីសម្ដែងសម្រេកចិត្តរបស់ជនជាមេបាគ្រួសារដែលប្រាថ្នាឱ្យសាមីខ្លួនកូនចៅជាអ្នកការថ្មី បានសេចក្ដីសុខសេចក្ដីចម្រើនទាំងអស់។

សូមស្រង់ទំនុកខ្លះក្នុងទំនុកច្រៀងមង្គលការ មកពោលក្នុងទីនេះដោយសង្ខេប ដូចតទៅនេះ ៖

## ទំនុកហោមរោង ឬ បើករោង

ទំនុកច្រៀងមួយបែប ជាទំនុកសម្ដែងសេចក្ដីគោរពចំពោះវត្ថុសក្តិសិទ្ធិនៅពេលចូលរោងការ ហៅថាទំនុក **ហ៊ុមរោង ឬបើករោង** មានដើមថា ៖

| | |
|---|---|
| យើងខ្ញុំសុំនមស្ការ | លើកហត្ថាលើសិរសី |
| បង្គំកែវទាំងបី | សូមសិរីជ័យជម្នះ ។ |
| ហើយលេងភ្លេងហោមរោង | តាមទំនងទំនៀមចាស់ |
| ភ្លេងផ្ទើមជាដើមអាសន៍ | បើកប្រកាសដាស់ទេវតា។ |
| ថ្ងៃនេះថ្ងៃជោគជ័យ | ញាតិប្រុសស្រីក្នុំមេបា |
| នឹងរៀបមង្គលការ | លៀងអាហារពិសាតុ ។ |

ហេតុនេះសូមទេវតា នូវអ្នកតាបាចាស់ស្រុក
ការពារឱ្យបានសុខ ចាកក្តីទុក្ខភ័យទាំងឡាយ ។
អញ្ជើញព្រាយកុមារ ព្រៃបព្វតាទីជិតឆ្ងាយ
ចូលមកយកស្រាបាយ ហើយប្រែកាយឱ្យពរជ័យ ។
ដល់លោកអ្នកទាំងឡាយ សុខសប្បាយទាំងប្រុសស្រី
ព្រមទាំងគូស្វាមី ទើបការថ្មីកុំបីហ្មង ។
ហោមរោងប្រាំពីរបទ ចប់កំណត់ត្រឹមនេះហោង
សូមឱ្យអស់ញាតិផង ជួយគឹកកងហ៊ោយកជ័យ ។
ជ័យហោងហៅជយោ យើងស្រែកហ៊ោគម្រប់បី
កក្រើកបើករោងថ្មី ដោតសួស្តីដោយជាក់ច្បាស់ ។

## ទំនុកបើកបាយខុន

មានទំនុកច្រៀងមួយបែប ជាទំនុកសម្តែងសេចក្តីគោរពចំពោះត្រកូលរៀមច្បង សូមកូនស្រីមកផ្ទឹមសម្រាប់ច្រៀងក្នុងមង្គលការនៅពេលមុនផ្ទឹម គឺពេលដែលកូនប្រុសមកអង្គុយលើអាសនៈ កណ្តាលហ្វូងមេបាប្រុងចាំកូនស្រីមកផ្ទឹម មានដើមថា ៖

បាយខុនចងដៃ អំបោះមួយសរសៃ ថ្លៃស្មើនឹងមាស
ទឹកផ្តិលសំរិទ្ធិ ប្រសិទ្ធឱភាស លើកឡើងគ្រវាស
ត្រដួចគួចហត្ថ ។

ថ្ងៃនេះថ្ងៃជា ថ្ងៃបានពេលា យកពារយាមសត្វ
ពេលស័ព្ទអក្សរ អរុណសុវត្ថិ ពារពតកផាត់
ពន្លឺពេញវង់ ។

ឮសូរគងហើយ អ្នកក្រាបលើខ្នើយ ប្រុងលុតជួញជង់
ដៃចាប់ស្លាពរ លើទ្រទម្រង់ ហត្ថាវាតវង់
ហូតដាក់បីដង ។

ច្បងជូនឪពុក ហើយទើបក្រាបទុក ជូនទៅម្តាយផង
ទៅជូនមាស្រី ទីបីជូនបង រៀបតាមរៀមច្បង
ទំនៀមបុរាណ ។

ស្លាពរទាំងបី ជូនមេបាស្រី ជាស្រេចគ្រប់ប្រាណ
កូនប្រុសគោរព គ្រប់ញាតិសន្តាន ចាំស្រីកល្យាណ
ចេញប្រាណមកផ្ទឹម ។

អនអើយ!ស្រីអន! សុំបើកវាំងនន ឱ្យអនអមទឹម
ដឹកដៃកូនស្រី ប្រឹមប្រិយញញឹម ក្រាបម៉បអបផ្ទឹម
នៃបនឹមលោកប្រុស ។

## ទំនុកបើកវាំងនន

អនអើយ !ស្រីអន ! សុំបើកវាំងនន សុំអនមកផ្ទឹម
ត្បិតពេលថ្មើរនេះ ទាន់នៅព្រលឹម សុំអនមកផ្ទឹម
គូព្រេងដល់ហើយ ។

## ទំនុកបំពេរ

ទំនុកច្រៀងមួយបែប ជាទំនុកសម្តែងដំបូន្មាន ដែលម្តាយទូន្មានកូនស្រី សម្រាប់ច្រៀងក្នុងមង្គលការនៅពេលចងដៃ ហៅថា **ទំនុកបំពេរ** មានដើមថា ៖

| | |
|---|---|
| កូនអើយ!ចាំផ្ទៀង | ម្តាយច្រៀងបំពេរ |
| ពាក្យឯកប្លែកគេ | ជាមេច្បាប់ចាស់ ។ |
| ចូរចាំជាក្រឹត្យ | ព្រោះត្បិតក្រណាស់ |
| ធម្មតាមេផ្ទះ | ប្រះគេងឈ្វេងគិត ។ |
| កើតមកជាមនុស្ស | ទ្រើសនៅគំនិត |
| ត្រូវរៀនរិះគិត | មើលព្រឹត្តិស្វាមី ។ |
| កុំដើរបង់សៀត | ឃ្លាតផ្ទះរាត្រី |
| បើមានការអ្វី | ប្រាប់ប្តីឱ្យដឹង ។ |
| ចូលគេងកូនឯង | កុំថ្លែងរឿងខឹង |
| កុំត្អូករីងត្អឹង | ក្រញឹងក្រញូវ ។ |
| យប់យន់យូរហើយ | នាងអើយ !គេងទៅ |
| ព្រោះពេលយប់ជ្រៅ | ប្តីពៅបំពេរ ។ |
| នាងនឿយពីថ្ងៃ | គ្មានដៃទំនេរ |
| បម្រើរត់រេ | ដោយគេការយើង ។ |
| នាងគេងកាលណា | កុំផ្ងារដៃឡើង |
| មួយទៀតកុំទើង | គេងទឹមក្បាលប្តី ។ |
| បើជួនជាពាល់ | កាន់ដល់កេសី |
| ត្រូវមានសម្តី | សុំទោសតាមការ ។ |

ចម្រៀងប្រជាប្រិយខ្មែរយើង មានច្រើនទំនុក ច្រើនបទជាអនេកលើសគណនា ពុំអាចពណ៌នាឱ្យចប់សព្វគ្រប់ក្នុងទីនេះបាន ប៉ុន្តែទោះជាច្រើនដូច្នោះ ក៏សង្កេតសព្វគ្រប់ទៅឃើញថា ចម្រៀងប្រជាប្រិយខ្មែរទាំងប៉ុន្មានទោះជាយ៉ាងណាក៏សុទ្ធតែទុកជាសម្រែកចិត្តរបស់ប្រជាជនខេមរជាតិទាំងអស់ ហើយជារបស់មានប្រយោជន៍ដោយយ៉ាងទៅតាមទំនុកតាមបទ ប្លែកតែខ្លះតិចខ្លះច្រើន ដែលស្រង់ទំនុកខ្លះមកពោលខាងដើមនេះ សង្ខេបណាស់គ្រាន់តែជាឧទាហរណ៍ និងជាបទពិចារណាជូនបងប្អូនជនរួមជាតិពិចារណាប៉ុណ្ណោះ សូមបញ្ចប់ត្រឹមប៉ុណ្ណោះ ។

ដកស្រង់ដោយលោក **ចែមផាន**

*និគមវចនៈ*

| | |
|---|---|
| *ចម្រៀងខ្មែរបាត់ជាតិខ្មែរបង់* | *មិនឋិតនៅគង់យូរប៉ុន្មាន* |
| *ចម្រៀងខ្មែររស់ខ្មែររស់បាន* | *ជនខ្មែរគួរមានភក្តីភាព ។* |
| *រក្សាចម្រៀងខ្មែរឱ្យនៅ* | *ចម្រើនតទៅជារៀងរាប* |
| *ឱ្យវិតតែខ្ពស់កុំឱ្យទាប* | *កុំសាបរលាបដល់អវសាន។* |

**បណ្ឌិតចាបពិន**

# ប្រវត្តិនៃការអប់រំក្នុងពិភពលោក (ត)

## ៥.ការអប់រំ តាមអរិយធម៌ក្រិច និងរ៉ូម៉ាំងបុរាណ

ប្រវត្តិអប់រំនៃក្រិច និងរ៉ូមបុរាណ បានបំភ្លឺដល់ដើមកំណើតនៃបញ្ហាដែលតស៊ូជាច្រើន ដែលគ្រូនាពេលសព្វថ្ងៃត្រូវប្រឈមមុខ។ ក្នុងចំណោមបញ្ហាអប់រំ ជនជាតិក្រិចនិងរ៉ូម៉ាំង ដែលបានពិភាក្សាគឺអ្វីគឺ ពិត ល្អ ល្អស្អាត ? អ្នកណាជាគំរូដ៏មានតម្លៃសម្រាប់កុមារត្រាប់តាម ? តើការអប់រំបង្កើតពលរដ្ឋល្អឬទេ ? តើការអប់រំគួរតែឆ្លើយតបទៅនឹងការផ្លាស់ប្តូរខាងសង្គម សេដ្ឋកិច្ច និងនយោបាយដូចម្តេច ?

**ក. ការអប់រំតាមបែបហូមែរ** (Homeric Education)

ជំនាន់មនុស្សទាំងឡាយ បានធ្វើឱ្យកើតបនូវចំណោទសួរនៃកំណាព្យរឿកថារបស់Homerគឺ Iliad and Odysey ដោយបានបង្ហាញខ្លួន នៅប្រហែលឆ្នាំ១២០០មុនគ.ស.រឿកថារបស់Homerជួយឱ្យជនជាតិក្រិចកំណត់ខ្លួនគេនិងវប្បធម៌របស់គេ ។ ប្រៀបដូចជាពិធីទាំងឡាយ នៅក្នុងសង្គមមនុស្សមិនទាន់ចេះអាន និងសរសេរនោះ ការពិពណ៌នាគួរឱ្យរំភើបចិត្តរបស់Homer នៃអ្នកធ្វើចម្បាំងជាតិក្រិចប្រឆាំងនឹង Trojans ត្រូវបានយកមកប្រើជាគោលបំណងអប់រំដ៏សំខាន់ ៖

១. វាបានរក្សានូវវប្បធម៌ តាមការផ្ទេរវា ពីមនុស្សចាស់ទៅមនុស្សក្មេង ។

២. វាបានអប់រំអត្តសញ្ញាណវប្បធម៌ជនជាតិក្រិច ដោយផ្អែកលើប្រភពរឿងនិទាន និងប្រវត្តិសាស្ត្រ ។

៣. វាបង្កើតអត្តចរិតយុវវ័យ[1] ។

Agamemnon, Ulysses, Achilles និងអ្នកច្បាំងផ្សេងទៀត បានដើរតួគួរឱ្យរំភើបនូវទំហំជីវិតវិរបុរស ដោយប្រើវិរបុរសទាំងនោះ ជាតួនាទីគំរូ។ ជនជាតិក្រិចក្មេងៗ បានសិក្សាអំពីតម្លៃ ដែលបានបង្កើតជីវិតឱ្យមានតម្លៃអាកប្បកិរិយាដែលបានរំពឹងចេញវិរជនសង្គ្រាម និងអនិបុណភាពអត្តចរិត ដែលនាំទៅដល់ការចុះរាសីរបស់គេ[2]។

**ខ. ការអប់រំភាពជាពលរដ្ឋ**

ក្រិចបុរាណបានធ្វើឱ្យចម្រើនដល់តួនាទីការអប់រំ ក្នុងការបង្កើតពលរដ្ឋល្អ។ ដូចជាជនជាតិអាមេរិចកាំង ទំនងជាមិនយល់ស្របទៅលើរូបមន្តជាក់លាក់ សម្រាប់អប់រំពលរដ្ឋល្អ ដូចនេះជនជាតិក្រិចក៏បានពិភាក្សាទៅលើបញ្ហានេះដែរ។ មិនដូចមហាចក្រភពចិននិងអេហ្ស៊ីបក្រិចបុរាណបានចែកជាផ្នែកតូចៗហើយជាញឹកញាប់ប្រកួតប្រជែងរដ្ឋដែលជាទីក្រុងដូចជាអាថែន និងស្ប៉ាត (Athens and Sparta) បានកំណត់ន័យការទទួលខុសត្រូវ និងសិទ្ធិពលរដ្ឋខុសៗគ្នា ។ ក្រោយពេលធ្វើការពិសោធជាមួយទម្រង់រដ្ឋាភិបាលផ្សេងៗគ្នាអាថែនបានក្លាយជារដ្ឋប្រជាធិបតេយ្យ ដែលសង្កត់ធ្ងន់ទៅលើការទទួលខុសត្រូវជាសាធារណៈរួមទាំងពលរដ្ឋរបស់ខ្លួន។ ស្ប៉ាតជាគូប្រជែងរបស់អាថែន គឺជាការប្រើអំណាចផ្តាច់ការខាងយោធា (Authoritarian military dictatorship)[3] ។ ដើម្បីប្រៀបធៀបរដ្ឋាភិបាលឱ្យខុសគ្នា រដ្ឋជាទីក្រុងនីមួយៗ មានប្រភេទនៃការអប់រំពលរដ្ឋរបស់ខ្លួន ។

**គ. ការបង្កើតការអប់រំ និងការអប់រំក្នុងប្រព័ន្ធ**

ជនជាតិក្រិចទទួលស្គាល់សារៈសំខាន់នៃការអប់រំដែលកំពុងមានអន្តរកម្ម គឺការធ្វើឱ្យមានការជ្រួតជ្រាប និងការចូលរួមក្នុងវប្បធម៌ទាំងមូលរបស់រដ្ឋជាទីក្រុង ជាមួយការអប់រំក្នុងប្រព័ន្ធ ។ តាមរយៈការបង្កើតឱ្យមានការអប់រំយុវវ័យជនជាតិក្រិចត្រូវបានត្រៀមរៀបចំដើម្បីឱ្យក្លាយជាពលរដ្ឋនៃសង្គមរបស់គេ ។ ការអប់រំក្នុងប្រព័ន្ធផ្តល់ចំណេះដឹងចាំបាច់ដើម្បីបំពេញក្តីសង្ឃឹមនៃជីវិតក្នុងសង្គមទាំងមូលថែមទៀត ។ ឧទាហរណ៍ ពួកអាថែនជឿថា មនុស្សដែលមានសេរីភាព ចាំបាច់

1 Louis Goldman, Home,Literacy, and Education,*Educational Theory* (Fall 1989),pp.391-400
2 Robert Homes Beck, The Iliad: Principle and Lessons, *Educational Theory* (Spring 1986),pp179-195
3Nigel M. kennel, The *Gymnasium of Virtue: Education and Culture in Ancient Sparta* (Chapel Hill: University of South Carolina Press,1995)

ត្រូវមានការអប់រំដែលប្រកបដោយសេរីភាព ដើម្បីបំពេញករណីយកិច្ចពលរដ្ឋ ព្រមទាំងអភិវឌ្ឍជាបុគ្គល [4] ។ ផ្ទុយទៅវិញ ស្ប៉ាតប្រើការអប់រំក្នុងប្រព័ន្ធ សម្រាប់ការបណ្តុះបណ្តាលយោធា ។

**ឃ. តួនាទីនៃទាសករ**

សង្គមក្រិច ជាប់ពាក់ព័ន្ធទៅតាមផ្នែកជាមួយទាសករ ។ ភាគច្រើននៃទាសករ ដែលរួមបញ្ចូលទាំងស្ត្រី និងកុមារ គឺជាឈ្លើយសង្គ្រាម ឬ អ្នកទាំងឡាយ ដែលបានថ្កោលទោសដោយច្បាប់ចំពោះសេវកគតិភាព ។ ទោះបីជាទាសករដែលមានការអប់រំតិចតួច កូនសិស្សទោលជាអ្នកមានក្នុងក្រុងអាថែនក៏ដោយ ក៏ទាសករភាគច្រើន ត្រូវបានគេបណ្តុះបណ្តាលដើម្បីឱ្យចេះធ្វើកសិកម្ម ឬបំណិនខាងពាណិជ្ជកម្ម ។ ពួកអាថែន ជឿជាក់ថា ការអប់រំប្រកបដោយសេរីភាពសមរម្យសម្រាប់មនុស្សសេរី គឺឥតមានប្រយោជន៍សម្រាប់ទាសករ ។ ការពិភាក្សាសម័យទំនើបរវាងអ្នកគាំទ្រនៃការអប់រំសេរី និងវិជ្ជាជីវៈ បានវិលត្រឡប់ទៅរកភាពខុសគ្នានៃពួកអាថែន រវាងការបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ពួកទាសករ និងការអប់រំសេរី សម្រាប់ពលរដ្ឋសេរី។

**ង. ការអប់រំស្ត្រី**

ក្នុងសង្គមក្រិច ដែលគ្របដណ្តប់ដោយពួកបុរស មានតែស្ត្រីក្នុងករណីលើកលែងភាគតិចប៉ុណ្ណោះ ដែលទទួលបានការអប់រំក្នុងប្រព័ន្ធខ្លះៗ ។ ក្នុងក្រុងអាថែន ស្ត្រីមានសិទ្ធិខាងសេដ្ឋកិច្ច និងស្របច្បាប់តាមដែនកំណត់បំផុត ហើយស្ត្រីភាគតិចបំផុត បានចូលរៀន ។ ស្ត្រីក្មេងៗដែលមានសំណាងជាង ទទួលបានការបង្រៀននៅនឹងផ្ទះពីគ្រូបង្រៀនសិស្សទោល ។ ស្ត្រីផ្សេងទៀតដូចជាបព្វជិតជាស្ត្រីនៃនិកាយសាសនាផ្សេងៗ បានសិក្សាទម្លាប់ខាងសាសនា នៅសាលារៀនតាមព្រះវិហារ ។ ផ្ទុយទៅវិញ ស្ត្រីក្មេងៗរបស់ពួកស្ប៉ាត ទទួលបានការបណ្តុះបណ្តាលខាងយោធា និងកីឡាកាយសម្ព័ន្ធ ដើម្បីរៀបចំពួកគេជាម្តាយដែលមានសុខភាពនៃទាហានស្ប៉ាតនាពេលអនាគត ។

**៥.១. ពួកសូហ្វីស**

នៅក្នុងសតវត្សទី ៥ មុនគ.ស.សេដ្ឋកិច្ចដែលកំពុងផ្លាស់ប្តូរ បាននាំមកនូវគំរូខាងអប់រំ និងសង្គមថ្មី ទៅដល់ក្រិចជាពិសេសអាថែន។ វណ្ណៈអភិជន (Aristocracy) ដែលមានវ័យចំណាស់ បានប្តូរកន្លែងដោយវណ្ណៈពាណិជ្ជករថ្មី ដែលមានផលចំណេញពីការរីកដាលពីពួកអាថែន និងអាណានិគមកម្ម ។ ការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គមនេះបង្កើតបានលក្ខខណ្ឌសម្រាប់ពួកសូហ្វីស។

**ក. គ្រូដែលដើរត្រាច់ចរ**

ពួកសូហ្វីសដែលជាក្រុមអ្នកអប់រំដែលកំពុងធ្វើដំណើរ បានអភិវឌ្ឍវិធីបង្រៀនថ្មី ដើម្បីបង្រៀនវណ្ណៈពាណិជ្ជករថ្មី តាមបំណិនការនិយាយសាធារណៈ ។ ភាពគ្រប់គ្រាន់ក្នុងសិល្បៈនៃការថ្លែងសុន្ទរកថាសំខាន់ខ្លាំងណាស់ក្នុងសង្គមប្រជាធិបតេយ្យ ដូចជាអាថែន ដែលវាត្រូវបានគេប្រើដើម្បីបញ្ចុះបញ្ចូលកិច្ចប្រជុំ និងព្រះរាជបរិវារឱ្យពេញចិត្ត [5] ។

**ខ. វេយ្យាករណ៍ តក្កវិទ្យា និងវោហារសាស្ត្រ**

ពួកសូហ្វីសស្វែងរកអភិវឌ្ឍបំណិនទំនាក់ទំនងរបស់សិស្ស ដើម្បីឱ្យគេអាចក្លាយជានីតិពន្ធ និងអ្នកគាំទ្រដ៏មានជោគជ័យ ។ ប្រធានបទសំខាន់បំផុតរបស់ពួកសូហ្វីសតក្កវិទ្យា វេយ្យាករណ៍ និងវោហារសាស្ត្រ គឺជាប្រធានបទ ដែលត្រូវបានអភិវឌ្ឍនៅពេលក្រោយមក ទៅជាសិល្បៈសេរី ។ តក្កវិទ្យា គឺជាវិធាននៃអំណះអំណាងដ៏ត្រឹមត្រូវ បានបណ្តុះបណ្តាលនិស្សិត ឱ្យចេះរៀបចំការបង្ហាញរបស់គេបានច្បាស់លាស់ ហើយនិងវេយ្យាករណ៍ បានអភិវឌ្ឍថាមពលនៃការប្រើប្រាស់ភាសាឱ្យមានប្រសិទ្ធភាព វោហារសាស្ត្រ ដែលជាការសិក្សាសម្តីបញ្ចុះបញ្ចូល មានសារៈសំខាន់ពិសេស សម្រាប់អ្នកថ្លែងសុន្ទរកថា នាពេលអនាគត ។

(នៅមានត) **លោកអនុបណ្ឌិតសូ សុធីរ**

4 Kevin Robb, *Literacy and Paideia in Ancient Greece* (New York:Oxford University Press,1994)
5The Philosophy of the Sophists, http:www.radicalacademy.com/philosophists.htm.

# ប្រវត្តិប្រទេសកម្ពុជា មនុស្សដើមដូនតាខ្មែរ

តាមការស្រាវជ្រាវរបស់ជាតិពន្ធុវិទូបានឱ្យដឹងថា នៅអាស៊ីខាងកើត ដំបូងមានអំបូរមនុស្សដើមធំបីគឺ អំបូរម៉ុងគោឡូអ៊ីត អំបូរឥណ្ឌូនេស៊ីយាង និងអំបូរមេឡានេស៊ីយាង ។ អំបូរម៉ុងគោឡូអ៊ីតចុះមកខាងត្បូង បង្កើតបានជាតិផ្សេងៗមានចិន ទីបេ ជប៉ុន និងកូរ៉េជាដើម ។ ចំណែកអំបូរឥណ្ឌូនេស៊ីយាង និងអំបូរមេឡានេស៊ីយាង ចុះមកខាងត្បូងរួមរស់ជាសម្ព័ន្ធគ្រួសារបង្កើតបានអំបូរមនុស្សមួយក្រុមថ្មីទៀត រស់នៅជាកុលសម្ព័ន្ធផ្សេងៗដាច់ពីគ្នា ចាប់ពីព្រំដែនប្រទេសឥណ្ឌាទៅប្រទេសចិន រហូតដល់សមុទ្រ( សមុទ្រចិនសព្វថ្ងៃ )។ អំបូរមនុស្សថ្មីនេះដែលក្រោយមកគេឱ្យឈ្មោះថា អំបូរខ្មែរ-មន។

ចំណែកពួកឥណ្ឌូនេស៊ីយាងខ្លះទៀតចុះទៅរស់នៅលើកោះទាំងឡាយនៃប្រទេសឥណ្ឌូនេស៊ីសព្វថ្ងៃ ហើយពួកមេឡានេស៊ីយាងខ្លះទៀតចុះទៅរស់នៅលើឧបទ្វីបដែលជាប្រទេសម៉ាឡេស៊ីសព្វថ្ងៃ ដោយពុំមានរួមសម្ព័ន្ធបង្កើតបានជាអំបូរមនុស្សថ្មីទៀតទេ ។ ឥឡូវយើងស្វែងយល់ពីពាក្យថា ខ្មែរ-មន ។ តើពាក្យនេះមានន័យដូចម្តេចខ្លះ ? ហើយអ្នកណាជាអ្នកឱ្យឈ្មោះនេះ ? មនុស្សដើមដែលជាអំបូរខ្មែរនេះ រស់នៅជាកុលសម្ព័ន្ធ តូចធំដាច់ពីគ្នា មានមេកើយត្រួតត្រាដែលគេឱ្យឈ្មោះថា មេកន្ទ្រាញ ។ ពួកនេះរស់នៅលើទឹកដីដែលរៀបរាប់ខាងលើតាំងពីយូរណាស់មកហើយ ពុំដែលមានទទួលអរិយធម៌ពីតំបន់ណាផ្សេងទេ ។ រវាងឆ្នាំ ២៣៤ នៃព.ស. ទើបមានពុទ្ធសាសនាថេរវាទ គឺជាសង្ឃដែលចេញពីឥណ្ឌាមកផ្សាយធម៌របស់ព្រះពុទ្ធដល់ពួកមនុស្សទាំងឡាយដែលរស់នៅពីព្រំដែនចិនទៅឥណ្ឌា រហូតដល់សមុទ្រ (សមុទ្រចិន) ព្រមទាំងលើកោះទាំងឡាយនៃប្រទេសឥណ្ឌូនេស៊ីនិងម៉ាឡេស៊ីសព្វថ្ងៃនេះ ។

ដំបូងក្រុមផ្សាយពុទ្ធសាសនានេះបានចូលទៅទឹកដីរបស់កុលសម្ព័ន្ធដែលនៅត្រង់ប្រទេសភូមាសព្វថ្ងៃនេះ ។ ពួកកុលម្ព័ន្ធទាំងនោះបានទទួលអបអរសាទរចំពោះព្រះសង្ឃនិងក្រុមមនុស្សដែលចូលទៅផ្សព្វផ្សាយពុទ្ធសាសនា ដោយមានព្រះសង្ឃជាប្រធានព្រមទាំងយកចិត្តទុកដាក់ជួយឧបត្ថម្ភគ្រប់បែបយ៉ាង ។ ដោយឃើញពួកកុលសម្ព័ន្ធទាំងនោះមានមនោសញ្ចេតនាល្អដូចនេះ ក្រុមមនុស្សនិងព្រះសង្ឃដែលចូលទៅផ្សព្វផ្សាយសាសនាបានប្រសិទ្ធនាមពួកនោះជាភាសាបាលីថា «**មនៈ** »គឺអ្នកមានចិត្តល្អ ។

ក្រោយពីបណ្តុះបណ្តាលពួក**មនៈ**នេះឱ្យបានជ្រួតជ្រាបពីទ្រឹស្តីពុទ្ធសាសនា និងបំបួសជាសង្ឃបានច្រើន បង្កើតជាវត្តអារាមរួចហើយ ពួកក្រុមផ្សព្វផ្សាយពុទ្ធសាសនាក៏បន្តចូលមកទឹកដីមនុស្សដើមជាបុព្វបុរសខ្មែរ ដែលរស់នៅព្រំដែនចិនរហូតដល់សមុទ្រចិន ។ ក្រោយពីបានផ្សព្វផ្សាយទ្រឹស្តីព្រះពុទ្ធសាសនាដល់កុលសម្ព័ន្ធទាំងនោះជាច្រើនកន្លែងមកក៏សង្កេតឃើញថា ទឹកដីរបស់កុលសម្ព័ន្ធដែលជាបុព្វបុរសខ្មែរ ជាទឹកដីមហាសាល សម្បូរដោយសម្បត្តិធម្មជាតិសម្រាប់មនុស្សរស់នៅ ក៏ប្រសិទ្ធនាមឱ្យឈ្មោះពួកទាំងនោះជាភាសាបាលីថា « **ខេមរៈ** » មានន័យថាជនដែលសុខកាយសប្បាយចិត្ត ពុំមានខ្វះខាតអ្វីទាំងអស់ ។

ពួកអ្នកផ្សព្វផ្សាយពុទ្ធសាសនា បានបំបួសអ្នកកុលសម្ព័ន្ធជាព្រះសង្ឃ ជាបន្តបន្ទាប់រួចចាត់ព្រះសង្ឃទាំងនោះចេញផ្សព្វផ្សាយព្រះធម៌គ្រប់ទិសទីលើទឹកដីជន ខេមរៈ ។ ក្រៅពីបង្រៀនធម៌របស់ព្រះពុទ្ធ ពួកអ្នកផ្សព្វផ្សាយសាសនាទាំងនោះក៏បានបង្រៀនភាសាផងដែរដល់ពួក**ខេមរៈ** ដើម្បីងាយស្រួលទាក់ទងគ្នាពីកុសម្ព័ន្ធមួយទៅកុលសម្ព័ន្ធមួយទៀត ព្រោះកុលសម្ព័ន្ធនីមួយៗមានភាសានិយាយរៀងៗខ្លួនសម្រាប់ទំនាក់ទំនងតែនៅក្នុងកុលសម្ព័ន្ធរបស់ខ្លួនតែប៉ុណ្ណោះ ។ ឧទាហរណ៍ ៖ បាយដែលយើងបរិភោគសព្វថ្ងៃ គឺកុលសម្ព័ន្ធមួយហៅថាអ្វីផ្សេងពីកុលសម្ព័ន្ធមួយទៀត ។ ទើបតែពួកផ្សព្វផ្សាយសាសនាព្រះពុទ្ធដែលបង្រៀនពីពុទ្ធប្រវត្តិថា ព្រះពុទ្ធបានត្រាស់ដឹងក្រោយពីឆាន់ **មធុបាយាស** របស់នាងសុជាតា ជាសេដ្ឋីធីតានៅតំបន់ឧរុវេលនិគម ។ **មធុបាយាស** គឺបាយលាយទឹកឃ្មុំ ចំពោះបាយយើងបរិភោគសព្វថ្ងៃគ្មានលាយទឹកឃ្មុំទេ ដូចនេះត្រូវហៅថា «បាយ » បានហើយ ។ ចាប់ពីពេលនោះមកកុលសម្ព័ន្ធទាំងអស់បានឯកភាពហៅថា

បាយៗ ហើយចាត់ទុកបាយជាព្រះមេ (ក្លាយពីព្រះម៉ែ ជាអ្នកមានគុណ) នេះជាឧទាហរណ៍មួយប៉ុណ្ណោះ ខ្ញុំពុំអាចរៀបរាប់អស់ទេ ។ សព្វថ្ងៃភាសាខ្មែរប្រើពាក្យបាលីជាច្រើន ។

ចាប់ពីពេលនោះមក ខេមរជនបានរស់នៅដោយសុខសាន្ត មានទំនាក់ទំនងគ្នាពីកុលសម្ព័ន្ធមួយទៅកុលសម្ព័ន្ធមួយ រស់នៅមានសណ្ដាប់ធ្នាប់ មានច្បាប់ទម្លាប់ ជាជនមានអរិយធម៌ ។ ក្រោយមកមានកុលសម្ព័ន្ធផ្សេងបានចុះមកពីខាងជើងចូលមករស់នៅជាមួយពួកខេមរៈ ។ ប៉ុន្តែពួកចូលមកថ្មីនេះ ពុំមានសណ្ដាប់ធ្នាប់ជាជនមានអរិយធម៌ទេ ជាហេតុបង្កឱ្យមានការប្រទូស្តជាមួយខេមរៈ ។ ពេលនោះ ពួកពុទ្ធបរិស័ទដែលនៅទីនោះបានទៅសម្រុះសម្រួល ដោយចង្អុលទៅពួកចូលមកនៅថ្មីជា « **សាមណេរ** » គឺអ្នកចូលថ្មីពុំទាន់ស្គាល់ច្បាប់ទម្លាប់អ្វីទេ ចូរប្រព្រឹត្តិនូវមេត្តាធម៌ ចំពោះពួកនោះ ហើយឱ្យពួកថ្មីសូមទោសពួកខេមរៈថា « **ខមាទោស** » ។

ចាប់ពីពេលនោះមក ពួកខេមរៈហៅអ្នកចូលថ្មីថា «សាមណេរៗ » ហើយពួកសាមណេរនិយាយទៅពួកខេមរៈថា «**ខមាទោសៗ**»។ ក្រោយមកពាក្យថ«**សាមណេរ**»នូវត្រឹម«**សាម** »ហើយពាក្យ«**ខមាទោស**»នៅត្រឹម« **ខមៈ** »។

ចំណែកព្រះសង្ឃជាខេមរជនកាន់តែមានច្រើនឡើងៗ ហើយនិមន្តផ្សព្វផ្សាយធម៌ព្រះពុទ្ធគ្រប់ទិសទី ។ ប្រហែលជាមានខេមរសង្ឃខ្លះនិមន្តទៅទស្សនាបូជនីយដ្ឋានផ្សេងៗនៅក្នុងប្រទេសឥណ្ឌា ហើយបានជ្រើសរើសឈ្មោះនគរមួយនៅឥណ្ឌា គឺ «**កម្ពោជៈ**»មកដាក់ឈ្មោះនគររបស់ខ្លួន គឺ «**កម្ពុជរដ្ឋ**» ។ ម៉្យាងទៀត នៅប្រទេសគេមានអក្សរប្រើប្រាស់ខេមរសង្ឃទាំងឡាយក៏បានខិតខំបង្កើតតួអក្សរដើម្បីកត់ត្រាផ្សេងៗ ។ ក្រោយពីមានអក្សរសម្រាប់ប្រើប្រាស់ខេមរសង្ឃយល់ឃើញថាភាសាដែលខេមរជនប្រើប្រាស់សុទ្ធតែភាសាបាលី លោកក៏ប្រឹងប្រែងកម្លាយភាសាបាលីខ្លះឱ្យមកជាភាសាខ្មែរ ។ ក្នុងវិធីកម្លាយនេះ គឺយកតួអក្សរទីពីរមកដាក់ពីក្រោមតួអក្សរទីមួយ ។ ឧទាហរណ៍ ពាក្យថា « **បុរស** » ជាភាសាបាលី ក៏កម្លាយឱ្យមកជា « **ប្រុស** » ជាខេមរភាសា ដោយយកតួអក្សរ« **រ** » មកដាក់ក្រោមតួអក្សរ « **ប** » ។ « **សិរី** » ទៅ « **ស្រី** » «**បតី**» ទៅជា « **ប្ដី** » « **ខេមរៈ** » ទៅជា « **ខ្មេរ** » ក្រោយមកទៅជា « **ខ្មែរ** » ។ ល ។

លុះយូរលង់ក្រោយមក ខ្មែរយើងអានភាសាបាលីមកជាសម្រាយ ឧទាហរណ៍ ៖ « **មនៈ** »អានថា « មន » «**ខមៈ** » អានថា « ខម » «**នមោ** » អានថា « នមោ » ។ ពីដើមមានសាលារៀនតែនៅទីក្រុងទេ ម៉្លោះហើយកូនអ្នកស្រុកស្រែត្រូវទៅរៀននៅវត្ត ។ នៅវត្តមុននឹងចាប់រៀនតួព្យញ្ជនៈ ព្រះសង្ឃតម្រូវឱ្យរៀន« **នមោ ពុទ្ធាយ សិទ្ធំ** » (ដោយអានថា ៖ នមោ-ពុទ -ធា -យ-សិទធំ)។ ពេលសិស្សចេះអាន ចេះសរសេរស្ទាត់ហើយទើបចាប់រៀនតួព្យញ្ជនៈ ។

មានគេសួរសម្ដេចសង្ឃរាជ ជួនណាត « តើ «នមោ »មានន័យដូចម្ដេច ? លោកមានសង្ឃដីកាថា ៖ ពីដើមមកសិស្សទៅរៀននៅវត្ត ត្រូវសូត្រថ្វាយបង្គំព្រះថា «**នមោ ពុទ្ធាយ សិទ្ធំ** » ជាភាសាបាលី ប៉ុន្តែក្រោយមកគេឈប់អានជាភាសាបាលី ។ គឺគេអានថា ន មោ ពុទ ធា យ សិទធំ » ។

ក្រោយបំផុតខ្មែរយើងអាន «**មនៈ** ទៅជា «មន» ,« **ខមៈ** »ទៅជា «ខម »(សៀមហៅខ្មែរយើងថា« **ខម** »)« **សាម** » ទៅជា «សៀម » «**ខេមរៈ** » ទៅជា « ខ្មែរ » រហូតមក ។

ប្រវត្តិទឹកដីដូនតាខ្មែរចប់តែប៉ុណ្ណេះ ។ លើកក្រោយខ្ញុំនឹងជំរាបជូនពីដែនដីសុវណ្ណភូមិ ។

អត្ថបទនេះ ខ្ញុំធ្វើការសិក្សាស្រាវស្រាវដោយផ្អែកលើពាក្យថា មន ខ្មែរ ខម និងសង្ឃដីកាខ្លះៗរបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត**។

*សូមបញ្ជាក់ ពុទ្ធសាសនាចូលមកដល់លើទឹកដីនៃមនុស្សដែលជាបុព្វបុរសខ្មែរ ប្រហែលជា២០០ឆ្នាំ មុនគ.ស. ពុទ្ធសាសនាប្រើភាសាបាលី ដូចនេះពាក្យណាដែលមិនមែនជាបាលីដូច មន ខម គឺជាពាក្យដែលបំភ្លៃក្នុងបំណងបំបាត់ដានប្រវត្តិសាស្ត្រ ។ រហូតមកដល់សព្វថ្ងៃក៏គេនៅបន្តបំភ្លៃពាក្យដូចជា សុខោទ័យ ទៅជាសុខោថៃ ។ ល ។*

**លោក ខោល គុន**

និវត្តជន



# ចិត្តវិទ្យាអប់រំ

## សម្បទា និងសម្បទាតរុកោសល្យរបស់គ្រូបង្រៀន

### I.សញ្ញាណទូទៅសម្បទា

**១. និយមន័យ ៖** សម្បទាជាលក្ខណៈចិត្តស្មុគស្មាញរបស់បុគ្គល ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់បំពេញសកម្មភាពណាមួយឱ្យទទួលបានផលល្អ ។

**ឧទាហរណ៍ ៖** សិស្ស « ក » មានសម្បទាផ្នែកគណិតវិទ្យា ។ សិស្សនេះមានសមត្ថភាពអាចធ្វើលំហាត់គណិតវិទ្យាបានដោយស្រួល ហើយរហ័សទៀតផង។

សម្បទាមានអត្ថន័យធំធេងណាស់ចំពោះសង្គម និងមនុស្សគ្រប់រូប ។ ការអភិវឌ្ឍសម្បទារបស់បុគ្គលម្នាក់ៗបានផ្ដល់ដល់សង្គមនូវលទ្ធផលថ្មីៗ លើគ្រប់វិស័យ ដូចជា សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស សិល្បៈ ... ដែលនាំឱ្យសង្គមមានការរីកចម្រើនឈានទៀងយ៉ាងឆាប់រហ័ស ។

**ឧទាហរណ៍ ៖** សម្បទាផ្នែកវិទ្យាសាស្ត្រ និងបច្ចេកទេសរបស់អ្នកប្រាជ្ញក្នុងលោក ។

ម៉្យាងទៀត សម្បទារបស់បុគ្គលម្នាក់ៗដែលលេចឡើង ត្រូវតែធ្វើវិក្រិតការឱ្យទាន់ពេលវេលា ព្រោះនេះជាក្រឹត្យក្រមនៃលក្ខខណ្ឌដែលនាំមកនូវផលប្រយោជន៍សម្រាប់កែលំអបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗ ។

**ឧទាហរណ៍ ៖** បើឃើញមនុស្សម្នាក់មានសំឡេងល្អ គេត្រូវបណ្ដុះបណ្ដាលបន្ថែមដោយបង្ហាត់គេឱ្យច្រៀង ដើម្បីឱ្យគេក្លាយទៅជាអ្នកចម្រៀងដែលប្រកបដោយគុណភាព ... ។

ការបំពេញសកម្មភាពបានល្អ គឺជាលទ្ធផលនៃការគួបផ្សំនៃសម្បទាច្រើនចូលគ្នា ។

**២. ប្រភេទផ្សេងៗនៃសម្បទា**

តាមការអភិវឌ្ឍសម្បទា គេអាចចែកសម្បទាជាពីរប្រភេទ ៖

**ក. សម្បទាបង្កើតឡើងវិញ ៖** គឺជាសម្បទារបស់បុគ្គលម្នាក់ៗ ដែលផ្ដល់លទ្ធផលបានល្អនៅក្នុងការសិក្សានៅក្នុងការសម្រេចសកម្មភាពផ្សេងៗតាមគំរូកំណត់ ។

**ឧទាហរណ៍ ៖** សិស្សខ្លះក្រោយពីបានស្ដាប់ការពន្យល់របស់គ្រូ គេអាចពន្យល់មេរៀន ព្រមទាំងអាចស្រាយបញ្ជាក់លំហាត់បានដូចគ្រូដែរ ។

**ខ. សម្បទាច្នៃប្រឌិត ៖** គឺជាសម្បទារបស់មនុស្សម្នាក់ៗ ដែលប្រើវិធីថ្មីនៅក្នុងសកម្មភាព ដោយទទួលបានផលល្អប្រសើរ ។

**ឧទាហរណ៍ ៖** ការនិពន្ធកំណាព្យបានល្អ ការគូររូបបានល្អ ។

កោសល្យ គឺជាសម្បទាលើសកម្មភាពមួយចំនួនធំ ដែលបុគ្គលម្នាក់ៗសម្រេចបានលទ្ធផលល្អប្រសើរ ។

ចំណែកទេពកោសល្យ គឺជាសម្បទាមួយបែបមានភាពស្មុគស្មាញ ដែលបុគ្គលម្នាក់សម្រេចបានលទ្ធផលល្អអស្ចារ្យ ហើយមានអត្ថន័យធំធេងចំពោះសង្គម និងមានតម្លៃមិនអាចកាត់ថ្លៃបាន ។

**ឧទាហរណ៍ ៖** លោក ប៉ាស្កាល់ (១៦២៣- ១៦៦២) ក្លាយជាអ្នកប្រាជ្ញនៅអាយុ ១៦ឆ្នាំ ដោយបានសរសេរនិក្ខេបបទស្តីអំពីការរកឃើញម៉ាស៊ីនគិតលេខ ។

**៣. មុខងារសម្បទា**

គេអាចចែកសម្បទាជាពីរប្រភេទ ៖

**ក. សម្បទាទូទៅ ៖**គឺជាសម្បទាដែលសម្រេចបានលទ្ធផលល្អនៅក្នុងវង្វង់សកម្មភាពច្រើន ។

**ឧទាហរណ៍ ៖** សម្បទាទូទៅក្នុងការសិក្សា ៖
- សម្បទាយល់ដឹង
- សម្បទាខាងការវិនិច្ឆ័យ
- សម្បទាខាងការគិត
- សម្បទានៃលំនឹកកម្ម
- សម្បទាអនុវត្តចំណេះដឹង ។

**ខ. សម្បទាពិសេស ៖** គឺជាសម្បទាដែលមានអត្ថន័យតែមួយនៅក្នុងវង្វង់សកម្មភាពពិសេសមួយ ។

**ឧទាហរណ៍ ៖** សម្បទាពិសេសខាងលំនឹកកម្ម ដូចជា សិស្សខ្លះស្តាប់កំណាព្យមួយចប់អាចចាំ និងសូត្រឡើងវិញបាន ... ។

**៤. ការបណ្តុះបណ្តាលនិងការអភិវឌ្ឍសម្បទា**

ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងក្នុងការអប់រំ គេតែងតែលើកយកមកនិយាយពី « និស្ស័យធម្មជាតិ » ។ប៉ុន្តែគ្មាននរណាដឹងពីប្រភពនៃ « និស្ស័យធម្មជាតិ »នេះឡើយ ។

**ក.** ចិត្តវិទូមួយចំនួន បានចាត់ទុកកោសល្យទាំងអស់ថា ជាការកំណត់ដោយតំណពូជ ហើយគ្មានការប្រែប្រួលឡើយ ។ គេបានគូសបញ្ជាក់តែនៅលើជាតុធម្មជាតិក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍនៃសម្បទាតែប៉ុណ្ណោះ ហើយគេទាត់ចោលជាតុសង្គម «ពិសេសការអប់រំ»ទាំងអស់ ។ការវាយតម្លៃសម្បទានេះនាំទៅរកការភាន់ច្រឡំប្រកបដោយគ្រោះថ្នាក់ តែគេប្រើវិធីនេះដើម្បីបម្រើផលប្រយោជន៍របស់វណ្ណៈមួយក្តាប់តូចប៉ុណ្ណោះ។

**ខ.** តាមទស្សនៈចិត្តវិទ្យាបច្ចុប្បន្នវិញ សម្បទាជាបាតុភូតចិត្តដែលត្រូវបានបណ្តុះ និងអភិវឌ្ឍក្នុងសកម្មភាពរបស់បុគ្គលម្នាក់ៗ ក្រោមឥទ្ធិពលនៃការអប់រំ ។

សម្បទា គឺជាលទ្ធផលនៃសកម្មភាពរបស់បុគ្គលក្នុងលក្ខខណ្ឌសង្គមប្រវត្តិជាក់លាក់ ។

ការអប់រំ និងការបង្រៀន មាននាទីសំខាន់ក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍសម្បទារបស់បុគ្គលម្នាក់ៗពិសេសរបស់មនុស្សជំនាន់ក្រោយ ។ ហេតុនេះគេត្រូវលើកកម្ពស់គុណភាពអប់រំ ដោយអប់រំគ្រូឱ្យមានការយល់ដឹងខ្ពស់ខាងសីលធម៌ និងសមត្ថភាព ។

**II. សម្បទាគរុកោសល្យរបស់គ្រូបង្រៀន**

សម្បទាគរុកោសល្យជាធ្នូបង្កើតសម្បទាគ្រប់វិស័យរបស់មនុស្ស ។ វីរជន និងអ្នកប្រាជ្ញ នៅលើសកលលោកតាំងពីសម័យបុរាណរហូតដល់សព្វថ្ងៃ កាលណាគេលើកយកមកនិយាយពីស្នាដៃរបស់គាត់នោះ គាត់មិនភ្លេចរំលឹកដល់អំពើល្អ ដែលគ្រូរបស់គាត់បានណែនាំគាត់នៅជំហានដំបូងទេ គឺពេលដែលសម្បទារបស់គាត់មិនទាន់រីកលូតលាស់នៅឡើយ ។ វីរជន និងអ្នកប្រាជ្ញទាំងនោះ នៅតែនឹកឃើញគ្រូរបស់គេជានិច្ច ទោះបីគេបានសម្រេចដល់ថ្នាក់វិទ្យាសាស្ត្រ ឬសិល្បៈកំពូលយ៉ាងណាក៏ដោយ ។

សម្បទាគរុកោសល្យ អាចផ្តើមចេញពីឧត្តមគតិវិជ្ជាជីវៈ និងការស្រឡាញ់សិស្សរបស់គ្រូ ។(នៅមានត)

**ឯកសារនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ**

# មាតាបិតា ពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុក តែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា(ត)

**១.២. អំពីពាក្យសម្ដីហិង្សាប្រចាំថ្ងៃ**

ហេតុអ្វីបានជាយើងប្រើពាក្យសម្ដីហិង្សា (គ្រោតគ្រាត)?

- គេធ្វើឱ្យអ្នកខឹងមែនឬ ? អ្នកមិនអាចអត់ទ្រាំបាន ពេលនោះជាក់ច្បាស់ណាស់អ្នកត្រូវតែខឹង ។ កាលបើមានកំហឹងកើតឡើងហើយ ពាក្យសម្ដី និងសូរសំឡេងពេញដោយភាពគ្រោតគ្រាត ។ បើដូច្នេះ តើមានពាក្យឯណាដែលផ្អែមល្ហែមទៅកើត ? ពាក្យត្រូវគ្របដណ្ដប់យ៉ាងលើសលប់ទៅលើសកម្មភាពដែលធ្វើឱ្យយើងមានកំហឹង។ នេះក៏អាចក្លាយជាសង្គ្រាមពាក្យសម្ដី ។

ចំពោះបុត្រធីតារបស់យើងវិញ តើគប្បីប្រើពាក្យសម្ដីហឹង្សានេះជាមួយដែរឬអត់ នៅពេលអ្នកទ្រាំកំហឹងពុំបាន ? នៅពេលនេះបុត្រធីតារបស់យើងជាសត្រូវរបស់អ្នកណា ក្នុងសង្គមគ្រួសារ ។

- ការជេរប្រមាថកូនដោយពាក្យអសុរោះ តើអ្នកបានសង្កេតឃើញ កូនទទួលលទ្ធផលស្របតាមគតិរបស់អ្នកកម្រិតណា?

- អ្នកមានធ្លាប់គិតឬក៏អាចពោលពាក្យប្រមាថ ដោយសម្ដីអសុរោះដូចជា មីនេះ អានេះ.... ជេរស្ដីដូចឆ្កែប៉ុណ្ណឹងហើយនៅតែមិនស្ដាប់ ឬនៅតែគ្មានកំណើត .... ឬក៏ពាក្យអសុរោះធ្ងន់ធ្ងរជាងនេះទៀត ។ តើនេះចាត់ទុកជាអំពើថយថោកគួរចៀសវាង ឬយ៉ាងដូចម្ដេច ?

ពុទ្ធសាសនិកជន ក៏ដូចជនជាតិខ្មែរគ្រប់រូប បានជ្រួតជ្រាបរួចមកហើយថា ការប្រមាថនាំមកនូវសេចក្ដីវិនាស ។

ការប្រមាថ ឬអំពើប្រមាថ អាចជាសកម្មភាពមានន័យសំដៅត្រង់ ឬប៉ុនប៉ង(ចេតនា)និងអាចជាអំពើដោយភ្លាំងភ្លាត់(អចេតនា)។

**ក. អំពើប្រមាថសំដៅត្រង់ ឬប៉ុនប៉ង**

អំពើដោយចេតនា ដែលធ្លាយចេញពីបេះដូងដោយភ្លើងកំហឹងពុះពោរ សំដៅចំពោះអ្នកដទៃជាគូបដិបក្ខឱ្យទាបថោកតាមគតិរបស់ខ្លួន តែមិនគប្បីឱ្យកើតឡើងសម្រាប់មាតាបិតាចំពោះបុត្រធីតានោះឡើយ។

**ខ. អំពើប្រមាថដោយអចេតនា**

កើតឡើងតែក្នុងគ្រួសារ ពិសេសជាការប្រព្រឹត្តរបស់មាតាបិតាចំពោះបុត្រធីតា ដែលពុំមែនជាគោលបំណងពិតប្រាកដ ។ បានសេចក្ដីថា ការជេរប្រមាថនេះ ដើម្បីបន្ធូរអារម្មណ៍ដែលកំពុងពុះកញ្ជ្រោលដោយភ្លើងកំហឹង ។ ការពិតគ្មានមាតាបិតាណាម្នាក់ចង់ឱ្យកូនមានស្ថានភាពជីវិត ដូចពាក្យសម្ដីប្រមាថរបស់ខ្លួនឡើយ ។

តើលោក-អ្នកយល់ដូច្នេះដែរឬទេ? សូមលោក-អ្នកសាកល្បងពិចារណា និងគូសសញ្ញា☑នៅក្នុងប្រអប់ណាមួយខាងក្រោមនេះ ៖

ពិតយ៉ាងនេះមែន □ មិនដូច្នោះទេ □

(ពេលណាមួយនឹងបានដឹង ដោយខ្លួនឯងផ្ទាល់) ។

ការជេរប្រមាថរបស់មាតាបិតា ទោះបីមិនត្រង់ ឬអចេតនាក្ដី មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ចំពោះបុត្រធីតារបស់អ្នក ។ ពីព្រោះអ្វី ?

បុត្រធីតារបស់អ្នកមិនអាចដឹងពីជម្រៅចិត្ត ឬគតិពិតរបស់លោក-អ្នកបានឡើយ ។ អ្វីដែលបុត្រធីតាទទួលបាននៅពេលនោះ គឺការជេរប្រមាថ ឬការប្រទេចផ្ដាសាដោយត្រង់ តែប៉ុណ្ណោះ ។

ពាក្យទំនៀមខ្មែរចារទុកថា គ្រូទាយ ម្ដាយថា វានឹងបង្ហាញផល ២យ៉ាងគឺ ៖

• ផ្នែកជំនឿក្នុងផ្លូវចិត្ត ចាត់ទុកថាពាក្យសម្ដីមាតាបិតា ជាសម្ដីព្រះ ពីព្រោះថាមាតាបិតា គឺជាព្រះកន្លោងដែលចិតនៅគ្រប់គ្រងបីបាច់រក្សាផ្ទាល់ ដែលចាត់ទុកថាជាមាត់ទិព្វ សម្ដីស័ក្ដសិទ្ធិ ។ យើងគ្រប់គ្នាតែងចង់បានការឱ្យពរជ័យសិរីមង្គលពីមាតាបិតា គ្មានណាម្នាក់សុំមាតាបិតាឱ្យប្រមាថ ឬដាក់បណ្ដាសា ទើបសប្បាយចិត្តនោះឡើយ ។ មែន □ មិនមែន □ សូមគូស ☑ ក្នុងប្រអប់ណាមួយ ។ ចំពោះពុទ្ធសាសនិកជន គឺមានជំនឿមុតមាំណាស់ក្នុងប្រការនេះ ។

• បើយើងវិភាគផ្នែកលោកិយវិញ អំពើពុំគប្បីនៃការជេរប្រមាថ ប្រទេចផ្ដាសាបែបនេះ ជាការដុតកម្ទេចផ្លូវក្ដីសង្ឃឹម ។ បុត្រធីតារបស់លោក-អ្នកបានឮហើយ ប្រាកដជាមិនសើចសប្បាយនោះឡើយ ។ ផ្ទុយទៅវិញ ទឹកមុខរបស់គេពោរពេញដោយភាពក្រៀមក្រំ សកម្មភាពស្រពាប់ស្រពោន ឬអាចភាពជូរចត់ជាងនេះ នឹងអាចជាអំពើស្ថិតនៅក្នុងការយល់ច្រឡំថា ជីវិតរបស់គេគ្មានន័យ ឬរស់គ្មានន័យ តើនឹងមានអ្វីកើតឡើង ។ ប្រសិនបើលោកអ្នកមានអំពើនេះមែន សូមលោក-អ្នក ធ្វើការសង្កេត ថាតើបុត្រធីតា នឹងមានភាពខុសប្រក្រតីអ្វីខ្លះ? ...គឺច្រើនយ៉ាង ដែលសុទ្ធតែជាបញ្ហាអវិជ្ជមាន។

លោកអ្នកប្រាជ្ញបុរាណខ្មែរទូន្មានថា ការបាត់បង់វត្ថុមួយ គឺជាការបាត់បង់ស្រាលមួយ ការបាត់បង់កិត្តិយសមួយ គឺជាការបាត់បង់ធ្ងន់មួយ រីឯការបាត់បង់សេចក្ដីសង្ឃឹម គឺជាការបាត់បង់ធ្ងន់ធ្ងរគ្រប់យ៉ាងនៃជីវិត ។

ការសោកស្ដាយដ៏ក្រៃលែងមួយ ឬភាពអាម៉ាស់នៃត្រកូលនឹងកើតឡើង នៅពេលដែលបុត្រធីតាគ្មានអនាគតត្រចះត្រចង់ ជាមនុស្សទាបថោក ដូចតាមការប្រមាថរបស់អ្នក ។

ដូច្នេះយើងជាមាតាបិតា សូមគិតថាទ្រព្យដែលថ្លៃបំផុតក្នុងលោក គឺទ្រព្យកូននេះហើយ ។

ចាប់តាំងពីថ្ងៃដំបូងនៃការចាប់បដិសន្ធិ រហូតបានមកជាទារក គឺលោកអ្នកមានការស្រឡាញ់ថ្នាក់ថ្នម បបោសអង្អែល សម្មិតសម្អាង ដាក់នាមប្រពៃ ថែបំប៉នសព្វយ៉ាង សូម្បីធូលីមួយគ្រាប់ ឬកូនស្រមោចមួយក្បាលនៅលើខ្លួនក៏ពុំបានចុះហេតុម្ដេចឡើយកូនធំពេញរូបពេញរាងបែរជាប្រមាថប្រទេចផ្ដាសាទៅវិញ ។ តើនរណាជាអ្នកបំផ្លាញកូនមុនគេ ? ឬក៏ទម្លាក់កំហុសទៅលើសង្គម ឬក៏សាលារៀន? មាតាបិតាពិត គឺជាមនុស្សមិនគេចវេះពីកំហុសរបស់ខ្លួន ទទួលស្គាល់របស់ខ្លួន រៀនសូត្រពីកំហុសរបស់ខ្លួន និងមិនធ្វើកំហុសដដែលៗ ។

ការជេរប្រមាថរបស់លោកអ្នកជាមាតាបិតា វាពុំមែនជាសកម្មភាពអប់រំ តែវាជាជម្លោះមួយ។ ជម្លោះគឺជាសង្គ្រាម។ សង្គ្រាម គឺជាការច្បាំងរវាងភាគី ២ ជាសត្រូវនឹងគ្នាដែលមានលទ្ធផលចាញ់ឬឈ្នះ។ ការជេរប្រមាថរបស់លោកអ្នកជាមាតាបិតា គ្រាន់តែជាការយកឈ្នះលើបុត្រធីតាតែប៉ុណ្ណោះ ។ ការជេរប្រមាថ ជាទណ្ឌកម្មផ្លូវចិត្ត និងជាដំណាក់កាលទាល់ច្រករបស់អ្នកអប់រំ ។ ការអប់រំជាការលាតត្រដាងបង្ហាញហេតុផល និងផ្ដល់ចំណេញទាំងសងខាង។ យើងគ្រប់គ្នាពិតជាមានឆន្ទៈដូចគ្នា គឺធ្វើជាមាតាបិតាមានសមត្ថភាព កសាងសុភមង្គលក្នុងគ្រួសារយ៉ាងជាក់ប្រាកដណាស់ ។

សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បានចារបញ្ជាក់ពន្យល់យ៉ាងច្បាស់នៅក្នុងវចនានុក្រមខ្មែររបស់ព្រះអង្គអំពីពាក្យប្រមាថ និងប្រទេចផ្ដាសា គឺមានន័យថា ៖

**ប្រមាថ** (ន.)(សំ.)(---ម៉ាត) ការបៀតបៀនគេ, ការញាំញីគេ, ការធ្វើទុក្ខបុកម្នេញឱ្យគេលំបាក, ការមើលងាយគេ។ ប្រើជាកិ.ក៏បានមនុស្សប្រមាថសត្វ គឺមនុស្សបៀតបៀនសត្វ ។ មនុស្សប្រមាថចាស់ គឺមនុស្សមើលងាយចាស់។ ប្រមាថកាតទានមើលងាយ បៀតបៀនគេឱ្យគេខាតលាភប្រយោជន៍(វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ**ជួន ណាត**)។

**ប្រទេចផ្ដាសា** (កិ) ជេរដោយពាក្យបួងបាច់ឱ្យគេវិនាសអន្តរាយហិនហោច ។ ប្រទេចផ្ដាសា ប្រទេចដាក់បណ្ដាសាឱ្យគេវិនាសហិនហោច (វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត**)។

តើអ្នកគិតថាគួរជេរប្រមាថប្រទេចផ្ដាសា តាមកំហឹងដែលជាអំពើសង្គ្រាមជាមួយបុត្រធីតាឬយ៉ាងណា ? សង្គ្រាមជាការភ័យខ្លាចណាស់ និងពុំមែនជាសុភមង្គលក្នុងគ្រួសារនោះឡើយ។ (នៅមានត)

**លោក ផេង កែន**
**ប្រធានការិយាល័យរដ្ឋបាល**
**មន្ទីរអ.យ.កខេត្តកំពង់ឆ្នាំង**




# អភិវឌ្ឍចំណេះដឹង និងបំណិន(តចប់)

**ង. ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន**(Using of Information Technology)

ទៅព្រមជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យា គំនិតថ្មីៗកើតឡើងរៀងរាល់ថ្ងៃតាមរយៈព័ត៌មានអេឡិចត្រូនិច។ អ្នកដឹកនាំខ្លាំងពូកែត្រូវចេះវិធីប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីមានឱកាសចាប់យកជាអចិន្ត្រៃយ៍នូវគំនិតថ្មីៗ ។

**២.២. បំណិនទំនាក់ទំនងអន្តរបុគ្គល** (Interpersonal Skills):

បានលើកឡើងក្នុងនិយមន័យនៃភាពជាអ្នកដឹកនាំរួចមកហើយថា ភាពជាអ្នកដឹកនាំនៃការបណ្តុះបណ្តាលនិងជំរុញមនុស្សឱ្យប្រឹងប្រែងធ្វើការកាន់តែប្រសើរឡើង ... ។ ការធ្វើការជាមួយមនុស្សបណ្តុះគេ ទាមទារនូវបំណិនដោយឡែកមួយចំនួនដែលយើងឱ្យឈ្មោះថា បំណិនទំនាក់ទំនងអន្តរបុគ្គល (Interpersonal skills)។ បំណិនទំនាក់ទំនង(Communication skills)បំណិនបណ្តុះបណ្តាលគំនិតអ្នកដទៃ(Inspiring others skills)បំណិនកសាងទំនុកចិត្ត(Building trust skills)បំណិនបណ្តុះបណ្តាលសក្តានុពលរបស់អ្នកដទៃ (Developing others′ potential skills) និងបំណិនសហការ(Collaboration skills)។

**ក. ការប្រាស្រ័យទាក់ទង** (Communication):

អ្នកដឹកនាំសាលាដែលល្អគឺ ដឹកនាំសាលាដោយបើកចំហ ឥតលាក់លៀម ។ គាត់មានការផ្លាស់ប្តូរព័ត៌មានជាទៀងទាត់ជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ។ គ្រប់អ្នកពាក់ព័ន្ធត្រូវបានអញ្ជើញឱ្យចូលរួមពិភាក្សាដោះស្រាយគ្រប់បញ្ហារបស់សាលាដោយបើកចំហ ។ ប្រការនេះបានធ្វើឱ្យគ្រប់អ្នកពាក់ព័ន្ធទាំងអស់មានអារម្មណ៍ថា ខ្លួនជាផ្នែកមួយរបស់សាលារៀនហើយមានការជំរុញទឹកចិត្តឱ្យកាន់តែមានការប្រឹងប្រែងធ្វើការ។ ប៉ុន្តែការផ្តល់គ្រប់ព័ត៌មានជូនគ្រប់អ្នកពាក់ព័ន្ធទាំងអស់ជាការងារមួយពិបាក ។ ក្នុងសាលារៀន ព័ត៌មានសំខាន់សម្រាប់សាលារៀន ដូចឈាមដែលសំខាន់សម្រាប់ខ្លួនមនុស្ស ដែរ។ ក្នុងខ្លួនមនុស្សឈាមហូរទៅចិញ្ចឹមគ្រប់ផ្នែកនៃរាងកាយតាមរយៈសរសៃឈាម ដោយឡែកចំពោះក្នុងសាលារៀនវិញគ្រប់ព័ត៌មានត្រូវហូរទៅគ្រប់ទីកន្លែងតាមរយៈខ្សែបណ្តោយមួយហៅថា ការប្រាស្រ័យទាក់ទង (Communication) ។ នាយកសាលាត្រូវធានាឱ្យប្រាកដថា បណ្តាញព័ត៌មានត្រូវបានបើកចំហជានិច្ចទៅគ្រប់ទិស ។

ការប្រាស្រ័យទាក់ទងអាចប្រព្រឹត្តិទៅតាមវិធីច្រើនបែប។ ជាធម្មតា នាយកសាលាធ្វើការប្រាស្រ័យទាក់ទងតាមរយៈការប្រជុំ ។ ការប្រជុំមានច្រើនបែបដូចជា ការប្រជុំទូទៅ ការប្រជុំបុគ្គលិកក្នុងសាលា ការប្រជុំក្រុមបច្ចេកទេស និងការជួបនិយាយគ្នាតតួ (ផ្ទាល់ជាមួយបុគ្គលិកម្នាក់)។ ការនិយាយគ្នាតតួមានគុណប្រយោជន៍ក្នុងការកសាងទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធ កសាងទំនុកចិត្ត ជួយឱ្យបានទទួលនូវព័ត៌មានត្រឡប់ទាន់ពេល និងបង្កើតបរិយាកាសជជែកគ្នា ។ នាយកសាលាមួយចំនួន ប្រើក្តារខៀនព័ត៌មាន សម្រាប់ផ្តល់ព័ត៌មាន ។ នេះជាវិធីមូលដ្ឋានសម្រាប់ផ្តល់ព័ត៌មាន។ បច្ចុប្បន្ន

នេះ មាននាយកសាលាជាច្រើនប្រើទូរស័ព្ទក្នុងការប្រាស្រ័យទាក់ទង ហើយនៅទីក្រុង នាយកសាលាខ្លះបានឈានដល់ប្រើសារអេឡិចត្រូនិច ។

វិធីប្រាស្រ័យទាក់ទងផ្សេងៗ ដែលបានលើកឡើងខាងលើទាមទារឱ្យនាយកសាលាមានសមត្ថភាពគ្រឹះមួយចំនួនដូចជា សមត្ថភាពស្តាប់ សមត្ថភាពនិយាយ និងសមត្ថភាពសរសេរ ។ ទោះបីគាត់មានគ្រប់សមត្ថភាពទាំងអស់នេះហើយក្តី ការប្រាស្រ័យទាក់ទងក៏នៅតែមិនទាន់មានប្រសិទ្ធភាព ប្រសិនបើគាត់រក្សាខ្លួនឱ្យគេពិបាកជួប ស្ថិតនៅតែក្នុងការិយាល័យបិទជិត ។ ការប្រាស្រ័យទាក់ទងក៏មានន័យផងដែរថាមានវត្តមានបង្ហាញមុខគ្រប់ពេលក្នុងសាលា និងធ្វើខ្លួនឱ្យងាយស្រួលទាក់ទង ។ និយាយដល់សមត្ថភាពស្តាប់ នាយកសាលាគប្បីយល់ថា ទន្ទឹមនឹងផ្តល់ព័ត៌មានជូនគ្រប់អ្នកពាក់ព័ន្ធនោះ ដើម្បីដឹកនាំសាលាឱ្យបានប្រកបដោយប្រសិទ្ធភាព នាយកសាលាក៏ត្រូវការមកវិញនូវព័ត៌មាននានាទាក់ទងនឹងសាលារបស់ខ្លួនដែរ ។ ព័ត៌មានទាំងនោះត្រូវតែស្មោះត្រង់និងត្រឹមត្រូវ ។ វិធីដ៏ល្អបំផុតដើម្បីបានទទួលនូវព័ត៌មានពីបុគ្គលិក មាតាបិតាសិស្ស និងសិស្សនោះគឺ ស្តាប់ពួកគេនិយាយ ។ អ្នកដឹកនាំល្អជាអ្នកដែលពូកែស្តាប់ ។ នាយកល្អស្តាប់យ៉ាងយកចិត្តទុកដាក់នូវបុគ្គលិករបស់ខ្លួន មាតាបិតាសិស្ស និងសិស្សរបស់ខ្លួន ។ ស្តាប់គឺទទួលនូវព័ត៌មានត្រឡប់ពីអ្នកដទៃ ។ ព័ត៌មានត្រឡប់អាចវិជ្ជមាន និងអវិជ្ជមាន ។ ចូរកុំខ្លាចនូវព័ត៌មានអវិជ្ជមាន ។ សូមទុកព័ត៌មានត្រឡប់ទាំងអស់ជាឱកាសសម្រាប់រៀន ។ ការបង្កើតនូវប្រអប់សំបុត្រក៏ជាវិធីមួយទៀតសម្រាប់ទទួលនូវព័ត៌មានដែរ ។ ដោយបង្កើតប្រអប់សំបុត្រនៅក្នុងសាលានិងអានទៀងទាត់នូវខ្លឹមសារសំបុត្រទាំងនោះ នាយកសាលានឹងបានទទួលនូវព័ត៌មានបន្ថែមទៀតទាក់ទងដល់សកម្មភាពរបស់ខ្លួនក៏ដូចជាអ្វីៗ ដែលកើតឡើងនៅសាលារៀន។ប្រការនេះអាចជួយគាត់ឱ្យដោះស្រាយបញ្ហាបានទាន់ពេល និងប្រកបដោយប្រសិទ្ធភាព ។

**ខ. បណ្តុះគំនិតអ្នកដទៃ** (Inspiring others)

គឺសមត្ថភាពបណ្តុះគំនិតអ្នកដទៃដែលធ្វើឱ្យអ្នកដឹកនាំខុសពីអ្នកគ្រប់គ្រង។ បណ្តុះគំនិតអ្នកដទៃមានន័យថាជួយអ្នកទាំងនោះឱ្យមានអារម្មណ៍ថា គេមានលទ្ធភាពអាចបំពេញកិច្ចការណាក៏បាន ។ ឧទាហរណ៍ យើងអាចបណ្តុះនូវគំនិតស្មោះត្រង់ ទុកចិត្ត ខិតខំ ។ល។ ប្រការគួរឱ្យស្តាយគឺនាយកសាលាជាច្រើនមើលទៅមន្ត្រីរបស់ខ្លួន ក្នុងក្រសែភ្នែកអវិជ្ជមាន ។ យើងតែងឮគាត់ពោលមិនល្អពីបុគ្គលិករបស់គាត់ ដូចជាថា « គ្រូនេះខ្ជិល គ្រូនោះគ្មានគំនិតច្នៃប្រឌិត គ្រូម្នាក់ទៀតល្ងង់ទាមទារឱ្យប្រាប់គ្រប់កិច្ចការ » ។ យើងកម្រឮគាត់ពោលពាក្យវិជ្ជមានពីមន្ត្រីរបស់គាត់ ឬពីប្រការដែលគាត់បានជួយទ្រទ្រង់មន្ត្រីរបស់គាត់ណាស់។ នាយកសាលាត្រូវជឿជាក់ថា មនុស្សទាំងអស់មានលទ្ធភាពរីកចម្រើនបានប្រសិនបើគេបានទទួលនូវការជួយទ្រទ្រង់គ្រប់គ្រាន់ ហើយវិធីដែលល្អបំផុតក្នុងការជួយមនុស្សឱ្យរីកចម្រើន គឺការបណ្តុះគំនិតគេដោយសេចក្តីស្មោះត្រង់ ការជួយទ្រទ្រង់ និងការជឿជាក់លើសមត្ថភាពរបស់គេ។

ការបណ្តុះគំនិតមនុស្សអាចធ្វើដោយបង្ហាញនូវគំរូដល់គេ ។ យើងអាចបណ្តុះគំនិតស្មោះត្រង់ដោយបង្ហាញនូវគំរូស្មោះត្រង់ ។ ប្រសិនបើយើងចង់ឱ្យមនុស្សចេះទទួលខុសត្រូវ យើងត្រូវបង្ហាញនូវការទទួលខុសត្រូវរបស់យើង ហើយចែករំលែកនូវការទទួលខុសត្រូវជាមួយពួកគេ ។ ដោយបង្ហាញនូវទំនុកចិត្តចំពោះពួកគេ មនុស្សទាំងនោះនឹងមានទំនុកចិត្តលើខ្លួនឯង និងលើអ្នកដទៃទៀត។

នាយកសាលាក៏គប្បីរៀបចំផងដែរឱ្យមានការប្រជុំជាទៀងទាត់ ដើម្បីបង្ហាញនូវវឌ្ឍនភាព ។ ការប្រជុំអាចផ្តោតលើការបង្ហាញនូវលទ្ធផលនៃការខំប្រឹងប្រែង និងជោគជ័យរបស់គេ ។ ត្រូវលើកទឹកចិត្តគេឱ្យខំប្រឹងប្រែងថែមទៀត ប៉ុន្តែត្រូវចៀសវាងកុំស្តីបន្ទោសពួកគេ ។

**គ. កសាងទំនុកចិត្តចំពោះអ្នកដទៃ** (Building trust with others):

យើងបានកំណត់និយមន័យនៃភាពជាអ្នកដឹកនាំថា ***ភាពជាអ្នកដឹកនាំជាការបណ្តុះនិងជំរុញមនុស្សឱ្យប្រឹងប្រែងធ្វើការកាន់តែប្រសើរឡើង...ដើម្បីឱ្យកុមារទាំងអស់រៀនបានប្រកបដោយជោគជ័យ*** ។ ការងារនេះអាចធ្វើឱ្យសម្រេចបានលុះត្រាតែបរិយាកាស**ទុកចិត្តគ្នា** ត្រូវបានកសាងឡើង ។ នាយកសាលាត្រូវតែបានទទួលនូវទំនុកចិត្តពីមនុស្សទាំងអស់ក្នុងសហគមន៍ សាលារៀន ។ ក្នុងសាលារៀនមួយដែលមនុស្សទាំងអស់មានទំនុកចិត្តមកលើនាយករបស់ខ្លួននោះ ជានិច្ច

កាលពួកគេនឹងមានទំនុកចិត្តខ្ពស់រវាងគ្នានឹងគ្នា។ ការកសាងទំនុកចិត្តក្នុងសាលារៀន ជាភារកិច្ចសារវន្តសម្រាប់នាយកសាលា ។

ដើម្បីបានទទួលនូវទំនុកចិត្តពីមន្ត្រីរបស់ខ្លួន នាយកសាលាត្រូវតែមានទំនុកចិត្តលើខ្លួនឯង ។ ជាការសំខាន់ណាស់ ដែលនាយកសាលាត្រូវបង្ហាញថា ខ្លួនមានសមត្ថភាពនឹងដោះស្រាយបញ្ហាដែលកើតក្នុងសាលាដោយខ្លួនឯងមិនមែនរង់ចាំតែការណែនាំពីថ្នាក់លើរហូតនោះទេ ។ នាយកសាលាក៏ត្រូវបង្ហាញផងដែរថាខ្លួនមានឆន្ទៈ និងមានសមត្ថភាពអាចជួយទ្រទ្រង់គេនៅរាល់ពេលដែលគេត្រូវការ។ លើសពីនេះទៅទៀតនាយកសាលាត្រូវតែបង្ហាញនូវភាពស្មោះត្រង់ជាមួយពួកគេផងដែរ ។ ត្រូវតែរក្សានូវពាក្យសម្ដីរបស់ខ្លួន និងត្រឹមត្រូវជាមួយពួកគេ ។ ការប្រកាន់នូវឥរិយាបថបែបនេះជាមួយមន្ត្រីរបស់ខ្លួន អាចឱ្យមន្ត្រីទាំងនោះមានអារម្មណ៍ទុកចិត្តមកលើនាយករបស់ខ្លួន គិតថាអាចពឹងពាក់គាត់បាន ហើយអារម្មណ៍ទុកចិត្តគ្នាក៏ត្រូវបានកសាង ។

ដើម្បីកសាងនូវបរិយាកាសទុកចិត្តក្នុងសាលារៀន នាយកសាលាមិនត្រឹមតែខំធ្វើការដើម្បីបានទទួលនូវទំនុកចិត្តពីមន្ត្រីរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែខ្លួនគេផ្ទាល់ក៏ត្រូវមានទំនុកចិត្តលើមន្ត្រីទាំងនោះដែរ ។ គាត់ត្រូវមានការជឿជាក់ថា មន្ត្រីរបស់គាត់មានសមត្ថភាព អាចធ្វើអ្វីៗបានទាំងអស់ ហើយប្រព្រឹត្តទៅលើពួកគេ ប្រកបដោយភាពត្រឹមត្រូវ។ សូមចងចាំថាមានទំនុកចិត្តលើមនុស្ស អាចជួយឱ្យមនុស្សមានអារម្មណ៍ទុកចិត្តលើខ្លួនឯង ។ ទំនុកចិត្តអាចដឹកនាំគេឱ្យទុកចិត្តអ្នកដទៃទៀត ហើយបន្ទាប់ពីនោះបរិយាកាសទុកចិត្តគ្នាក៏ត្រូវបានកសាងឡើង។

ប៉ុន្តែដោយហេតុថា មនុស្សទាំងអស់មិនដូចគ្នានោះ វាជាកាលំបាកក្នុងការទុកចិត្តមនុស្សគ្រប់រូបនិងប្រព្រឹត្តិមកលើពួកគេដោយស្មើភាព ។ ទាំងអស់គ្នាមិនមានកម្រិតយល់ដឹងស្មើៗគ្នាទេ ។ដូចនេះវិធីដែលល្អគឺ មើលទៅពួកគេក្នុងផ្លូវវិជ្ជមាន។ត្រូវមានការជឿជាក់ថា ម្នាក់ៗសុទ្ធតែមានការរីកចម្រើនបាន ហើយផ្ដល់ជូននូវការជួយទ្រទ្រង់សមស្របជូនមន្ត្រីដែលមានការយឺតយ៉ាវជាងគេ ។ ត្រូវគិតជានិច្ចថា **ទាំងអស់គ្នាសុទ្ធតែជាផ្នែកមួយនៃសហគមន៍សាលារៀនរបស់យើង** ។ យើងមិនអាចបោះបង់ចោលអ្នកណាម្នាក់ទេ ។

**ឃ. បណ្ដុះបណ្ដាលនូវសក្ដានុពលរបស់អ្នកដទៃ** (Developing others people potential):

មនុស្សម្នាក់ៗសុទ្ធតែមាននូវសក្ដានុពលដោយឡែករៀងៗខ្លួន ។ សក្ដានុពលដែលមិនត្រូវបានបណ្ដុះបណ្ដាលប្រៀបដូចនឹងដីមួយដុំដែលមិនត្រូវបានដាំដំណាំ ។ នាយកសាលាត្រូវតែរកមធ្យោបាយជួយគ្រូ សិស្ស និងគ្រួសារសិស្សឱ្យយល់នូវសក្ដានុពលរបស់ខ្លួន ។ វិធីមួយដើម្បីបណ្ដុះបណ្ដាលសក្ដានុពលមន្ត្រីរបស់ខ្លួនគឺ ចំណាយពេលនិយាយជាមួយគេ ។ វាអាចជាការប្រជុំក្នុងក្រុម ការជួយជាបុគ្គលម្នាក់ៗផ្ទាល់ ឬការប្រជុំវាយតម្លៃ ។ ក្រោយការប្រជុំត្រូវតែមានការធ្វើព័ត៌មានត្រឡប់ ហើយព័ត៌មានត្រឡប់ ត្រូវតែស្មោះត្រង់ និងស្ថាបនា។ រាល់កំណែលម្អត្រូវតែមានតុល្យភាពជាមួយការវាយតម្លៃវិជ្ជមាន ។ ការបង្វឹក(coaching) ក៏ជាមធ្យោបាយមួយជួយមនុស្សឱ្យអភិវឌ្ឍនូវសក្ដានុពលរបស់គេដែរ ។ម្យ៉ាងទៀតការចែករំលែកនូវបទពិសោធន៍ និងជំនាញរបស់ខ្លួនជាមួយមន្ត្រីក៏ជួយឱ្យនាយកសាលាអាចបង្កើតនូវសមត្ថភាពនិងបំណិនផ្ទាល់ខ្លួនផងដែរ ។

វិធីដែលល្អមួយទៀតគឺការរៀនដោយសង្កេតអ្នកដទៃ ។ នាយកសាលាគប្បីបង្កើនឱកាសឱ្យមន្ត្រីរបស់ខ្លួនមានឱកាសរៀនពីគ្នាទៅវិញទៅមក។ គាត់អាចចាត់ចែងឱ្យពួកគេធ្វើជាដៃគូ ឬអាចឱ្យមន្ត្រីដែលមានបទពិសោធជាអ្នកណែនាំ(mentor) មន្ត្រីដទៃទៀត ឬលើកទឹកចិត្តគ្រូឱ្យសង្កេតការបង្រៀនគ្នាទៅវិញទៅមក ។

**លោក អ៊ុំ សារីក់**

✍📖✍

# វេយ្យាករណ៍

## របៀបប្រើពាក្យ(ត)

### របៀបប្រើពាក្យឫ (រឹ)ឬ (រឺ)

ឫ ស្រះ សំស្ក្រឹតជារស្សៈ (រឹ) ជាមុទ្ធជ : មានសំឡេងកើតក្នុងក្បាល(ដូច រ ដែរ)។

ក្នុងភាសាខ្មែរ ពាក្យដែលគេសរសេរ ជាមួយ ឫ (រឹ) មានប្រើតែ ៦ម៉ាត់ គឺពាក្យ ឫក, ឫក្ស, ឫកពា, ឫសដី, ឫសដូង, ឫស្សី ។ ក្រៅពីនេះឫមានប្រើនៅក្នុងពាក្យសំស្ក្រឹតដូចពាក្យដែលប្រើក្នុងឃ្លាខាងក្រោមនេះ ៖

ហោរសង្កេតរក ឫក្ស ថ្ងៃ ខែ ឆ្នាំ ។ ថ្ងៃនេះ ជាថ្ងៃជា ត្រូវឫកពាដ៏ល្អអនេក ។

មានព្រះមហាឫសី១រូបមានឫទ្ធានុភាពដ៏ខ្លាំងពូកែគង់នៅតែក្នុងព្រៃ ។

ចំណែកពាក្យ ឬ (រឺ) មានតែមួយពាក្យទេ ។ ឧទាហរណ៍ៈ ទៅឬទេ ?

### របៀបប្រើពាក្យ និង នឹង ហ្នឹង

-និងនិ. (បារ. et)សម្រាប់និយាយតពាក្យឬតឃ្លាបេះពីមួយទៅមួយដែលមានសេចក្ដីដំណើរថាទាំង, ព្រមទាំង, ផង, នេះផង, នុះផង: អ្នកនិងខ្ញុំ, គោនិងក្របី, ផ្ទះនេះផ្ទះនុះ+និងផ្ទះឯណោះ, សុខនិងទុក្ខ, ទៅនិងមិនទៅ, ឱ្យនិងមិនឱ្យ, យកចាននិងផ្ដិលមកផង ។ ល។

- **នឹង** គេប្រើបានច្រើនយ៉ាងក្នុងប្រយោគទូទៅ ដូចជា ៖

**១. នឹង** កិ.នុ. ពាក្យជាកិរិយានុគ្រោះសម្រាប់និយាយនាំមុខកិរិយាសព្ទ ប្រាប់អនាគតកាលទៅខាងមុខថា មុខជា, ប្រាកដជា, គង់, គង់តែ : ស្អែកនឹងទៅផ្ទះអ្នក, យើងគង់តែនឹងបានជួបគ្នាទៀតក្នុងថ្ងៃណាមួយពុំខាន ។

**២. នឹង** គុ. ឬ កិ.វិ. ស្ងៀម, ដើយ, មិនកម្រើក : អង្គុយនឹងថ្កល់ គឺអង្គុយដូចគេថ្កល់។ មិនប្រែលប្រួល, មិនឡើងមិនចុះ, នៅដូចដែល : ជំងឺនុះ+នៅនឹង ។ ទឹកនឹង គឺទឹកដែលមិនឡើង មិនស្រក ឬមិនហូរ ។

**៣. នឹង** អា.និ. ពាក្យប្រាប់ដំណើរសម្រេចនូវអំពើ, សម្រាប់ប្រើនិយាយនាំមុខនាមសព្ទ មានន័យថា ដោយ, ជាមួយ, ដោយសារ; ឰដ៏, នៅត្រង់ : ដួសសម្លនឹងវែក, ដាំបាយនឹងឆ្នាំង, កាប់ឈើនឹងប៉ូវថៅ គឺដួសសម្លដោយវែក, ដាំបាយដោយឆ្នាំង, កាប់ឈើដោយប៉ូវថៅ; ទៅនឹងខ្ញុំ, នៅនឹងគេ, ដេកនឹងគេ, ស៊ីនឹងគេ, គឺទៅជាមួយនឹងខ្ញុំ, នៅជាមួយនឹងគេ, ដេកដោយសារគេ, ស៊ីដោយសារគេ; ព្យួរអាវនឹងដៃកែវ, បោះដែកគោលនឹងជញ្ជាំង គឺព្យួរអាវឰដ៏ដៃកែវ, បោះដែកគោលនៅត្រង់ជញ្ជាំង ។ ល ។

**៤. នឹង** អា.និ. គឺកម្មវេងបន្ទាប់ពីអា.និ. ដែលនិយាយថា នូវ គឺនូវជាទី១ នឹងជាទី២ ដើម្បីកុំឱ្យថានូវទាំង ២ដង : ពីម្សិលមិញគេបាននិយាយនូវពាក្យនេះនឹងខ្ញុំថា... (ពីម្សិលមិញ គេបាននិយាយនឹងខ្ញុំថា ...)

**ហ្នឹង** វិ.ស. នុះ : ហ្នឹងហើយ នុះហើយ; ហ្នឹងឯង នុះឯង ដំណើរហ្នឹង ដំណើរនុះ ។ និ. (ព.សា.) ដូច្នឹង; អ៊ីចឹង, អើ (អ្នកម្នាក់ប្រាប់ថា) : ទៅកុំខានហ្ន៎ះ ! (អ្នកម្នាក់ឆ្លើយតបថា) ហ្នឹង ! ។ ហ្នឹងហើយ ! អ៊ីចឹងហើយ ! ។ ហ្នឹងឯង អ៊ីចឹងឯង ! ។ បើនិយាយមានសម្លេងខ្ពស់ស្រួចខ្លាំង ត្រូវសរសេរដាក់ជើងក្អែក (+) នេះពីលើជា ហ្នឹងហើយ! ហ្នឹងឯង ! (សម្រាប់សម្ដីសាមញ្ញ) ។

### របៀបប្រើពាក្យ អ្នក - នាក់

១. អ្នក (អ.ថ. នាក់) ជានាមស័ព្ទ កាលណាប្រើរៀងខាងដើមនាមស័ព្ទ គុណស័ព្ទ និងកិរិយាស័ព្ទ ។

ក- **អ្នក** ប្រើរៀងខាងដើមនាមស័ព្ទ ៖ អ្នកកីឡា អ្នកក្រុង អ្នកជំនួញ អ្នកចំការ អ្នកស្រែ អ្នកផ្សារ អ្នកភូមិ អ្នកស្រុក ... ។

ខ- **អ្នក** ប្រើរៀងខាងដើមគុណស័ព្ទ ៖ អ្នកធំ អ្នកតូច អ្នករុង អ្នកថ្នារ អ្នកខ្ពស់ អ្នកទាប អ្នកខ្លះ អ្នកណា ...។

គ- **អ្នក** ប្រើរៀងខាងដើមកិរិយាស័ព្ទ ៖ អ្នកសរសេរ អ្នកធ្វើការ អ្នកឡើងត្នោត អ្នកលេង អ្នករក អ្នករៀន...។

២. **អ្នក** ជានាមស័ព្ទ ប្រើជំនួស ឬ ខាងដើមឈ្មោះជនដែលគេនិយាយទៅរកក្នុងទីចំពោះមុខ ៖ អ្នកអញ្ជើញទៅណាហ្នឹង ? អ្នកសុខអញ្ជើញមកពីផ្សារវិញហើយឬនៅ ?

៣. ដទៃពីនេះគេប្រើពាក្យ**នាក់** សម្រាប់រៀងខាងចុងសំខ្យាគុណស័ព្ទ និងអនិយមគុណស័ព្ទសម្រាប់មនុស្ស ៖ មានអ្នកនិពន្ធប៉ុន្មាននាក់ ? មានអ្នកសរសេរ៣នាក់ ។

## របៀបប្រើពាក្យ ពិបាក និង លំបាក

ពាក្យ **ពិបាក**ក្លាយមកពីពាក្យបាលីថា**វិបាក** ដោយគ្រាន់តែផ្លាស់ **វ** ជា **ព** ប៉ុណ្ណោះ ។ ពាក្យថា**វិបាក**មានន័យថា ផល គឺផលបាប ផលកម្ម ។ យើងប្រើពាក្យ**ពិបាក**នេះជាគុណស័ព្ទ ដូចជាការពិបាក , ក្នុងការឡើងកំពូលភ្នំខ្ពស់ៗ ពិបាកនឹងធ្វើដំណើរណាស់ ព្រោះមិនមានផ្លូវល្អដែលនឹងអាចទៅបាន , ដែលធ្វើបានដោយកម្រ ។

ពាក្យថា **លំបាក**( តាម វ.ច. ខ.លោកថា ពាក្យសៀម និងលាវ ) មានន័យដូចគ្នានឹងពាក្យថា ពិបាកដែរ។

ឧ. - ផ្លូវលំបាកដើរ ព្រោះមានថ្មដុំធំៗ រដិបរដុបច្រើន ។

-គេថា ក្រប្រាក់ លំបាកកាយ សប្បាយចិត្តត្បិតមានលុយចាយ មានបាយស៊ី។

## របៀបប្រើពាក្យ ប្រសិនជា- ប្រសិនណាបើ -ប្រសិនបើ

ពាក្យទាំងប៉ុន្មានម៉ាត់នេះ គឺជានិបាតសព្ទ សម្រាប់ប្រើក្នុងការនិយាយដោយស្មានថា « បើ- បើជា » ច្រើនរៀននៅខាងដើមឃ្លា ឬប្រយោគណាដោយស្មាន ។

ឧ. ប្រសិនជា កុំបាច់ទៅតើបានឬទេ ?

- ប្រសិនណាបើ កុំអាលប្រញាប់ឱ្យប្រាក់មុនមិនជាអ្វីសោះ ? ។

- ប្រសិនបើ ខ្ញុំឱ្យនៅចាំផ្ទះពុំបានឬ ? ។

តែពាក្យទាំងប៉ុន្មាននេះ បើពុំបានជាគិតនោះ ច្រើនតែភាន់ច្រឡំប្រើខុសស្រឡះ ប៉ះទៅលើពាក្យដែលគ្មាន ហើយខុសទៅវិញ ។

ឧ. បើប្រសិនណា ជាសត្វលោកទាំងអស់មានអហេសាដូចគ្នា ក្នុងសកលលោកសមនឹងបរិបូណ៌ដោយសេចក្ដីសុខសាន្តយ៉ាងក្រៃលែង ។

ឧ. បើសិនណាជា អាឆ្លកសេះអ្នកមានល្បឿនស្មើគ្នានឹងអាខ្មៅសេះខ្ញុំនោះ ខ្ញុំនឹងទិញអ្នកបានឬទេ ?

ឧ. បើសិនជា ខ្ញុំបានដឹងរឿងនេះតាំងពីដំបូងមក មិនបានជាឆ្លោយដល់ប៉ុណ្ណោះសោះ ។

**កំណត់សម្គាល់ ៖** ពាក្យបើប្រសិនណា បើសិនណា បើសិន គ្មានប្រើទេ ។ រីឯពាក្យដែលត្រូវប្រើឱ្យបានត្រឹមត្រូវតាមក្បួនខ្នាតវេយ្យាករណ៍ ដែលលោកអ្នកប្រាជ្ញបានតែងតាំងទុកមកហើយនោះគឺពាក្យ ប្រសិនបើជា - ប្រសិនណាបើ ប្រសិនបើ ។

( នៅមានត )

**លោកចែម ផាន**

# សាលារៀនជាមជ្ឈដ្ឋានផ្សាយនូវវិជ្ជាទូទៅ( តចប់ )

★ចំណុចសំខាន់គឺ គ្រូមិនត្រូវបោះបង់ចោលនូវពពួកមនុស្សពេញវ័យទេ ។

សេចក្តីថ្លៃថ្នូរ ថ្កុំថ្កើងរុងរឿងនិងពេញចិត្ត កាត់ថ្លៃមិនបាននៃសាលារៀន គឺត្រង់កាលឃើញទីភូមិដែលសាលារៀនតាំងឋិតនៅក្នុងម៉ាគា នៃការរីកចម្រើនក្រោមការជួយចូលរួមសកម្មភាពនានានៃសាលារៀន។

បញ្ហាដែលគ្រូយើងចងចាំនោះគឺ កុមារមកសាលាដើម្បីរៀន ក៏ប៉ុន្តែក្នុងតួនាទីជាគ្រូបង្រៀន យើងក៏ត្រូវរៀនផងដែរ។ យើងរៀនអ្វីដែលថ្មីនៅជុំវិញខ្លួនយើងដើម្បីបង្រៀនសិស្ស ។ យើងរៀនដើម្បីបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាព និងឱ្យសិស្សកាន់តែចូលចិត្ត ។ ដូច្នេះសិស្សទាំងអស់នឹងរៀនអំពីរៀនអាន និងគណិតវិទ្យា ហើយយើងជាគ្រូក៏រៀនអ្វីដែលថ្មីពីសិស្សរបស់យើងដែរ ។ គ្រូនឹងរកឃើញវិធីជម្នះរាល់ការលំបាកនេះ ហើយរៀបចំតំរិយាបថវិជ្ជមានចំពោះកុមារ និងក្នុងស្ថានភាពលំបាក ។ ការបង្រៀននឹងក្លាយទៅជាការសប្បាយរីករាយ មិនមែនជាការងារតឹងរ៉ឹងនិងការងារលំបាកនោះទេ ។

ករណីយកិច្ចរបស់អ្នកអប់រំ ចេញមកពីបេសកកម្មរបស់ខ្លួន។ គ្រូត្រូវតែមានចំណេះវិជ្ជាទូលំទូលាយសម្រាប់បម្រើបេសកកម្មនោះ ហើយត្រូវមានឆន្ទៈដ៏រឹងប៉ឹងសម្រាប់បម្រើឧត្តមគតិដ៏ខ្ពង់ខ្ពស់នេះ ។ អ្នកអប់រំម្នាក់ៗដើម្បីធ្វើខ្លួនឱ្យទៅជា **«ជង្រុក »** នៃចំណេះវិជ្ជាទូទៅនិងចំណេះវិជ្ជាខាងមុខវិជ្ជាជីវៈ ត្រូវមានករណីយកិច្ចសិក្សាដោយខ្លួនឯងឱ្យបានហ្មត់ចត់ ៖ គឺសេចក្តីស្មោះត្រង់ និងសេចក្តីយុត្តិធម៌តម្រូវឱ្យធ្វើយ៉ាងដូច្នេះ ។ **កាលណាគេឈប់សិក្សា គេក៏ត្រូវឈប់បង្រៀនដែរ។** ចំពោះអ្នកអប់រំ ក្នុងចំណោមមុខវិជ្ជាទាំងអស់ ត្រូវចាត់ទុកចំណេះវិជ្ជាខាងផ្នែកគរុកោសល្យ ជាចំណេះវិជ្ជាទី ១ ។

ក៏ប៉ុន្តែសូមបញ្ជាក់ថា ការរៀនខ្លួនឯងសម្រាប់បម្រើបេសកកម្មនេះ មិនច្រឡំនឹងការរៀនកម្មវិធីសិក្សាសម្រាប់ប្រឡងយកសញ្ញាបត្រនោះទេ ។

បេសកកម្មនៃការអប់រំ គឺជាកាតព្វកិច្ចយ៉ាងធ្ងន់ធ្ងរ ហើយយ៉ាងតឹងរ៉ឹង គេមិនទាមទារឱ្យគ្រូម្នាក់ៗ ប្រកបទៅដោយគុណសម្បត្តិគ្រប់យ៉ាងដោយគ្មានគុណវិបត្តិនោះទេ ។ បានសេចក្តីថាគ្រូម្នាក់ៗរមែងមានលក្ខណៈទាំងពីរនេះ ក៏ប៉ុន្តែចំណុចសំខាន់មិនមែនឋិតនៅត្រង់គុណសម្បត្តិដែលបានមកនោះទេ គឺ ឋិតនៅត្រង់ការខិតខំប្រឹងប្រែងដោយក្លាហានហើយទៀងទាត់ក្នុងការសម្រេចគុណសម្បត្តិនេះ ។

គ្រូបង្រៀនទទួលផលប្រយោជន៍ដ៏សំខាន់ពីការងារបង្រៀនរបស់ខ្លួននឹងមានឱកាសកាន់តែច្រើនថែមទៀតដើម្បីស្វែងយល់អំពីគំនិតថ្មីៗតាមរយៈទំនាក់ទំនងជាមួយអ្នកដទៃ ទាំងក្នុងនិងក្រៅសាលា ដូចជាក្នុងសាលាកម្រង ឬ បណ្តាញគ្រូបង្រៀន ។ ដោយបានអនុវត្តនូវគំនិតថ្មីៗទាំងនេះ គ្រូបង្រៀននឹងចលនាសិស្សឱ្យសិស្សកាន់តែចូលចិត្តរៀនកាន់តែមានគំនិតច្នៃប្រឌិត និងយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ។ ហេតុដូច្នេះកុមារនិងមាតាបិតាអាចផ្តល់យោបល់កែលម្អដល់គ្រូបង្រៀនវិញ ហើយគ្រូបង្រៀននឹងទទួលបានការគាំទ្រពីសហគមន៍កាន់តែច្រើន ហើយនឹងទទួលបានរង្វាន់និងការលើកទឹកចិត្តដោយសារការងារល្អនេះ ។ សហគមន៍នឹងមានមោទនភាពដោយសារកុមារកាន់តែច្រើនបានចូលរៀននៅសាលា ។ សហគមន៍នឹងយល់ថា « **អ្នកដឹកនាំសហគមន៍ក្នុងពេលអនាគត»** កំពុងទទួលបានការអប់រំដើម្បីចូលរួមក្នុងសកម្មភាពសង្គមកាន់តែសកម្ម ។ សហគមន៍មើលឃើញថា បញ្ហាសង្គម ដូចជាឧក្រិដ្ឋកម្មតូចតាច ឬ បញ្ហាយុវវ័យនឹងកាត់បន្ថយបាន។ សមាជិកសហគមន៍ទាំងអស់នឹងចូលរួមកាន់តែសកម្មក្នុងសកម្មភាពរបស់សាលារៀន ហើយបង្កើតទំនាក់ទំនងកាន់តែល្អរវាងសាលា និងសហគមន៍ ។ យើងបានរកឃើញថា « **កុមារមានមនុស្សធម៌និងស្មោះត្រង់ជាមួយមនុស្សចាស់»** ។

**« សេចក្តីពេញចិត្តចំពោះខ្លួនឯង មិនត្រូវមាននូវក្នុងខ្លួន ពីព្រោះវាជាឧបសគ្គនៃភាពរីកចម្រើន »**

**លោក ចែម ផាន**

# គណិតវិទ្យា

## រកឃើញសំណួរត្រឹមត្រូវ

**វត្ថុបំណង**

- បកស្រាយព័ត៌មានផ្សេងៗ ។
- ភ្ជាប់សំណួរទៅនឹងព័ត៌មានជាក់លាក់ដែលទាក់ទងនឹងសំណួរនោះ។

### I. គោលបំណងរបស់សលាកប័ត្រ

- ជំរុញសិស្សឱ្យអានប្រធានចំណោទ និងសំណួរដោយប្រុងប្រយ័ត្ន។
- ឱ្យសិស្សស្វែងយល់អត្ថន័យប្រធានចំណោទ និងវាក្យស័ព្ទដោយឡែកដែលប្រើនៅក្នុងសំណួរ ។
-ឱ្យសិស្សជៀសវាងការធ្វើការងារដោយមិនបានត្រិះរិះ(automatismes) តាមរបៀប ៖ «បើគេសួរខ្ញុំឆ្លើយ »។

**ចំណោទ**

កប៉ាល់មួយផ្ទុកអង្ករ ២៥០០០០គក ។ គេច្រកអង្ករទៅក្នុងបាវ បាវនីមួយៗមានទម្ងន់ ៥០គក ។ គេលើកអង្ករដាក់ចូលទៅក្នុងកប៉ាល់ដោយរថយន្តស្ទូច ។ រថយន្តនេះស្ទូចអស់ក្នុងរយៈពេល ៣ម៉ ៣០ន ទើបរួចរាល់។

ក្នុងចំណោមសំណួរទាំងបីខាងក្រោម ចូររកសំណួរណាដែលទាក់ទងទៅនឹងប្រធានចំណោទ ។

□ក- តើរថយន្តនោះស្ទូចមួយលើកបានអង្ករប៉ុន្មានបាវ ?

□ខ- តើកប៉ាល់នោះផ្ទុកអង្ករបានប៉ុន្មានបាវ?

□គ- តើនៅវេលាម៉ោងប៉ុន្មានទើបគេស្ទូចអង្កររួច ?

### II. ការរៀបចំរបស់គ្រូ

- គ្រូត្រូវចម្លងចំណោទដាក់ក្ដារខៀនមុនម៉ោងបង្រៀន ឬសរសេរលើផ្ទាំងក្រដាសធំ បើមានលទ្ធភាព។

### III. លំនាំនៃការបង្រៀន

**ដំណាក់ទី១ : អំណាន និងការយល់អត្ថន័យនៃអត្ថបទ**

- ឱ្យសិស្សអានចំណោទ និងសំណួរទាំងបីដោយស្ងៀមស្ងាត់
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សអាន
-គ្រូសួរម្ដងមួយសំណួរៗ ៖

«តើចំណោទនេះគេនិយាយអំពីអ្វីខ្លះ ?»

«តើគេឱ្យអ្នកធ្វើអ្វីខ្លះ ?»(ជ្រើសរើសសំណួរត្រឹមត្រូវក្នុងចំណោមសំណួរទាំងបី)

«តើចំណោទនេះ មានសំណួរប៉ុន្មាន ?»

-ឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់ ចំពោះសំណួរនីមួយៗ ។
- ឱ្យសិស្សផ្ទៀងផ្ទាត់និងកែតម្រូវ ។

**សំណួមពរ**:ក្នុងចំណោមសំណួរទាំងបី ចូរជ្រើសរើសសំណួរមួយដែលគេអាចឆ្លើយបាន។ ពីព្រោះអ្វី ? តើវាខ្វះអ្វីខ្លះ?

**ដំណាក់ទី២ : ការស្រាវជ្រាវរបស់សិស្ស**

- ឱ្យសិស្សធ្វើការងារជាបុគ្គល ជាក្រុម ២នាក់ៗ ដោយសរសេរសៀវភៅព្រៀង។
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សដោះស្រាយ ។

- គ្រូដើរត្រួតពិនិត្យការងាររបស់សិស្ស ។

✷បើមានសិស្សមិនទាន់យល់ច្បាស់ពីសំណួរមពរ គ្រូត្រូវចោទជាសំណួរ « តើមានបម្រាប់ជាលេខដែលទាក់ទងទៅនឹងសំណួរទី១ ឬទេ ?»

- ឱ្យសិស្សដែលជួបការលំបាកឆ្លើយ ។
- គ្រូពន្យល់ និងបំពេញបន្ថែមចំណុចខ្វះខាត ។
- ឱ្យសិស្សបន្តការងារ ។

**<u>ដំណាក់ទី៣</u> :ការបូកសរុប**

- ឱ្យសិស្សឡើងមកបង្ហាញសំណួរដែលគេរកឃើញដោយធ្វើអំណះអំណាងបញ្ជាក់ ។
- ឱ្យសិស្សផ្ទួផ្ទងចម្លើយផ្ទៀងផ្ទាត់និងកែតម្រូវ ។

✷បើសិស្សណាមានចម្លើយផ្សេងៗទៀត គ្រូត្រូវឱ្យគេឡើងមកបង្ហាញចម្លើយទាំងនោះ និងធ្វើអំណះអំណាងបញ្ជាក់ផង។

- ឱ្យសិស្សត្រិះរិះពិចារណា និងប្រៀបធៀបចម្លើយទាំងអស់របស់គេ ដើម្បីរកសំណួរណាដែលត្រឹមត្រូវ ។
- ឱ្យសិស្សឡើងគូសខ្វែងក្នុង □នៅមុខសំណួរដែលរកឃើញនៅលើក្ដារខៀន ។
- គ្រូបំពេញបន្ថែមចំណុចខ្វះខាត ។
- ឱ្យសិស្សម្នាក់ឡើងមកបង្ហាញពីរបៀបដោះស្រាយចំណោទដោយគណនាផង ។
- ឱ្យសិស្សផ្ទៀងផ្ទាត់ផ្ទួផ្ទងរបៀបឆ្លើយ និងធ្វើកំណែ ។
- គ្រូ និងសិស្សធ្វើសំយោគ ។

**<u>ដំណាក់ទី៤</u>: សន្និដ្ឋាន**

- គ្រូបង្ហាញអត្ថបទ « គួរចងចាំ » ដោយរៀបរាប់ពន្យល់ រួចឱ្យសិស្សចម្លងអត្ថបទ « គួរចងចាំ » នេះ ។

**គួរចងចាំ** :

ជាទូទៅប្រធានចំណោទត្រូវបានបញ្ចប់ដោយសំណួរ ។

**លំហាត់ដែលមានប្រយោជន៍**

គឺលំហាត់ដែលនាំអ្នកឱ្យស្រមៃទៅរកសំណួរទាំងឡាយដែលគេអាចរកឃើញ នៅពេលដែលលំហាត់នោះគ្មានសំណួរ ។ នេះគឺជាមធ្យោបាយមួយសម្រាប់ត្រួតពិនិត្យលើការយល់អត្ថន័យនៃអត្ថបទ ។

IV-**ចម្លើយ**

**សំណួរ «ខ »**

ចំនួនបារអង្ករដែលកប៉ាល់នោះផ្ទុក

២៥០០០០ ÷ ៥០ = ៥០០០បាវ

V- **សម្គាល់**

ដើម្បីត្រួតពិនិត្យ និងវាយតម្លៃការយល់ដឹងរបស់សិស្ស គ្រូត្រូវដាក់ចំណោទទាំង៤ ខាងក្រោមនេះឱ្យសិស្សធ្វើនៅក្នុងថ្នាក់ និង នៅផ្ទះ ។

ចំពោះចំណោទទី ២ គ្រូត្រូវចម្លងតែតារាងសម្រាប់បំពេញតែប៉ុណ្ណោះ ប៉ុន្តែគេត្រូវរៀបចំចំណោទទាំងនេះនៅលើផ្ទាំងក្រដាសធំជាមុន ។

**ចំណោទ** :

១. កសិករម្នាក់លក់ដំឡូង ១៨ បាវ ដែលក្នុងមួយបាវមានទម្ងន់ ៥០គក ។ គាត់ទុក ២៥០គកសម្រាប់បរិភោគ និង ១៥០គកសម្រាប់ធ្វើពូជ ។

- ចូររកសំណួរណាដែលអ្នកអាចឆ្លើយបាន ។

ក- តើគាត់លក់បានប៉ុន្មាន ?

ខ- តើដំឡូងទាំងអស់មានទម្ងន់ប៉ុន្មានគីឡូក្រាម ?

គ- តើគាត់លក់អស់ប៉ុន្មានបាវ ។

- ចូរដោះស្រាយចំណោទ ។

២.អត្ថបទ និងសំណួរនៃចំណោទខាងក្រោមនេះត្រូវបានដាក់លាយឡំគ្នា ។

ចូរសាកល្បងរៀបអត្ថបទ និងសំណួរទាំងនោះទៅតាមលំដាប់លំដោយ ដោយយកតែលេខសំណួរមកបំពេញក្នុងតារាងខាងក្រោមឱ្យត្រូវនឹងអត្ថបទ ។

| | |
|---|---|
| **អត្ថបទទី ១ ៖**<br>កញ្ចប់កាហ្វេដែលថ្លៃ១.៣០០៛កាលពីអាទិត្យមុនឥឡូវនេះថ្លៃ ១.៤៥០៛ | **សំណួរទី១ ៖**<br>តើគាត់នៅសល់ប្រាក់ប៉ុន្មានរៀល ? |
| **អត្ថបទទី ២៖**<br>ខ្សែមួយដុំមានប្រវែង១០០ម ។ គេលក់លើកទីមួយ៤០ម និង លក់លើកទីពីរ ៣៨ម ។ | **សំណួរទី២ ៖**<br>តើគាត់ធ្វើដំណើរអស់រយៈពេលប៉ុន្មានម៉ោង ? |
| **អត្ថបទទី ៣ ៖**<br>ពីផ្ទះចាន់ធីទៅសាលារៀនមានចម្ងាយ១.២០០ម។មួយជំហានរបស់ចាន់ធីមានប្រវែង ០,៤ម ។ | **សំណួរទី ៣ ៖**<br>តើតម្លៃរបស់វាកើនឡើងប៉ុន្មាន ? |
| **អត្ថបទទី ៤ ៖**<br>អ្នកស្រីសុកមានប្រាក់៨៦.៥០០៛បានមកពីការលក់ក្រូច។ គាត់ទិញសម្ភារសិក្សាសម្រាប់កូនគាត់អស់ប្រាក់២.៣៥០០៛ និង ស្បែកជើងមួយគូដែលមានតម្លៃថោកជាងសម្ភារសិក្សា ៥.៥០០៛។ | **សំណួរទី ៤ ៖**<br>តើគាត់នៅសល់ខ្សែប្រវែងប៉ុន្មានម៉ែត? |
| **អត្ថបទទី ៥ ៖**<br>អ្នកបើកបររថយន្តម្នាក់ធ្វើដំណើរពីភ្នំពេញទៅតាកែវដែលមានចម្ងាយ ៧៧គម ។ គាត់បើកបរក្នុងល្បឿន ៧០គម/ម៉ | **សំណួរទី ៥ ៖**<br>តើវាដើរប៉ុន្មានជំហាន<br>ដើម្បីទៅដល់សាលារៀន? |

| អត្ថបទ | សំណួរ |
|---|---|
| ១ | |
| ២ | |
| ៣ | |
| ៤ | |
| ៥ | |

៣. ចូរអានអត្ថបទខាងក្រោម រួចតាក់តែងសំណួរឱ្យបានពីរ ដែលទាក់ទងទៅនឹងអត្ថបទនោះ ។
ពូសំជាអ្នកបើកបររថយន្តឈ្នួល ។ គាត់បើកបរក្នុង១ថ្ងៃជាមធ្យម១៥០គមសម្រាប់ការងាររបស់គាត់ ។ គាត់ធ្វើការ ៦ ថ្ងៃក្នុងមួយអាទិត្យ និង ៤៦ អាទិត្យក្នុងមួយឆ្នាំ ។

..............................................................................................................................

..............................................................................................................................

..............................................................................................................................

៤. ចូរអានអត្ថបទខាងក្រោម រួចតាក់តែងសំណួរឱ្យបានពីរដែលទាក់ទងទៅនឹងអត្ថបទនោះ។
មីងសារិន លក់ផលិតផលចំការរបស់គាត់បានប្រាក់១.៩៧០.០០០៛ ។ គាត់ទិញទូរទស្សន៍មួយថ្លៃ ៣៥០.០០០៛ អាគុយមួយដែលមានតម្លៃថោកជាងទូរទស្សន៍ ១៩៥.០០០៛ និងសំលៀកបំពាក់អស់ប្រាក់ ៨៥.០០០៛ ។

..............................................................................................................................

..............................................................................................................................

..............................................................................................................................

**ដកស្រង់ដោយលោកស្រី ម៉ិន សារ៉ន**

**អនុសារណោវាទ**
**ចំពោះយុវជនអ្នកនៅវត្ត**

ហៃពួកយុវជនអ្នកកំសត់
បើកុំបានវត្តជ្រកអាស្រ័យ
សមអ្នកនឹងឥតមានតម្លៃ
យប់ថ្ងៃហួសទៅឥតប្រយោជន៍ ។
គួរអ្នកកុំភ្លេចវត្តលំនៅ
ទោះអ្នកចេញទៅឆ្ងាយស្រឡោច
គួរដឹងគុណវត្តកុំបង្ខោច
ប្រយោជន៍និងផលផ្ដល់ពុំខាន ។
បើមានគេសួរពីកាលរៀន
ចំណេះរបៀនទាំងប៉ុន្មាន
អ្នកកុំនិយាយបង្វែងដាន
ត្រូវប្រាប់ថាបានចេះព្រោះវត្ត ។
កុំពោលបង្អួតពួកស្រីៗ
ត្រូវស្ដីតាមត្រង់កុំបំភ្លាត់
បំផ្លែងបំផ្លើសបំភ្លេចវត្ត
ក្រែងទោសទាញទាត់ឱ្យវិនាស ។
បាយវត្តជាភោជន៍មានព្រលឹង
គួរនឹករំពឹងកុំទីសទាស
នាម៉ឺនមន្ត្រីមកពីពាស្ត្រ
គឺពាស្ត្រឡើងទៅជាមន្ត្រី ។
បាយផ្ទះបាយវត្តដូចជាគ្នា
ចំអែតអាត្មាមានជីវី
ឆ្អែតហើយរៀនសូត្យចេះខ្វេចខ្វី
មុនីកើតមានដោយសារវត្ត ។
សាធុ ! សូមឱ្យអ្នកបានសុខ
នីរទុក្ខនីរភ័យសិរីកំទ្រ
ជាជនសប្បុរសរបស់រដ្ឋ
មានបែបមានបទប្រសើរហោង !

**សម្ដេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញ្ញាណោ**
**ថ្ងៃទី ១៦ ឧសភា ១៩៦៣**




# វិធីអាន

(បទពាក្យប្រាំពីរ)

១. ខ្ញុំយល់ថាអានមានបួនបែប បើគិតសង្ខេបឱ្យនៅខ្លី
**អានមួយ**មិនចាំបាច់គិតអ្វី មិនបាច់រកន័យ**អានសប្បាយ** ។
២. អានប្រលោមលោករឿងនិទាន អត្ថបទផងមានចុះផ្សព្វផ្សាយ
អានមិនចេះអត់គឺអានងាយ មិនចាំមិត្តប្រាយស៊ីជំរៅ ។
៣. **អានពីរ**ក៏ងាយហើយរហ័ស ក៏អាចដឹងច្បាស់មិនសល់នៅ
**គឺអានដំណឹង**ផងរាក់ជ្រៅ ព័ត៌មានក្នុងក្រៅសព្វបែបយ៉ាង ។
៤. ត្រូវអានចោះៗឱ្យបានការ អានយកត្រង់ណាជាភស្តុតាង
កុំអានតែពាសវាសត្រេងត្រាង មិនអានល្អជាងនាំខាតពេល ។
៥. **អានបីអាន**ទ្រឹងសំឡឹងគិត អានទាំងគំនិតគ្មានប្រហែល
អាននេះពិបាកអានច្រំដែល យូរអានយូរពេល**អានស្រាវជ្រាវ** ។
៦. **អានបួន**អានយ៉ាប់ខ្លាំងជាងគេ អានគិតរិះរេអានមិនព្រាវ
ឱ្យដឹងខុសត្រូវមិនអានព្រាវ អានស្រង់អានស្រាវ**អានផ្ទៀងផ្ទាត់** ។
៧. **តើត្រូវធ្វើម្ដេចអានបានលឿន** សាច់ការក៏ជឿនកើនមិនហត់
ចូរធ្វើតាមក្បួនល្អប្រាកដ អានមានអំណត់បានយូរផង ។
៨. ខ្ញុំសូមរំឭកអ្នកអានថា ពេលចូលគេហាដោយទំនង
ភ្នែកឃើញវត្ថុទាំងអស់ផង ភ្នែកឃើញម៉ត់ម៉ង់មិនសល់អ្វី ។
៩. ពេលនោះភ្នែកយើងមិនបានផ្ដោត វត្ថុមួយសោតឬពីរបី
ម្ដេចក៏ភ្នែកយើងដោយមិនភ័យ មិនប្រឹងមើលខ្មីឃើញទាំងអស់ ។
១០. ឧបមាមួយទៀតចោលភ្នែកទៅ លើមនុស្សម្នាក់នៅពីមុខស្មោះ
ឃើញថាចាស់ក្មេងគ្មានចន្លោះ ទាំងទ្រព្យរបស់លើអង្គប្រាណ ។
១១. សេចក្ដីនេះហើយដែលយើងប្រើ មិនមានស្ទាក់ស្ទើរក្នុងអំណាន
ពេលយើងចោលភ្នែកគ្មានរំខាន ភ្នែកប្រមូលបានទិដ្ឋភាពសព្វ ។
១២. ទាំងរូបអត្ថបទចំណងជើង ទំព័រប្រាប់យើងច្បាស់គ្រប់ជប់
អក្សរមូលជ្រៀងដឹងមួយចប់ ដឹងដល់កំណាប់ន័យត្រួសៗ ។

១៣. ចោលភ្នែកពីឆ្វេងទៅខាងស្ដាំ ព្យាយាមចងចាំហើយជ្រលួស
អានដើមបន្ទាត់រួចបង្ហួស កណ្ដាលត្រួសៗនូវខាងចុង ។
១៤. ព្យាយាមអានម្ដងពីរបន្ទាត់ ចាប់ន័យប្រាកដដាក់ទៅក្នុង
ខួរក្បាលអ្នកចាំភ្នែកអ្នកប្រុង កុំយកទាំងស្រុងមិនបានការ ។
១៥. ជ្រើសរើសយកន័យដែលចង់បាន មិនបាច់ចង់បានដូចទេសនា
ដូចកលបេះម្ទេសក្នុងចំការ ច្បិចយកផ្លែណាដែលទុំៗ ។
១៦. គេច្រើនតែយកវិធីនេះ ទុកជាចំណេះមិនលំៗ
ចំណេញទាំងពេលបានផលធំ ពិសេសនិយមអានកាសែត ។
១៧. ចំពោះអំណានដែលពិបាក ត្រូវតែប្រឹងសាកកុំបណ្ដែត
ធ្វើតាមខ្ញុំទៀតនឹងដឹងហេតុ នឹងបានធ្លុះធ្លែតវិជ្ជាពិត ។
១៨. កត្ដាចំបងធំជាងគេ គ្មានអ្វីប្លែកទេគឺ**តាំងចិត្ត**
ថានឹងប្រឹងអានដល់កម្រិត មិនរត់មិនមឹតចោលវិជ្ជា ។
១៩. កត្ដាទីពីរក៏សំខាន់ អ្នកត្រូវប្រកាន់នូវខ្លឹមសារ
គឺ**អារម្មណ៍ល្អ**ត្រជាក់ថ្លា មិនហើរឆ្ងេឆ្ងាចិត្តនឹងន។
២០. កត្ដាទីបីគឺ**បរិស្ថាន** ប្រាកដនោះមានអ្វីៗល្អ
គឺកន្លែងស្ងាត់មិនកុះករ រៀបចំបវរមិនទើសភ្នែក ។

**លោក ឈា ឈៀន**
(អគ្គនាយករង គ.ប.ច. អយក.)

## *តើភពផែនដីយើងមានអាយុប៉ុន្មាន ?*

*មនុស្សមានវ័យចំណាស់បំផុតដែលរស់បានមកដល់សព្វថ្ងៃនេះគឺ មានអាយុ ១១៤ ឆ្នាំ ។ អណ្ដើកអាចរស់បាន លើសពី ១៥០ ឆ្នាំ ចំណែកឯត្រីសមុទ្រ ដែលគេរកឃើញនៅក្នុងទឹកកក នៅបាតសមុទ្រនៅឆ្នាំ ២០០៧ នៅប្រទេសអ៊ីសឡង់* (Iceland)*មានអាយុលើសពី ៤០០ ឆ្នាំ រីឯដើមឈើមួយដើមនៅប្រទេសស៊ុយអែត ត្រូវបានគេជឿជាក់ថាមានអាយុប្រហែល១០.០០០ឆ្នាំ ។ ប៉ុន្ដែអ្វីៗទាំងអស់នេះហាក់ដូចជាដំណក់ទឹកនៅក្នុងមហាសមុទ្រអញ្ចឹងដែរ ប្រសិនជាយើងធ្វើការប្រៀបធៀបជាមួយនឹងផែនដីយើង ដែលមានអាយុដែលមិនគួរឱ្យជឿ គឺ ៤, ៥ ពាន់លានឆ្នាំ (បួនពាន់ប្រាំរយលានឆ្នាំ) ។*

*នៅក្នុងឆ្នាំ ២០០៨ នៅឆកសមុទ្រហតសាន់* (Hudson) *នៃប្រទេសកាណាដា អ្នកភូតព្វវិទូបានរកឃើញកំណាកថ្មដែលមានអាយុចាស់ជាងគេបំផុតនៅលើពិភពលោក ។ ក្រោយពេលយកទៅពិសោធន៍ដោយវិទ្យុសកម្ម វាក៏បានបង្ហាញឱ្យឃើញថា សំណាកថ្មនោះមានអាយុកាលរហូតដល់៤,២៨ពាន់លានឆ្នាំ ។*

**អ៊ិនជីណែត**

# សីលប្រាំខាយចាំមិនភ្លេច សីលប្រាំជានិច្ចអ្នកសាងកុសល (តចប់)

(បទកាកគតិ)

១. លោកថាកាមេ តែងអាស្រូវកេរ្តិ៍ នាំឱ្យគេខឹង
កុំឱ្យទាក់ទង កុំខំសញ្ជឹង គិតពីរឿងហ្នឹង
គ្មានបានផលអ្វី ។

២. ស្រីពាក់ព័ន្ធប្រុស កុំប៉ះឱ្យសោះ ប្តីអ្នកដទៃ
នាំទុក្ខដល់ខ្លួន ជារឿងចង្រៃ ហើយសែនអប្រិយ៍
លោកឱ្យជៀសឆ្ងាយ។

៣. ឯប្រុសៗវិញ លោកឱ្យជៀសចេញ ស្រីអ្នកទាំងឡាយ
កុំធ្វើផ្តេសផ្តាស នាំឱ្យអន្តរាយ មិនបានសុខកាយ
ជារឿងរហូត ។

៤. មុសាវាទា កើតឡើងពេលណា នាំឱ្យគេក្រោធ
ព្រោះពាក្យភូតភរ និងពាក្យបញ្ឆោត ពុំដែលល្អសោត
គេអាចជឿបាន ។

៥. ពាក្យភូតកុហក ហៅសែនអាក្រក់ គេពុំរាប់អាន
គេលែងទុកចិត្ត គេស្អប់ដល់ប្រាណ ដល់អ្នកដែលបាន
ប្រើពាក្យមុសា ។

៦. សុរាមេរយ(សុរាមេរ័យ) អស់ទាំងប្រុសស្រី នៅក្នុងលោកា
ព្រះកុំឱ្យសេព នាំក្តៅឱរា ប៉ះវាពេលណា
ភ្លេចភ្លាំងស្មារតី ។

៧. មិនថាចាស់ក្មេង ធ្វើឱ្យវង្វេង លែងជាប្រក្រតី
លែងស្គាល់ម៉ែឪ បងប្អូនប្រុសស្រី បានឈ្មោះអប្រិយ៍
ខូចទ្រព្យផ្សេងៗ ។

៨. សីលទាំងប្រាំនេះ បើអ្នកណាចេះ រក្សាខ្ជាប់ខ្លួន
ព្រះថាបានសុខ និងបានរួចខ្លួន ឱ:ឱកូនស្ងួន
ចូរកាន់ឱ្យបាន ។

៩. ដល់ពេលស្លាប់ទៅ ព្រលឹងកូនចៅ ទៅសួគ៌និព្វាន
ជាកន្លែងសុខ លើសអស់សព្វឋាន គឺសួគ៌វិមាន
នោះឯងហើយណា។

១០. នៅទីបញ្ចប់ ខ្ញុំសូមគោរព ព្រះធម៌ថ្លៃថ្លា
ដែលបង្រៀនប្រដៅ ជនគ្រប់រូបា ត្រិះរិះសិក្សា
រំលឹកព្រះគុណ ។

១១. អាចជួយរំដោះ អស់ទាំងបាបគ្រោះ ទោះស្រាលឬធ្ងន់
បើយើងកាន់បាន សែនល្អពេកពន់ បានសុខដល់ខ្លួន
រហូតទៅហោង ។

ដកស្រង់ចេញពីសៀវភៅធម្មជីវិត (ព្រះមហាម៉ាសុរិនវិសុទ្ធា)



# ពុទ្ធសាសនានិងសង្គមខ្មែរ(តចប់)

ប្រទេសកម្ពុជាយើងធ្លាប់មានអ្នកប្រាជ្ញសាសនា អក្សរសាស្ត្រ វប្បធម៌ ប្រវត្តិសាស្ត្រយ៉ាងល្បីល្បាញជាច្រើន ដូចជាសម្ដេចព្រះសង្ឃរាជជួន ណាត,សម្ដេចហួត តាត, លោកគ្រូអាចារ្យហែម ចៀវ, សូរ ហាយ, ប៉ាងខាត់,ខៀវ ជុំ, ចាប ពិន,សេខ នាង, កឹម តូ, ឈឹម ស៊ុមន៍។ល។ ដែលបានសរសេរធម្មវិន័យ និងក្បួនច្បាប់ស្ទើររាប់មិនអស់ ។ អ្នកនិពន្ធកាព្យឃ្លោងក៏មានច្រើនរូបដែរ ដូចយ៉ាងឧកញ៉ាសុត្តន្តប្រីជាឥន្ទ, ព្រះបាទអង្គ ឌួង, ក្រម ង៉ុយ, អ៊ូ ចុង (កូនក្រមង៉ុយ) ជាដើមសុទ្ធតែជាអ្នកប្រាជ្ញនិពន្ធច្បាប់ទូន្មានកូនចៅខ្មែរ ឱ្យប្រតិបត្តិតាមឱវាទ ឱ្យស្រឡាញ់ប្រទេសជាតិ ឱ្យរួបរួមសាមគ្គីគ្នា។ សូម្បីតែអ្នកសិល្បៈចម្រៀងទាំងឡាយ ក៏សុទ្ធសឹងតែធ្លាប់បានបួសរៀនផ្លូវលោកផ្លូវធម៌នៅក្នុងវត្តអារាមដែរ។ ដូច្នេះវត្តពុទ្ធសាសនា ជាគ្រឹះ ជាឫសយ៉ាងមាំសម្រាប់ការពារវប្បធម៌ អក្សរសាស្ត្រ ប្រវត្តិសាស្ត្ររបស់ប្រទេសជាតិ ។ គ្រាមានភ័យអាសន្នអន្តរាយឬមានការភ័ន្តប្រែចលាចល ឬចម្បាំងរាំងជល គេរមែងយកវត្ត យកព្រះសង្ឃជាទីជ្រកកោន ។

កាលសម័យអាណានិគមបារាំងត្រួតត្រាកូសាំងស៊ីននោះប្រទេសបារាំងដែលមានភារៈគ្រាន់តែជាអាណាព្យាបាលលើប្រទេសខ្មែរប៉ុណ្ណោះ បែរជាពង្រឹងឥទ្ធិពលរបស់ខ្លួនឱ្យទៅជាមេអាណានិគម ប្រើអាវុធយុទ្ធភណ្ឌសង្កត់សង្កិនយកប្រទេសខ្មែរជាស្រុកចំណុះរបស់បារាំងទៅវិញ ហើយបានប្លន់លួចកេតនភណ្ឌរបស់ខ្មែរយកទៅប្រទេសបារាំង ព្យាយាមបំបាត់អក្សរសាស្ត្រខ្មែរ ហើយថែមទាំងធ្វើទារុណកម្មយ៉ាងធ្ងន់ទៅលើព្រះសង្ឃខ្មែរទៀតផង ។ កាលពីថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៤២ បារាំងបានបញ្ជាឱ្យចាប់ផ្សឹកលោកគ្រូអាចារ្យ ហែម ចៀវ នៅក្រសួងមហាផ្ទៃ រួចបញ្ជូនទៅដាក់គុកនៅកោះត្រឡាច កាត់ទោសប្រហារជីវិត រួមទាំងលោកគ្រូ អាចារ្យ ប៉ាង ខាត់ , នួន ដួង និងលោក ប៉ាច ឈឺន ផងដែរ ។

សូមអស់លោកអ្នកអានទាំងឡាយជួយចងចាំចំណាំទុកឱ្យច្បាស់ចុះថា ប្រទេសកម្ពុជាយើងធ្លាប់រងគ្រោះអន្តរាយហិនហោចទ្រព្យសម្បត្តិ គម្ពីរក្បួនច្បាប់ និងអ្នកប្រាជ្ញសំខាន់ៗច្រើនលើកច្រើនគ្រា ស្ទើរតែឥតស្រាកសោះ។ ថាអាណានិគមបរទេសទៅចុះ គេហ៊ានបំផ្លាញខ្មែរ ចុះខ្មែរក្រហមដែលធ្លាប់ហូបបាយវត្តដែរនោះ ម្ដេចឡើយ ក៏សាហាវហ៊ានបំផ្លិចបំផ្លាញវត្តអារាម ព្រះពុទ្ធរូប កេតនភ័ណ្ឌ និងកាប់សម្លាប់ព្រះសង្ឃ ឥតត្រាប្រណីយ៉ាងហ្នឹង ? ។

យើងដឹងហើយថា ខ្មែរក្រហមមិនទទួលខុសត្រូវរឿងបំផ្លាញសម្បត្តិទ្រព្យ វត្តអារាម ជីវិតខ្មែរទេ គេបបួលណាត់គ្នានិយាយយ៉ាងព្រងើយថា អ្វីៗទាំងអស់ស្រេចលើប្រវត្តិសាស្ត្រកត់ត្រាទុកចុះ ។ គេចូលចិត្តកាច់មួលថា ពុទ្ធសាសនាបង្ខាត់មនុស្សឱ្យស្លូតបូត បានជាខ្មែរស្លូតស្លាប់ គេយកដីជិតអស់ហើយ ។ ប៉ុន្តែអ្នកដែលកាចសាហាវផុតគេក្នុងពិភពលោកដូចខ្មែរក្រហមនោះក៏មិនឃើញច្បាំងឈ្នះបរទេស ហើយយកដីមួយហត្ថមកឱ្យខ្មែរម្ដងណាឡើយ ឃើញតែហែកទឹកដីខ្មែរ ព្រៃឈើខ្មែរទៅឱ្យបរទេសជិតខាង ហើយសម្លាប់ខ្មែរផ្គាប់ចិត្តបរទេសលើសគេទៅទៀត ។ ដូច្នេះយើងអាចយល់ច្បាស់ថា លទ្ធិ ឬទ្រឹស្ដីកាចឃោរឃៅទាំងប៉ុន្មានក្នុងលោក ពីអតីតកាលក្ដី បច្ចុប្បន្ននេះក្ដី ប្រាកដជាពុំមែនជាវិធីដោះស្រាយបញ្ហាទេ ឯលទ្ធផលនៅត្រង់សូន្យ ។

សេចក្តីរៀបរាប់បន្តិចបន្តួចអំពីរឿងអាណានិគម និងអំពើសាហាវរបស់ខ្មែរក្រហមនេះ ប្រហែលនាំឱ្យអ្នកអានខ្លះទាស់ចិត្តកើតទោមនស្សថា ម៉េចក៏យករឿងនយោបាយទៅបញ្ចូលក្នុងរឿងពុទ្ធសាសនាយ៉ាងនេះ ។

សូមជ្រាបថា ពុទ្ធធម៌ដែលនៅក្នុងព្រះត្រៃបិដកនោះឯង ជានយោបាយរបស់ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ត្រិះរិះណែនាំពន្យល់សត្វលោកឱ្យប្រតិបត្តិតាម ។ ព្រះអង្គជាព្រះបរមសាស្តាយល់ច្បាស់ក្រៃលែងក្នុងវិជ្ជានយោបាយ ទ្រង់ពូកែទេសនាពន្យល់អ្នកស្តាប់ឱ្យឆាប់យល់ ដោយទ្រង់ទាញយកដំណើរជីវិតរបស់សត្វលោកពីអតីតកាល( ជាតក )មកភ្ជាប់ជាមួយជីវិតបច្ចុប្បន្ន រួចថែមទាំងព្យាករណ៍ដំណើរជីវិតទៅអនាគតទៀតផង ។ នេះហើយជានយោបាយក្នុងការទេសនានៃព្រះដ៏មានបុណ្យនៃយើង ។ ព្រះអង្គបានបង្ហាត់បង្រៀនឧបាយកលទេសនាដល់ព្រះសង្ឃសាវ័ករបស់ព្រះអង្គ ដូចជាព្រះសារីបុត្ត ព្រះមោគ្គល្លាន ព្រះអានន្ទជាដើមដែលសុទ្ធតែមានបច្ចេកទេស មានកោសល្យក្នុងការណែនាំមនុស្សលោកដែលជួនកាលត្រូវដោះស្រាយប្រស្នាអ្នកកាន់លទ្ធិឬសាសនាផ្សេងៗ ជួនកាលត្រូវដោះស្រាយបញ្ហាជនពាល បណ្ឌិត ស្តេច មន្ត្រី ។ល ។ ព្រះសម្ពុទ្ធក្តី ព្រះសង្ឃសាវ័កក្តី សុទ្ធតែវៃឆ្លាតក្នុងការប្រមើលមើលនិស្ស័យសត្វដែលត្រូវទូន្មាន ឬមិនត្រូវទូន្មាន ។ មនុស្សខ្លះដែលព្រហើនកោងកាចហួសកែមិនឡើង សូម្បីជាព្រះញាតិរបស់ព្រះអង្គ ក៏ព្រះអង្គប្រោសមិនកើតដែរ ដូចយ៉ាងទេវទត្តជាអ្នកលេងជើងចាស់ ព្យាយាមព្យាបាទឈ្នានិសព្រះអង្គ រហូតធ្លាក់រណ្តៅខ្លួនឯង ។

ក្នុងបច្ចុប្បន្ននេះក៏ដូចពីអតីតកាលដែរ គេតែងចាប់ថ្នាក់ចោទប្រកាន់ថា ព្រះអង្គខ្លះទេសនានយោបាយព្រះលោកទេសនាចំៗ ច្បាស់ៗ ដូចជាប្រើពាក្យថា ត្រូវស្រឡាញ់ជាតិ សាសន៍ កុំគប្បីសម្លាប់ពូជសាសន៍ខ្លួន កុំស៊ីសំណូក កុំលួចលាក់សម្បត្តិជាតិ ។ ល ។

ដូចម្តេចហៅថា «នយោបាយ »? ពាក្យក្លាយមកពីពាក្យបាលីថា នយ+ ឧបាយ = នយោបាយ ប្រែថាឧបាយក្នុងការដឹកនាំ, កលល្បិចក្នុងការណែនាំពន្យល់ឬមេគំនិតដែលគេផ្តើមឡើងដើម្បីដឹកនាំអ្នកដទៃឱ្យប្រព្រឹត្តទៅរកទីដៅយ៉ាងនេះយ៉ាងនោះត្រូវនឹងពាក្យថា Politics ។ ពាក្យនេះ មិនមែនសំដៅយកចំពោះតែការដឹកនាំរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ គឺសំដៅយកការដឹកនាំសង្គម ស្រុកទេស សាសនា គ្រួសារផងដែរ ។ គេឯងទាំងអស់គ្នានិយាយថា នយោបាយទឹកភ្លើង , នយោបាយកសិកម្ម,នយោបាយសេដ្ឋកិច្ច, នយោបាយពាណិជ្ជកម្ម, នយោបាយបរទេស, នយោបាយជាតិ, នយោបាយរួបរួម, នយោបាយបំបែកបំបាក់ , នយោបាយបំផ្លាញ , នយោបាយកសាង , នយោបាយរំលត់ទុក្ខសាងសុខ។ល។មនុស្សលោកកើតមក ទោះបីបានរៀននយោបាយក្តី មិនបានរៀនក្តី សុទ្ធតែមានគំនិតកិច្ចកលជាធម្មជាតិរបស់ខ្លួន ។ បើគ្មាននយោបាយទេ ប្រាកដជាមិនគ្រប់ គឺវិកលចរិតនោះឯង ។ មាតាបិតាប្រើនយោបាយរកទ្រព្យមកចិញ្ចឹមបុត្រធីតា ប្រើនយោបាយសន្សំសំចៃធនធាននិង ប្រើកលល្បិចណែនាំពន្យល់កូនចៅឱ្យដើរទៅរកផ្លូវត្រូវ បញ្ចុះបញ្ចូលកូនចៅឱ្យប្រឹងរៀនសូត្រ ប្រកបការងារជាដើម ។ ទាំងអស់នេះសុទ្ធតែឧបាយនាំទៅរកទីដៅ គឺនយោបាយនោះឯង ។

**ដកស្រង់ពីសៀវភៅពន្លឺពុទ្ធសាសនា**

រៀបរៀងដោយ **លោកសោម ខន**

| | |
|---|---|
| *វិជ្ជា* | *នាំឱ្យមានវិន័យ* |
| *វិន័យ* | *នាំឱ្យមានសេចក្តីថ្លៃថ្នូរ* |
| *សេចក្តីថ្លៃថ្នូរ* | *នាំឱ្យមានគុណធម៌* |
| *គុណធម៌* | *នាំឱ្យយើងក្លាយជាមនុស្សល្អ។* |

*ស្រីហិតោបទេស*

# ឋានានុក្រមបព្វជិតពុទ្ធសាសនាខ្មែរ(តចប់)

**សភាសង្ឃ**

មានសភាសង្ឃបីប្រភេទ ៖

១. មានសភាជាន់ខ្ពស់ឬ ថេរសភាពីរ ៖ ថេរសភា មួយសម្រាប់និកាយនីមួយៗ ហើយស្ថិតនៅអមសង្ឃនាយកនៃគណៈរៀងៗខ្លួន ។

២. សភាកម្រិតមួយឬសាលាគណៈ សាលាគណៈនីមួយៗស្ថិតនៅអមមេគណនីមួយៗ ។

៣. សភាកម្រិតពីរឬសាលាអនុគណស្ថិតនៅអមអនុគណ ។

ថេរសភានីមួយៗ ត្រូវមានប្រធានមួយរូប នឹងសមាជិកប្រាំបួនរូប សម្រាប់សម្គាល់មហានិកាយនិងមានសមាជិកប្រាំរូបនិងអនុលេខាធិការមួយរូប។ សមាជិកនៃសមាជិកទាំងនោះត្រូវបានតែងតាំងឡើងដោយព្រះមហាក្សត្រតាមរយៈការស្នើសុំរបស់សង្ឃនាយក និងបន្ទាប់ពីយោបល់របស់រដ្ឋមន្ត្រីក្រសួងធម្មការ ។សមាជិកទាំងឡាយ ត្រូវបានជ្រើសរើសយកក្នុងចំណោមមន្ត្រីជាន់ខ្ពស់ ។ ប្រធានត្រូវជ្រើសរើសយកក្នុងរាជាគណៈថ្នាក់ឯក ចំណែកឯលេខាធិការត្រូវជ្រើសរើសក្នុងចំណោមព្រះភិក្ខុសង្ឃ ទីឋានានុក្រម ។

សភាសង្ឃផ្សេងៗទាំងនោះ ត្រូវចេះដឹងកិច្ចការខាងសាសនាយ៉ាងម៉ត់ចត់ ព្រមទាំងយល់ដឹងអធិករណ៍សាសនាភ្ជាប់និងកិច្ចការអាណាចក្រផង ។

ថេរសភាគឺជាសាលាជាន់ខ្ពស់ខាងសាសនា ដែលមានសមត្ថកិច្ចត្រឹមត្រូវតាមគន្លងច្បាប់ ដើម្បីសម្រេចដោយគ្មានបើកផ្លូវឧទ្ធរណ៍នូវកិច្ចការទាំងឡាយដែលជាកម្មវត្ថុនៃក្រមដីកា( សេចក្ដីសម្រេច )របស់សាលាគណកាលណាក្រមដីកានេះត្រូវបានតវ៉ា ។ ថេរសភាអាចត្រូវបានភាគីមួយតវ៉ា ។ ថេរសភាអាចត្រូវបានរដ្ឋមន្ត្រីក្រសួងធម្មការ តាមរយៈព្រះសង្ឃនាយក ប្ដឹងឱ្យជំនុំជំរះរឿងថ្មីៗបាន ។

សាលាគណទាំងឡាយ បង្កបង្កើតជាសភាកម្រិតទី១ ដែលមានសមត្ថកិច្ចត្រឹមត្រូវតាមគន្លងធម៌ ដើម្បីដោះស្រាយកិច្ចការទាំងឡាយដែលជាកម្មវត្ថុនៃក្រមដីកា(សេចក្ដីសម្រេច) របស់សាលាអនុគណ, កាលណាក្រមដីកានោះត្រូវបានភាគីណាមួយបដិសេធ ឬភាគីណាមួយសើរើប្ដឹងសាជាថ្មី ឬក៏មានរឿងថ្មីទៀត ដែលលោកចៅហ្វាយស្រុកបាន បញ្ជូនមកសាលាគណដោយផ្ទាល់ដើម្បីពិនិត្យពិចារណា ។

សាលាអនុគណទាំងឡាយ គឺសភាកម្រិតទី២ ដែលមានសមត្ថកិច្ចត្រឹមត្រូវតាមគន្លងធម៌ ដើម្បីពិនិត្យដោះស្រាយជាដំបូង ហើយតាមគំនិតផ្ដើមនៃភាគីសាមី ឬគំនិតផ្ដើមរបស់ចៅហ្វាយស្រុកនូវរឿងទាំងឡាយណាដែលបាននិយាយខាងលើ ហើយដែលរឿងទាំងឡាយនោះបានកើតមានឡើងនោះលើផែនដីរបស់ស្រុក ។

**មេគណនិងអនុគណ**

ខេត្តនីមួយៗនៃព្រះរាជាណាចក្រកម្ពុជាបង្កើតបានជាគណ ដែលដឹកនាំដោយលោកគ្រូមេគណមានមុខងារជាទីរាជាគណៈ ។

លោកគ្រូមេគណដែលត្រូវឡើងផ្ទាល់មកព្រះសង្ឃនាយក ត្រូវស្ថិតនៅក្រោមអំណាចរបស់ក្រសួងធម្មការ។ យើងបានឃើញហើយថា លោកគ្រូមេគណត្រូវបានសភាកម្រិតទី១ គឺសាលាគណជួយក្នុងការងារ។ សភានេះមានសមាជិកបួនរូបគឺលោកគ្រូមេគណជាប្រធាន លោកគ្រូបាឡាត់គណ លោកគ្រូវិន័យធរគណ និងលោកគ្រូសមុហ៍គណ ។

លោកគ្រូអនុគណជាប្រមុខនៃស្រុកនីមួយៗ ។ លោកមានងារទីឋានានុក្រម ស្ថិតនៅក្រោមអំណាចផ្ទាល់របស់មេគណរបស់ខេត្ត ។

លោកគ្រូអនុគណ ត្រូវបានសភាកម្រិតទីពីរគឺសាលាអនុគណជួយក្នុងការងារ ។ សាលាអនុគណមានសមាជិកបីរូបគឺលោកគ្រូអនុគណជាប្រធាន ,លោកគ្រូវិន័យធរ , និងលោកគ្រូសមុហ៍ ។

ចំពោះគណៈធម្មយុត្តិ មិនមានលោកគ្រូអនុគណ និងមិនមានសាលាអនុគណទេ ។ គណៈធម្មយុត្តិ មិនតម្រូវឱ្យមានសាលាគណមួយសម្រាប់ខេត្តនីមួយៗទេ គឺដោយសារវត្តធម្មយុត្តិមានតិច ។ ក្នុងករណីនេះ « លោកចៅហ្វាយខេត្តផ្ទាល់ទទួលបន្ទុកមើលការខុសត្រូវ ឬក្នុងករណីចាំបាច់ជួយធ្វើឱ្យមានដំណើរការល្អដល់វត្តអារាមទាំងឡាយរបស់និកាយនេះ » ។

ទីក្រុងភ្នំពេញបង្កបង្កើតទៅជាគណៈមួយ សម្រាប់គណៈនីមួយៗដោយមានលោកគ្រូមេគណនិងសាលាគណរៀងៗគណៈ ។ ប៉ុន្តែថាគណៈរបស់រាជធានីមិនមានអនុគណនិងសាលាអនុគណទេ ។

លោកគ្រូមេគណ ត្រូវបានតែងតាំងឡើង តាមសេចក្តីសម្រេចរបស់ព្រះសង្ឃនាយកនៃគណៈនីមួយៗក្រោយពីបានសេចក្តីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ ។ ការតែងតាំងនេះបាននាំឱ្យមានជាស្វ័យប្រវត្តិ នូវការដំឡើងឋានន្តរស័ក្តិរាជាគណៈដោយព្រះមហាក្សត្រ ។

ត្រូវបានតែងតាំងដោយព្រះសង្ឃនាយកនៃគណៈនីមួយៗ ដោយសេចក្តីយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ និងតាមសេចក្តីស្នើរបស់លោកគ្រូមេគណៈផងគឺ ៖ បាឡាត់គណ, អនុគណ, វិន័យធរ, សមុហ៍ ។ ក៏ដូចគ្នានេះដែរសម្រាប់លេខាធិការ របស់សាលាគណ និងអនុលេខាធិការរបស់សាលាអនុគណ ។

**លោក គួយ សុគាន**

សាស្ត្រាចារ្យវិទ្យាស្ថានជាតិអប់រំ

## *ជីវិតមាន់ជល់*

*គេសង្កេតឃើញថា ពេលមាន់ជល់គ្នា តែងមានចាញ់និងឈ្នះ បើជល់តិចរបួសតិច បើជល់ខ្លាំងរបួសខ្លាំង ហើយសម្រាប់អ្នកចាញ់អាចអស់ជីវិតក៏សឹងមាន ឯអ្នកឈ្នះឯណោះវិញក៏មិនខានពីការត្រូវ របួសឡើយ ទាំងសងខាងគ្មានបានទទួលអ្វីក្រៅពីការឈឺចាប់នោះឡើយ ឯផលប្រយោជន៍ត្រូវធ្លាក់ទៅលើម្ចាស់ទាំងអស់ ។*

*យ៉ាងណាមិញ សត្វលោកទាំងអស់ មិនចំពោះតែមាន់ទេ សូម្បីមនុស្ស បើគិតតែប្រទូសរ៉ាយ ប្រកួតប្រជែង ចង់យកឈ្នះអ្នកដទៃដោយគំនិតអាក្រក់ផ្សេងៗ ហើយក៏បៀតបៀនគ្នាទៅ តើមានអំណាចណាដែលគ្រាន់បើជាងមាន់នោះ ? សេចក្តីពិត គ្មានបានទទួលអ្វីក្រៅពីពៀរវេរា និងការឈឺចាប់ឡើយ ព្រោះគ្រប់គ្នាសុទ្ធតែជាប់ក្នុងទ្រុងមច្ចុរាជសមដូចដែលព្រះមានប្រភាគបានត្រាសសម្តែងទុកក្នុងគម្ពីរខុទ្ទកនិកាយ ធម្មបទគាថា ថា ៖*

*« ជយំ វេរំ បសវតិ ទុក្ខំសេតិ បរាជិតោ ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។ »*

*បុគ្គលអ្នកឈ្នះ តែងរងនូវពៀរ បុគ្គលដែលចាញ់ តែងដេកជាទុក្ខ ចំណែកអ្នកលះបង់នូវការឈ្នះ និងការចាញ់ជាអ្នកស្ងប់រម្ងាប់ ហើយដេកនូវជាសុខ ។*

ទំព័រស្ត្រី

# រឿងព្រេង ជ័យ សួស្តី

វេលានេះ សូមបរិយាយអំពីពាក្យថា « **ជ័យហោង** ! **សួស្តីហោង** ! **មែនហោង** ! » តាមឯកសាររបស់ក្រុមជំនុំទំនៀមទន្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យភ្នំពេញ មានសេចក្តីដូចតទៅ ៖

ជនានុជននៅប្រទេសខ្មែរ កាលបើមានធ្វើពិធីមង្គលការ វេលាដែលកូនប្រុសស្រីកំពុងក្រាបផ្ទឹមគ្នា នាកណ្តាលទីប្រជុំពួកញាតិមិត្ត មានមាតាបិតាជាដើម ដើម្បីសំពះទទួលស្លាពអំពីមេបានោះ លោកអាចារ្យតែងស្រែកសួរពួកញាតិមិត្តនៅទីនោះថា « ជ័យហោង ?»

ពួកញាតិមិត្តឆ្លើយព្រមគ្នាថា « **ជ័យ** ! »

លោកអាចារ្យសួរទៀត ថា « **សួស្តីហោង** !»

ពួកញាតិមិត្តថា « **សួស្តី** ! »

លោកអាចារ្យថា « **មែនហោង** »

ពួកញាតិមិត្តថា « **មែន** ! »

លោកអាចារ្យថា « **យកអ្វីជាបន្ទាល់** »

ពួកញាតិមិត្តថា « **យកហ៊ោជាបន្ទាល់** »

រួចក៏តាំងនាំគ្នាស្រែកហ៊ោកងរំពងពេញផ្ទះ៣ដង ឯលោកអាចារ្យក៏លើកឃ្មោះឡើងវាយយ៉ាងខ្លាំងឮសូរមូងៗទុកជាសញ្ញាថា កូនប្រុសស្រីគូស្វាមីភរិយាថ្មី មានសិរីសួស្តីជ័យមង្គលហើយ ។

របៀបនេះ អ្នកផងនៅប្រទេសខ្មែរយើង គេតែងធ្វើគ្រប់គ្នារាល់តែពេលរៀបមង្គលការកូនប្រុសស្រី ។

• សំណួរ ៖ គួរឱ្យឆ្ងល់ណាស់ ចុះហេតុអ្វី បានជាជាតិខ្មែរប្រកាន់យកពាក្យ « **ជ័យហោង** ! **សួស្តីហោង** ! **មែនហោង** ! » បីបទនេះមកធ្វើជាត្រីមុខក្នុងពិធីមង្គលការ ?។

• ឆ្លើយ ៖ ព្រោះមានអតីតនិទានជារឿងព្រេង ដែលចាស់ទុំជំណាលតៗគ្នាមកថា ៖

កាលពីព្រេងនាយ មានស្ត្រីក្រមុំម្នាក់ កំព្រាឪពុក មានតែម្តាយមិនដឹងជានៅស្រុកទេសណាទេ ។ ជួនជាគ្រានោះស្រុកទេសកើតគ្រោះអត់ឃ្លានដោយរាំងភ្លៀងយូរពេក ។ នាងក្រមុំកំព្រាតែងចូលទៅព្រៃរកជីកដំឡូងនិងមើមឈើឯទៀតជាមួយអ្នកស្រុក យកមកស្ងោរបរិភោគជួសបាយតែសព្វថ្ងៃរៀងមក ។ វេលារាត្រីមួយនាងក្រមុំដេកលក់ទៅយល់សប្តិឃើញថា ព្រះឥន្ទយកគជំមួយ មានសម្បុរល្អណាស់មកហុចឱ្យនាង ហើយប្រាប់ថា « **របស់នេះ ជាគជំជំរើស ចូរនាងថែរក្សាទុកឱ្យល្អ ឱ្យគង់នៅយូរលង់ទៅ នាងនឹងបានជាធំពុំលែងឡើយ** » ។ ព្រះឥន្ទប្រាប់រួចក៏គៀសខ្លួនបាត់មួយរំពេចទៅ ។ លុះព្រឹកឡើង នាងក្រមុំដណ្តាំបាយឆ្អិនជួសខ្ចប់ជាសំណុំនិងទឹកមួយបំពង់ រួចលីចបជីក ចូលទៅព្រៃជាមួយអ្នកស្រុកដូចថ្ងៃមុនៗ ។ លុះនាងចូលទៅក្នុងព្រៃឆ្ងាយ ស្រាប់តែមេឃមីរស្រទំងងឹតឈ្លប់ ផ្គរលាន់គ្រឹមៗហាក់ដូចជាធ្លាក់ភ្លៀងភ្លាម ។ ឯពួកចាស់ៗឃើញមេឃងងឹតដូច្នោះក៏និយាយលេងថា «**ហ៎ចាំអីទៀត យើងចាក់ទឹកបំពង់ចោលទៅ ចាំត្រងទឹកភ្លៀងផឹកវិញ**»។ នាងក្រមុំហេតុតែខ្លួននៅក្មេងខ្ចីសេចក្តី ឮសម្តីចាស់ៗដូច្នោះ ក៏ចាក់ទឹកបំពង់របស់ខ្លួនចោលអស់លើងទៅ ។ តមកមិនយូរប៉ុន្មាន ស្រាប់តែមេឃប្រែជាភ្លឺស្វាងស្រឡះទៅវិញ ឥតស្រក់ភ្លៀងមួយដំណក់សោះ ។ បន្ទាប់ពីនោះមកនាងក្រមុំស្រេកទឹកយ៉ាងខ្លាំង ទ្រាំពុំបានក៏ដើរស្វះស្វែងរកទឹកផឹក ទៅដាច់ឆ្ងាយពីគេដល់កន្លែងមួយ នាងឃើញទឹកដក់នៅដានជើងដំរី ដែលវាទើបដើរផុតទៅថ្មីៗ នាងស្មានថាជាទឹកភ្លៀង ដោយស្រេកខ្លាំងពេកក៏ឱនផឹកទាល់តែឆ្អែត ទើបបានដឹងជាក្រោយថា ជាទឹកនោមដំរី ។ នាងវិលមកផ្ទះវិញ ក៏មានទម្ងន់ដោយសារតែផឹកទឹកនោមដំរីនោះ ។ លុះគ្រប់ខែហើយសម្រាលមកជាកូនប្រុសនាងឱ្យឈ្មោះ«**ជ័យ**» ។ ចំណេរក្រោយមកទៀត នាងក្រមុំនោះមានប្តីបានកូនប្រុសម្នាក់ទៀតឱ្យឈ្មោះ «**សួស្តី**»។ មិនយូរប៉ុន្មានប្តីនាងអនិច្ចកម្មទៅ នាងនៅរក្សាចិញ្ចឹមកូនប្រុសទាំងពីរតែម្នាក់ឯង ។

ថ្លែងពីព្រះមហាក្សត្រក្នុងនគរនោះ ស្តេចទ្រង់ព្រះទីវង្គតទៅគ្មានព្រះរាជបុត្រា បុត្រីមួយព្រះអង្គនឹងឡើងគ្រប់គ្រងនគរព្រះរាជវង្សសោះ ។ ទើបពួកអាមាត្យមុខមន្ត្រី ធ្វើពិធីបួងសួងផ្សងដំរីមង្គល ដើម្បីស្វែងរកអ្នកមានបុណ្យវាសនា យកមកអភិសេកសោយរាជ្យក្នុងនគរនោះ ។ ឯដំរីមង្គលនោះ មានរេហ៍ពលជាច្រើនដើរដង្ហែពីក្រោយ ដើរទៅដល់ផ្ទះចៅ**ជ័យ** និងចៅ**សួស្តី** ក៏លុតជើងមុខទ្រោមក្រាបនៅមុខផ្ទះនោះ ។ អាមាត្យមុខមន្ត្រីតាមហែដំរី ឃើញអាការដូច្នេះហើយ ក៏សម្គាល់ថា ចៅ**ជ័យ** និង ចៅ**សួស្តី**ជាអ្នកមានបុណ្យបារមីច្រើនអាចសោយរាជ្យបាន ទើបយកគ្រឿងរាជ្យចូលទៅបំពាក់ចៅ**ជ័យ** ហើយអញ្ជើញឱ្យជិះដំរីមង្គល ហែចូលក្នុងព្រះបរមរាជវាំងតាំងអភិសេកចៅ**ជ័យ** ជាស្តេចសោយរាជ្យ អភិសេកចៅ**សួស្តី**ជាព្រះឧបរាជ ក្នុងពេលជាមួយគ្នា ។ នៅវេលាអភិសេកនោះ សេវកាមាត្យមុខមន្ត្រីទាំងពួងនាំគ្នាបន្លឺសម្រែកថា « ជ័យហោង ! សួស្តីហោង! មែនហោង ! » បីដងស្រេចហើយក៏ចាក់ទឹកក្លស់ទឹកស័ង្ខ អភិសេកសម្រេចកិច្ចមង្គលក្នុងគ្រានោះឯង ។

ពាក្យ « **ជ័យហោង ! សួស្តីហោង** ! មានរឿងព្រេងប្រារព្ធមកដូច្នេះ ។ ចំណែក « **មែនហោង !** » ពុំមានរឿងព្រេងប្រារព្ធចំពោះរូបអ្នកណាទេ ហើយពុំមានអត្ថាធិប្បាយឱ្យពិស្តារផង គ្រាន់តែជាពាក្យដែលលោកអាចារ្យសួរបញ្ជាក់យកសេចក្តីពិតប្រាកដជាលើកទី ៣ បន្ថែមទៅលើពាក្យ **ជ័យហោង** ទី១ **សួស្តីហោង** ទី២ ឱ្យឃើញថាកូនប្រុសស្រីដែលក្រាបសំពះទន្ទឹមគ្នានោះ ជាអ្នកមានជ័យជំនះឈ្នះមារសត្រូវមែន ជាអ្នកមានសិរីសួស្តីមែនៗ ឬពុំមែនប៉ុណ្ណោះ ។ ពួកញាតិមិត្តឆ្លើយបញ្ជាក់ថា « **មែនពិតណាស់ហោង ឥតក្លែងក្លាយទេ** » ។

ហេតុតែមាននិទានរឿងព្រេងដូចថ្លែងមកហើយនេះបានជាមានពាក្យ«**ជ័យហោង ! សួស្តីហោង ! មែនហោង!**» ក្នុងពិធីមង្គលការជាប់ជាទំនៀមទម្លាប់រហូតមកដល់សព្វថ្ងៃនេះ ។

**លោកចែម ផាន**

## *ព្យញ្ជនៈមួយចំនួនដែលគួរដឹង និង ប្រើប្រាស់ពេលបកប្រែឯកសារ*

*កំណត់សម្គាល់ពីព្យញ្ជនៈ ឡាតាំងដែលត្រូវនឹងព្យញ្ជនៈខ្មែរ ការសរសេរជាភាសាខ្មែរនូវសូរបរទេសមួយចំនួន ដែលយើងតែងប្រទះតាមរយៈពាក្យកម្ចី និងត្រូវបានអនុម័តកាលពីថ្ងៃពុធទី២៨ ខែឧសភា ឆ្នាំ២០០៨ គណៈកម្មាធិការជាតិភាសាខ្មែរ (គ.ជ. ភ.ខ.) ៖*

[g] *ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ* [ *ហ្គ*]

[ f ] *ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ* [*ហ្វ* ]

[ z] *ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ* [ *ហ្ស*]

[ J] *ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ* [ *ហ្ឋ* ]

[S] / [z] *ដែលយើងត្រូវប្រើកន្សោមព្យញ្ជនៈ* [ *ស*]

( *គ.ជ.ភ.ខ.* )




## តើលោកគ្រូអ្នកគ្រូដឹងទេពីរង្វាស់រង្វាល់អន្តរជាតិ

| | |
|---|---|
| ១ស.ម = ០,៣៩៤ អ៊ិញ (Inch - in) | ១អ៊ិញ = ២,៥៤ ស.ម |
| ១ម = ៣,២៨១ ហ្វីត (Feet - ft) | ១ហ្វូត (១២អ៊ិញ) = ៣០,៤៨ ស.ម |
| ១ម = ១,០៩៤ យ៉ាត (Yard - yd) | ១យ៉ាត = ៩១,៤៤ស.ម(៣ហ្វីត = ៣៦អ៊ិញ)<br>៣២ម = ៣៥ យ៉ាត |
| ១គ.ម = ០,៦២១ម៉ាយ (Mile - ml)<br>៨គ.ម =៥ ម៉ាយ (ប្រហាក់ប្រហែល) | ១ម៉ាយ=១.៦០៩,៣៤៤ ម<br>(Statute mile តាមក្បួនម៉ាយ) |
| ១គ.ម=០,៥៤០ម៉ាយនៃនាវាអន្តរជាតិ(Nautical Mile International) | ១ម៉ាយ (ម៉ាយនៃនាវាអន្តរជាតិ )=១.៨៥២ ម |
| ១គ.ម$^{២}$=០,៣៨៦១ម៉ាយការ៉េ | ១ម៉ាយការ៉េ (1 Square mile) = ២,៥៩០ គ.ម$^{២}$<br>= ២៥៩ហ.ត |
| ១ក្រាម = ០,០៣៥២៧អោន(Ounce - oz) | ១អោន =២៨,៣ ក្រ |
| ១គ.ក = ២, ២០ ផោន (Pound - lb) | ១ផោន = ៤៥៤ ក្រ |
| ១គ.ក = ០,១៥៧ ស្តោន (Stone) | ១ស្តោន = ៦,៣៥ គ.ក |
| ១ម$^{៣}$ = ២២០ ហ្កាឡុង (Gallon - gal) | ១ហ្កាលឡុង = ៤,៥៤៥ លីត្រ (តាមអង់គ្លេស) |
| | ១ហ្កាលឡុង = ៣,៧៨៥ លីត្រ (តាមអាមេរិច) |

## អំពីរង្វាស់រង្វាល់ខ្មែរបុរាណ

**ប្រវែង:**

១យោជន៍ = ៤០០សិន　១សិន = ២០ព្យាម　១ព្យាម = ៤ហត្ថ　១ហត្ថ = ២ចំអាម
១ចំអាម = ១២ធ្នាប់　១ធ្នាប់ = ៤ក្បៀស　១ក្បៀស = ២គ្រាប់ស្រូវ　១គ្រាប់ស្រូវ = ៨ត្នូចៃ
១ត្នូចៃ = ៨ពងចៃ　១ពងចៃ = ៨ចុងសក់　១ចុងសក់ = ៨ធូលី　១ធូលី = ៨អាណូ
១អាណូ = ៨បរមាណូ ។

**ស្រូវ:**

១០០ថាំង = ៥ដឹក　១ដឹក = ២០ថាំង　១ថាំង = ២តៅ　១តៅ = ២កន្តាំង
១កន្តាំង = ២ខ្យុក　១ខ្យុក = ២តោក　១តោក = ២កំបង់　១កំបង់ = ២ទូកដៃ
១ទូកដៃ = ២ក្តាប់　១ក្តាប់ = ២ចឹប ។

(ស្រង់ចេញពីទស្សនាវដ្តី សិក្សាចក្រ លេខ៦ ឆ្នាំ ២០០៤ )

# ក្រុង ស្រុក ខណ្ឌ-ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២(ត)

## V- បញ្ជីឈ្មោះឃុំតាមស្រុក(ចុងឆ្នាំ២០១១)

| ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ |
|---|---|---|---|---|---|
| **០៥** | **ខេត្តកំពង់ស្ពឺ** | | ១១. ស្រង់ | | ៤. គិរីវ័ន្ត |
| **០១** | **ស្រុកបរសេដ្ឋ មាន ១៥ ឃុំ** | | ១២. ទឹកល្អក់ | | ៥. ក្រាំងដីវ៉ាយ |
| | ១. បរសេដ្ឋ | | ១៣. វាល | | ៦. មហាសាំង |
| | ២. កាត់ភ្លុក | **០៤** | **ស្រុកឱរ៉ាល់មាន ៥ ឃុំ** | | ៧. អូរ |
| | ៣. និទាន | | ១. ហោងសំណំ | | ៨. ព្រៃរំដួល |
| | ៤. ភក្តី | | ២. រស្មីសាមគ្គី | | ៩. ព្រៃក្មេង |
| | ៥. ភារីមានជ័យ | | ៣. ត្រពាំងជោរ | | ១០. តាំងសំរោង |
| | ៦. ផុង | | ៤. សង្កែសាទប | | ១១. តាំងស្យា |
| | ៧. ពោធិអង្ក្រង | | ៥. តាសាល | | ១២. ត្រែងត្រយឹង |
| | ៨. ពោធិចំរើន | **០៥** | **ស្រុកឧត្តុង្គមាន ១៥ ឃុំ** | **០៧** | **ស្រុកសំរោងទងមាន ១៥ ឃុំ** |
| | ៩. ពោធិម្រាល | | ១. ចាន់សែន | | ១. រលាំងចក |
| | ១០. ស្វាយចចិប | | ២. ជើងរាស់ | | ២. កាហែង |
| | ១១. ទួលអំពិល | | ៣. ដំពូព្រឹក្ស | | ៣. ខ្ទុំក្រាំង |
| | ១២. ទួលសាលា | | ៤. ក្សេមក្សាន្ត | | ៤. ក្រាំងអំពិល |
| | ១៣. កក់ | | ៥. ក្រាំងចេក | | ៥. ញ្ញាយ |
| | ១៤. ស្វាយរំពារ | | ៦. មានជ័យ | | ៦. រលាំងគ្រើល |
| | ១៥. ព្រះខែ | | ៧. ព្រះស្រែ | | ៧. សំរោងទង |
| **០២** | **ក្រុងច្បារមន មាន ៥សង្កាត់** | | ៨. ព្រៃក្រសាំង | | ៨. សំបូរ |
| **០៣** | **ស្រុកគងពិសី មាន ១៣ ឃុំ** | | ៩. ត្រាចទង | | ៩. សែនដី |
| | ១. អង្គពពេល | | ១០. វាលពង់ | | ១០. ស្គុះ |
| | ២. ជង្រុក | | ១១. រាំងចាស់ | | ១១. តាំងក្រូច |
| | ៣. មហាឫស្សី | | ១២. យុទ្ធសាមគ្គី | | ១២. ធម្មតាអរ |
| | ៤. ពេជ្រមុនី | | ១៣. ដំណាក់រាំង | | ១៣. ត្រពាំងគង |
| | ៥. ព្រះនិព្វាន | | ១៤. ពាំងល្វា | | ១៤. ទំព័រមាស |
| | ៦. ព្រៃញាតិ | | ១៥. ភ្នំតូច | | ១៥. វល្លិ៍ស |
| | ៧. ព្រៃវិហារ | **០៦** | **ស្រុកភ្នំស្រួចមាន ១២ ឃុំ** | **០៨** | **ស្រុកថ្ពង មាន ៧ ឃុំ** |
| | ៨. រកាកោះ | | ១. ចំបក់ | | ១. អមលាំង |
| | ៩. ស្គុក | | ២. ដាំសង្កែ | | ២.មនោរម្យ |
| | ១០. ស្នំក្រពើ | | ៣. ដំបូករូង | | ៣. ប្រាំបីមុម |
| | ៤. រុងរឿង | **០៤** | **ស្រុកប្រាសាទបាល្ល័ង្គមាន៧ឃុំ** | | ២. ចំណាក្រោម |

៥. ទំពមាន
៦. វាលពន់
៧. យាអង្គ

**០៦ ខេត្តកំពង់ធំ**

**០១ ស្រុកបារាយណ៍ មាន ១៨ ឃុំ**

១.បាក់ស្នា
២. បល្ល័ង្គ
៣. បារាយណ៍
៤. បឹង
៥. ចើងដើង
៦. ច្រនាង
៧. ឈូកខ្សាច់
៨. ចុងដូង
៩. ជ្រលង
១០. គគីធំ
១១. ក្រវ៉ា
១២. អណ្ដូងពោធិ៍
១៣. ពង្រ
១៤. សូយោង
១៥. ស្រឡៅ
១៦. ស្វាយភ្លើង
១៧. ត្នោតជុំ
១៨. ទ្រៀល

**០២ ស្រុកកំពង់ស្វាយ មាន ១១ឃុំ**

១. ជ័យ
២. ដំរីស្លាប់
៣. កំពង់គោ
៤. កំពង់ស្វាយ
៥. នីពេជ
៦. ផាត់សណ្ដាយ
៧. សានគរ
៨. ត្បែង
៩. ត្រពាំងឫស្សី
១០. ក្ដីដូង
១១. ព្រៃគុយ

**០៣ ក្រុងស្ទឹងសែនមាន ៨សង្កាត់**

១២. ទូកមាសខាងកើត

១. ដូង
២. ក្រយា
៣. ផាន់ញើម
៤. សាគ្រាម
៥. សាលាវិស័យ
៦. សាមគ្គី
៧. ទួលគ្រើល

**០៥ ស្រុកប្រាសាទសំបូរ មាន ៥ឃុំ**

១. ឈូក
២. គោល
៣. សំបូរណ៍
៤. ស្រើង
៥. តាំងក្រសៅ

**០៦ ស្រុកសណ្ដាន់ មាន ៩ ឃុំ**

១.ឈើទាល
២. ដងកាំបិត
៣. ក្លែង
៤. មានរិទ្ធ
៥. មានជ័យ
៦. ងន
៧. សណ្ដាន់
៨. សុចិត្រ
៩. ទំរីង

**០៧ ស្រុកសន្ទុក មាន ១០ ឃុំ**

១. បឹងល្វា
២. ជ្រាប់
៣. កំពងថ្ម
៤. កកោះ
៥. ក្រយា
៦. ពៅ
៧. ប្រាសាទ
៨. តាំងក្រសាំង
៩. ទីពោ
១០. ត្បូងក្រពើ

**០៨ ស្រុងស្ទោង មាន ១៣ ឃុំ**

១. បន្ទាយស្ទោង
៤. ស្រែចែង

៣. ចំណាលើ
៤. កំពង់ចិនជើង
៥. កំពង់ចិនត្បូង
៦. ម្សាក្រង
៧. ពាមបាង
៨. ពពក
៩. ប្រឡាយ
១០. ព្រះដំរី
១១. រុងរឿង
១២.សំព្រោច
១៣. ទ្រា

**០៧ ខេត្តកំពត**

**០១ ស្រុកអង្គរជ័យមាន ១១ ឃុំ**

១. អង្គភ្នំតូច
២. អង្គរជ័យ
៣. ចំប៉ី
៤. ដំបូកខ្ពស់
៥. ដានគោម
៦. ដើមដូង
៧. ម្រោម
៨. ភ្នំកុង
៩. ប្រភ្នំ
១០. សំឡាញ
១១. តានី

**០២ ស្រុកបន្ទាយមាសមាន ១៥ឃុំ**

១. បន្ទាយមាសខាងកើត
២. បន្ទាយមាសខាងលិច
៣. ព្រៃទន្លេ
៤. សំរោងក្រោម
៥. សំរោងលើ
៦. ស្ដេចគង់ខាងជើង
៧. ស្ដេចគង់ខាងលិច
៨. ស្ដេចគង់ខាងត្បូង
៩. ត្នោតចុងស្រង់
១០. ត្រពាំងសាលាខាងកើត
១១. ត្រពាំងសាលាខាងលិច
៩. កន្ទោរខាងលិច

១៣. ទូកមាសខាងលិច
១៤. វត្តអង្គខាងជើង
១៥. វត្តអង្គខាងត្បូង

**០៣ ស្រុកឈូកមាន ១៥ ឃុំ**
១. បានៀវ
២. តាកែន
៣. បឹងនិមល
៤. ឈូក
៥. ដូនយ៉យ
៦. ក្រាំងស្បូវ
៧. ក្រាំងស្នាយ
៨. ល្បើក
៩. ត្រពាំងភ្លាំង
១០. មានជ័យ
១១. នារាយណ៍
១២. សត្វពង
១៣. ត្រពាំងបី
១៤. ត្រមែង
១៥. តេជោអភិវឌ្ឍន៍

**០៤ ស្រុកជុំគិរី មាន ៧ ឃុំ**
១. ច្រេស
២. ជំពូវន្ត
៣. ស្នាយអញ្ជិត
៥. ស្រែក្នុង
៦. ស្រែសំរោង
៧. ត្រពាំងរាំង

**០៥ ស្រុកដងទង់មាន ១០ ឃុំ**
១. ដំណាក់សុក្រំ
២. ដងទង់
៣. ខ្ចាយខាងជើង
៤. ខ្ចាយខាងត្បូង
៥. មានរិទ្ធិ
៦. ស្រែជាខាងជើង
៧. ស្រែជាខាងត្បូង
៨. ទទុង
៩. អង្គរមាស
១០. ល្អាង

**០៦ ស្រុកកំពង់ត្រាចមាន ១៤ ឃុំ**
១. បឹងសាលាខាងជើង
២. បឹងសាលាខាងត្បូង
៣. ដំណាក់កន្ទួតខាងជើង
៤. ដំណាក់កន្ទួតខាងត្បូង
៥. កំពង់ត្រាចខាងកើត
៦. កំពង់ត្រាចខាងលិច
៧. កន្ទោរខាងជើង
៨. កន្ទោរខាងកើត
១០. ព្រែកក្រឹស
១១. ឫស្សីស្រុកខាងកើត
១២. ឫស្សីស្រុកខាងលិច
១៣. ស្វាយទងខាងជើង
១៤. ស្វាយទងខាងត្បូង

**០៧ ស្រុកទឹកឈូមាន ១៦ ឃុំ**
១. បឹងទូក
២. ជុំគ្រៀល
៣. កំពង់ក្រែង
៤. កំពង់សំរោង
៥. កណ្ដោល
៦. កោះតូច
៧. កូនសត្វ
៨. ម៉ាក់ប្រាង្គ
៩. ព្រែកត្នោត
១០. ព្រៃឃ្មុំ
១១. ព្រៃថ្នង
១២. ស្ទឹងកែវ
១៣. ថ្មី
១៤. ត្រពាំងព្រីង
១៥. ត្រពាំងសង្កែ
១៦. ត្រពាំងធំ

**០៨ ក្រុងកំពតមាន ៥សង្កាត់**

(នៅមានត)

លោកស្រី **គុយ ផល្លា**

*ឈ្នះ កំហឹង ដោយក្ដីមិនខឹងតប*
*ឈ្នះ របបកខ្វក់ ដោយធម៌ស*
*ឈ្នះ កំណាញ់ ដោយអំណោយដ៏ល្អ*
*ឈ្នះ កុហកភូតភរ ដោយពាក្យសត្យ ។*
*ពុទ្ធភាសិត*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

គណៈកម្មាធិការកណ្តាល

លេខ : ២២/១៣ គ.ក

## សេចក្តីជូនដំណឹងមរណភាពប្រចាំខែ កញ្ញា ឆ្នាំ២០១៣

តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មាធិការកណ្តាលនៃ ស.ប.ស.ខ.
សូមសំដែងសេចក្តីសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
ហើយសូមចូលរួមកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| **ក.មរណៈភាពសមាជិក** | | | | | | | | | **សពទី** |
| | គីម អោ | ៦៨ | ស | គ្រូ. | និវត្តជន បឋមប្រខ្មោរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម | ១៩.០៦.១៣ | រោគាពាធ | ២១៨៧ ក.ច | ៩០៩៤ |
| ២ | ចាន់ ឃិម | ៧៤ | ប | គ្រូ. | និវត្តជន បឋមមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម | ២៤.០៦.១៣ | រោគាពាធ | ១៩៣៤ ក.ច | ៩០៩៥ |
| ៣ | សួស ស៊ីថា | ៥៨ | ស | បឋម | បឋមពន្លៃ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម | ០៥.០៧.១៣ | គ្រោះថ្នាក់ចរាចរ | ៩១៣៦ ក.ច | ៩០៩៦ |
| ៤ | ថោង សាមុត | ៧២ | ប | គ្រូ. | និវត្តជន បឋមបនហ.ស ផ្តល់បំបែកស្រុកចំការលើខេត្តកំពង់ចាម | ១២.០៧.១៣ | រោគាពាធ | ៥៧២២ ក.ច | ៩០៩៧ |
| ៥ | គីម ជិនធួន | ៤៤ | ប | បឋម | បឋមដុប ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម | ១២.០៧.១៣ | រោគាពាធ | ៨៨៨៦ ក.ច | ៩០៩៨ |
| ៦ | ជិន ស្រ៊ាង | ៦១ | ប | គ្រូ. | និវត្តជន បឋម៧មករា ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម | ២០.០៧.១៣ | រោគាពាធ | ៩៩៧៦ ក.ច | ៩០៩៩ |
| ៧ | ទុន យ៉ាវណ្ណី | ៥៣ | ប | បឋម | បឋម មាឃ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម | ១២.០៧.១៣ | រោគាពាធ | ៨៨៧៧ ក.ច | ៩១០០ |
| ៨ | ប៊ិន ពុទ្ធី | ៦៣ | ប | គ្រូ. | និវត្តជន ស្រុកកោះអណ្តែត ខេត្តតាកែវ | ១០.០៦.១៣ | រោគាពាធ | ៥៤២៩ ត.ក | ៩១០១ |
| ៩ | អ៊ុំ សើរ | ៦៤ | ប | គ្រូ. | និវត្តជន ស្រុកត្រាំកក់ ខេត្តតាកែវ | ០២.០៧.១៣ | រោគាពាធ | ២៣៣០ ត.ក | ៩១០២ |
| ១០ | ស៊ុតជូលី | ២៩ | ប | ម.ប.ភ | អនុវិទ្យាល័យ វត្តសរសៃមានបុណ្យ ស្រុកទ្រាំង ខេត្តតាកែវ | ២៤.០៧.១៣ | គ្រោះថ្នាក់ចរាចរ | ៩៣៣៧ ត.ក | ៩១០៣ |
| ១១ | ហង់ សំបូរ | ៤៣ | ប | គ្រូ. | ការិ. អយក ស្រុកកោះអណ្តែត ខេត្តតាកែវ | ២២.០៧.១៣ | រោគាពាធ | ២១៣៣ ត.ក | ៩១០៤ |
| ១២ | នួន វណ្ណា | ២៣ | ប | ម.ប.ភ | បឋម វត្តសរសៃ ស្រុកទ្រាំង ខេត្តតាកែវ | ២៦.០៧.១៣ | គ្រោះថ្នាក់ចរាចរ | ៩៧២០ ត.ក | ៩១០៥ |
| ១៣ | ខួត សុផុន | ៧៦ | ប | បឋម | និវត្តជន ស្រុកមោងឬស្សី ខេត្តបាត់ដំបង | ០១.០៦.១៣ | របេង | ៣៨៤៧ ប.ប | ៩១០៦ |
| ១៤ | ហ៊ាប ហ៊ិត | ៣៩ | ប | បឋម | បឋមជ្រៃរុន ស្រុកមោងឬស្សី ខេត្តបាត់ដំបង | ១៧.០៦.១៣ | រោគាពាធ | ៦៧០២ ប.ប | ៩១០៧ |
| ១៥ | ទុយ រ៉េត | ៥៨ | ប | ម.ទ.ភ | មជ្ឈ.គរុកោសល្យភូមិភាគ | ២៨.០៦.១៣ | រោគាពាធ | ៥៤៣១ ប.ប | ៩១០៨ |
| ១៦ | អោក សុវណ្ណា | ៦៧ | ប | បឋម | និវត្តជន ស្រុកមោងឬស្សី ខេត្តបាត់ដំបង | ២៩.០៦.១៣ | រោគាពាធ | ៣៩៩៣ ប.ប | ៩១០៩ |
| ១៧ | ឡុញ សុធីរ | ៦១ | ប | បឋម | និវត្តជន ស្រុកសង្កែ ខេត្តបាត់ដំបង | ១២.០៧.១៣ | មហារីក | ២៤០១ ប.ប | ៩១១០ |
| ១៨ | ជាស ថុក | ៦៧ | ប | គ្រូ. | និវត្តជន បឋមក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត | ១៨.០៧.១៣ | រោគាពាធ | ២៤២២ ក.ព | ៩១១១ |
| ១៩ | ឃុន បូយ៉ាន | ២៥ | ស | បឋម | បឋមច្បារអំពៅ ស្រុកទឹកឈូ ខេត្តកំពត | ២២.០៧.១៣ | គ្រោះថ្នាក់ចរាចរ | ៧៣៦៥ ក.ព | ៩១១២ |
| ២០ | នន់ នី | ៤៦ | ប | បឋម | បឋមប៉ាក់ខ្លង ការិ.អយក ស្រុកមណ្ឌលសីមា ខេត្តកោះកុង | ២៥.០៧.១៣ | រោគាពាធ | ០២១ ក.ក | ៩១១៣ |
| ២១ | គីម សារ៉ា | ២៥ | ប | បឋម | បឋមព្រៃខ្នុរ ស្រុកវ៉ារិន ខេត្តសៀមរាប | ២៥.០៧.១៣ | គ្រោះថ្នាក់ចរាចរ | ៨៣៣៨ ស.រ | ៩១១៤ |
| ២២ | ផ្លុងគ នួន | ៦៦ | ប | គ្រូ. | និវត្តជន ស្រុកជីក្រែង ខេត្តសៀមរាប | ៣០.០៧.១៣ | រោគាពាធ | ៣៩១៨ ស.រ | ៩១១៥ |
| ២៣ | នុត ញ៉ាន់ | ៧១ | ប | គ្រូ. | និវត្តជន ស្រុកពួក ខេត្តសៀមរាប | ១៧.០៨.១៣ | រោគាពាធ | ៣២២៧ ស.រ | ៩១១៦ |
| ២៤ | ហេង សំរាន្ត | ៤២ | ប | ម.ទ.ភ | វិទ្យាល័យ ហ.ស វត្តស្វាយ ក្រុងសៀមរាប ខេត្តសៀមរាប | ១៣.០៧.១៣ | បេះដូងរីក | ៣៦១ ស.រ | ៩១១៧ |
| ២៥ | ជា គង់ | ៤១ | ប | បឋម | បឋមបូពិ ក្រុងសៀមរាប ខេត្តសៀមរាប | ១៣.០៧.១៣ | រលាកថ្លើម | ៣២៤ ស.រ | ៩១១៨ |
| ២៦ | ញ៉ឹក វុទ្ធី | ៤៩ | ប | បឋម | បឋមសុខសាន្ត ស្រុកពួក ខេត្តសៀមរាប | ១៨.០៧.១៣ | រោគាពាធ | ៣៤៦៣ ស.រ | ៩១១៩ |
| ២៧ | គីម ផល្លា | ៣២ | ស | ម.ប.ភ | អនុវិ. ស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល | ១៧.០៦.១៣ | រោគាពាធ | ៩៧៩២ ក.ណ | ៩១២០ |
| ២៨ | ញូង ឈន | ៦៨ | ប | គ្រូ. | និវត្តជន ស្រុកល្វាឯម ខេត្តកណ្តាល | ០២.០៦.១៣ | រោគាពាធ | ២៨៤០ ក.ណ | ៩១២១ |
| ២៩ | គីម ប៉ោក | ៧៥ | ប | គ្រូ. | និវត្តជន ស្រុកកោះធំ ខេត្តកណ្តាល | ១៨.០៦.១៣ | រោគាពាធ | ៦១៤ ក.ណ | ៩១២២ |
| ៣០ | លី សុខន | ៦៩ | ប | គ្រូ. | និវត្តជន ស្រុកលើកដែក ខេត្តកណ្តាល | ០៤.០៦.១៣ | រោគាពាធ | ៧៧៧ ក.ណ | ៩១២៣ |
| ៣១ | ហាក់ ស្រេង | ៤៤ | ប | ម.ទ.ភ | វិ.ហ.ស អង្គស្នួល ស្រុក អង្គស្នួល ខេត្តកណ្តាល | ០៣.០៧.១៣ | ជំងឺថ្លើម | ៥២២២ ក.ណ | ៩១២៤ |
| ៣២ | ឆេង ឡាយ | ៤១ | ប | ម.ប.ភ | អនុ. បន្ទាយខ្មែរ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ | ២៩.០៦.១៣ | រោគាពាធ | ១៦៩៦ ក.ស្ព | ៩១២៥ |
| ៣៣ | ស៊ិន សារ៉ាយ | ៥៦ | ប | បឋម | មន្ទីរ អ.យ.ក ខេត្តកំពង់ស្ពឺ | ២៥.០៦.១៣ | រោគាពាធ | ០៥៤ ក.ស្ព | ៩១២៦ |
| ៣៤ | កែប សូកាន | ៦៣ | ប | បឋម | និវត្តជន ស្រុកគងពិសី ខេត្តកំពង់ស្ពឺ | ០៩.០៨.១៣ | រោគាពាធ | ០៧១៨ ក.ស្ព | ៩១២៧ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣៥ | ជុំ សុភី | ៥៤ | ស | បឋម | បឋម ចំប៉ា ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ០៧.០៨.១៣ | រោគាពាធ | ២៤៣៨ ក.ស្ព | ៩១២៨ |
| ៣៦ | កែវ ផន | ៧៣ | ប | បឋម | និវត្តជន ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ | ០១.០៨.១៣ | រោគាពាធ | ១៤៨៩ ក.ស្ព | ៩១២៩ |
| ៣៧ | តូច ហួត | ៧២ | ប | បឋម | និវត្តជន ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ | ២៥.០៥.១៣ | រោគាពាធ | ១៥៣៨ ក.ស្ព | ៩១៣០ |
| ៣៨ | ចិន មាន | ៥៩ | ប | បឋម | បឋមទួលស្រគំ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ | ១២.០៧.១៣ | រោគាពាធ | ២៣៧៣ ក.ស្ព | ៩១៣១ |
| ៣៩ | អ៊ុន ឃុត | ៦៦ | ប | បឋម | និវត្តជន ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ | ១៧.០១.១៣ | ជំងឺ | ០៧៨ ព.ហ | ៩១៣២ |
| ៤០ | អេង សុផុន | ៥១ | ប | ម.ប.ភ | មន្ទីរអប់រំយុវជន និងកីឡា ខេត្តព្រះវិហារ | ០៨.០៤.១៣ | ជំងឺ | ០២០ ព.ហ | ៩១៣៣ |
| ៤១ | ប៉ាង លន្ទី | ៦៦ | ប | ម.ប.ភ | និវត្តជន អនុវិ. រវៀង ស្រុករវៀង ខេត្តព្រះវិហារ | ២០.០៥.១៣ | លើសឈាម | ៥៤៥ ព.ហ | ៩១៣៤ |
| ៤២ | មុត ប៊ុនរើក | ៥៩ | ប | បឋម | បឋម ទួលព្រៃភ្សៀវ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ | ០៨.០១.១៣ | ខ្យល់គរ | ២០០៨ ព.ហ | ៩១៣៥ |
| ៤៣ | ចាប ឆន | ៧១ | ប | បឋម | និវត្តជន បឋមរោងចក្រ ក្រុងកំពង់សៀម ខេត្តកំពង់ចាម | ០២.០៨.១៣ | ជរាពាធ | ៣៩៧២ ក.ច | ៩១៣៦ |
| ៤៤ | គ្រុយ ម៉េត | ៦៦ | ស | បឋម | និវត្តជន បឋមកំពង់ចន្លុះ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម | ១១.០៨.១៣ | រោគាពាធ | ៩១៨១ ក.ច | ៩១៣៧ |
| ៤៥ | ព្រំ សារិតមន្ទី | ៥៨ | ប | បឋម | បឋមបឹងកុក ក្រុងកំពង់សៀម ខេត្តកំពង់ចាម | ១៨.០៨.១៣ | គ្រិនថ្លើម | ១១៣០ ក.ច | ៩១៣៨ |
| ៤៦ | កៅ ភឿន | ៦៨ | ប | បឋម | និវត្តជន បឋមប្រខ្មោរ ស្រុកជើងព្រៃ ខេត្តកំពង់ចាម | ១៩.០៨.១៣ | រោគាពាធ | ២១៨០ ក.ច | ៩១៣៩ |
| ៤៧ | ហូ លីហ៊ាង | ៦៥ | ប | បឋម | និវត្តជន អនុវិ. ព្រែកតានង់ ស្រុកកោះសូទិន ខេត្តកំពង់ចាម | ១៨.០៨.១៣ | រោគាពាធ | ១៩៩៣ ក.ច | ៩១៤០ |
| ៤៨ | ងួន សូម័យ | ៤១ | ស | បឋម | បឋម ទួលច្រេស ស្រុករំដួល ខេត្តស្វាយរៀង | ២៥.០៦.១៣ | រោគាពាធ | ២៨៤៨ ស្វ.រ | ៩១៤១ |
| ៤៩ | អ៊ុំ សុផាណារិន | ៥៤ | ស | បឋម | បឋមព្រះសីហនុ ក្រុងស្វាយរៀង ខេត្តស្វាយរៀង | ០៥.០៧.១៣ | លើសឈាម | ២២៤៩ ស្វ.រ | ៩១៤២ |
| ៥០ | សៀម វិន | ៧១ | ប | គ្រូ. | និវត្តជន ស្រុករមាសហែក ខេត្តស្វាយរៀង | ០៧.០៧.១៣ | គ្រិនថ្លើម | ១៣៧១ ស្វ.រ | ៩១៤៣ |
| ៥១ | លាង បានសួង | ៦៦ | ប | គ្រូ. | និវត្តជនវិ. កំពង់ធំ ខេត្តកំពង់ធំ | ១០.០៦.១៣ | រោគាពាធ | ៣៧៨ ក.ធ | ៩១៤៤ |
| ៥២ | ហ៊ាង ណាត | ៣៣ | ប | បឋម | បឋមខ្នាក់ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ | ១៧.០៦.១៣ | គ្រោះថ្នាក់ចរាចរ | ៤៦០៣ ក.ធ | ៩១៤៥ |
| ៥៣ | ជួបសុវណ្ណមុនី | ៣១ | ស | បឋម | បឋមកំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | ១៧.០៦.១៣ | រោគាពាធ | ៥២៩១ ក.ធ | ៩១៤៦ |
| ៥៤ | ថោង វន់ | ៦៤ | ប | គ្រូ. | និវត្តជន បឋមមាសគង់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ | ០១.០៧.១៣ | រោគាពាធ | ១២៦៦ ក.ធ | ៩១៤៧ |
| ៥៥ | តូច តាំង | ៦៨ | ប | គ្រូ. | និវត្តជនវិ. ហ.ស តាំងគោក ស្រុកបារាយណ៍ ខេត្តកំពង់ធំ | ១៤.០៧.១៣ | រោគាពាធ | ១៦៣៤ ក.ធ | ៩១៤៨ |
| ៥៦ | ឡេប មឿន | ៨០ | ប | គ្រូ. | និវត្តជន ការិ.អយក ស្រុកស្ទោង ខេត្តកំពង់ធំ | ១១.០៧.១៣ | រោគាពាធ | ៣៧២៤ ក.ធ | ៩១៤៩ |
| ៥៧ | ម៉ប់ ជិន | ៤៨ | ប | បឋម | បឋម ពង្រ ស្រុកស្ទោង ខេត្តកំពង់ធំ | ១៩.០៧.១៣ | រោគាពាធ | ២១៤២ ក.ធ | ៩១៥០ |
| ៥៨ | ខៀវ សារឿន | ៤៥ | ប | ម.ប.ភ | ការិ. មធ្យមសិក្សាចំណេះទូទៅ មអយក ខេត្តព្រៃវែង | ០៣.០៨.១៣ | រោគាពាធ | ០៨៦ ព.វ | ៩១៥១ |
| ៥៩ | បិត រ៉េត | ៦៥ | ប | គ្រូ | និវត្តជន ការិ. មធ្យមសិក្សាចំណេះទូទៅ មអយក ខេត្តព្រៃវែង | ៣១.០៨.១៣ | រោគាពាធ | ៣៥៣១ ព.វ | ៩១៥២ |
| ៦០ | រស់ សាង៉ុាំ | ៧១ | ប | ម.ប.ភ | និវត្តជន ការគ្រប់គ្រងគណៈកម្មាធិការកណ្តាល | ២២.០៧.១៣ | រោគាពាធ | ១៣៧៨ គ.ក | ៩១៥៣ |
| ៦១ | បួយ លាង | ៧១ | ប | ម.ប.ភ | និវត្តជន ការគ្រប់គ្រងគណៈកម្មាធិការកណ្តាល | ២១.០៨.១៣ | មហារីក | ១៣៦០ គ.ក | ៩១៥៤ |

| ល.រ | គោត្តនាម_នាម | អាយុ | ភេទ | មុខរបរ | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| **ខ.មរណភាពគូស្រករ** | | | | | | | | | **សពធី** |
| ១ | ចិន សុផល | ៥៧ | ស | កម្មករ | ប្រពន្ធលោកប្រាក់ សារិទ្ធ ការិ.អយកស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម | ១៩.០៧.១៣ | រោគាពាធ | ៩៩៤៦ ក.ច | ៥៣៨១ |
| ២ | ហ៊ឹម សុខា | ៤១ | ប | កសិករ | ប្តីអ្នកស្រី ម៉េង សុខា បឋមក្រាំងទ្រមូង ស្រុកគិរីវង់ ខេត្តតាកែវ | ០៧.០៧.១៣ | រោគាពាធ | ៤១៩៦ ត.ក | ៥៣៨២ |
| ៣ | នួន សុវណ្ណ | ៦៥ | ប | កសិករ | ប្តីអ្នកស្រីប៉ែន គីមឡាយ បឋមមង្គលមានលក្ខណ៍ ត្រាំកក តាកែវ | ១៤.០៧.១៣ | រោគាពាធ | ២៨១៩ ត.ក | ៥៣៨៣ |
| ៤ | ប៉ាន់ នៅ | ៥៤ | ស | កសិករ | ភរិយាលោក អ៊ុំ នាក់ និវត្តជន ស្រុកត្រាំកក់ ខេត្តតាកែវ | ១៤.០៧.១៣ | រោគាពាធ | ៥៥៦៣ ត.ក | ៥៣៨៤ |
| ៥ | ឡាច នួន | ៧៤ | ស | កសិករ | ភរិយាលោក សុខ ឆេង និវត្តជន ស្រុកបាទី ខេត្តតាកែវ | ០៦.០៧.១៣ | រោគាពាធ | ៥៣៥៩ ត.ក | ៥៣៨៥ |
| ៦ | ឃិន អូន | ៤៨ | ស | កសិករ | ភរិយាលោក ហង់ សំបូរ ការិ.អយក កោះអណ្តែត ខេត្តតាកែវ | ០១.០៧.១៣ | រោគាពាធ | ២១៣៣ ត.ក | ៥៣៨៦ |
| ៧ | ចាន នន្ទ | ៤១ | ប | ធ្វើស្រែ | ប្តីអ្នកស្រី ផាត មុំ អនុ. អូរដំបង ស្រុកសង្កែ ខេត្តបាត់ដំបង | ០៤.០៧.១៣ | លើសឈាម | ៥៣៨៣ ប.ប | ៥៣៨៧ |
| ៨ | តាប គីមឈាង | ៥៨ | ស | មេផ្ទះ | ភរិយាលោក តឹក សូម៉ារី បឋមគគីរ ស្រុកសង្កែ ខេត្តបាត់ដំបង | ១៧.០៥.១៣ | មហារីក | ២៥១៥ ប.ប | ៥៣៨៨ |
| ៩ | ចាប យី | ៤៣ | ប | មេផ្ទះ | ប្តីអ្នកគ្រូ ម៉ប់ សុខន បឋមសាមគ្គី សន្តិភាព ស្រុកជីក្រែង សៀមរាប | ២៧.០៧.១៣ | ខ្យល់គរ | ២១៧៤ ស.រ | ៥៣៨៩ |
| ១០ | សាត គង់ | ៧៥ | ប | កសិករ | ប្តីអ្នកគ្រូ ជា សាអែម ក្រុងសៀមរាប ខេត្តសៀមរាប | ០៥.០៥.១៣ | ជំងឺសួត | ៧២៦ ស.រ | ៥៣៩០ |
| ១១ | ឡូ សឿប | ៥១ | ស | មេផ្ទះ | ប្រពន្ធលោក ទិត្យ សារ៉ាត់ ស្រុកពួក ខេត្តសៀមរាប | ១៣.០៧.១៣ | លើសឈាម | ២៦៩៣ ស.រ | ៥៣៩១ |
| ១២ | ផាន់ ប៊ុនធឿន | ៤៤ | ប | កសិករ | ប្តីអ្នកគ្រូ មាស សុភា អនុវិទ្យាល័យ ខ្ពប ស្រុកស្អាង ខេត្តកណ្តាល | ០៩.០៦.១៣ | រោគាពាធ | ៥៦៧១ ក.ណ | ៥៣៩២ |
| ១៣ | ឯម វ៉ាន | ៧៨ | ស | មេផ្ទះ | ប្រពន្ធលោក គង់ ស៊ុំ និវត្តជន ការិ.អយក ស្រុកកៀនស្វាយ ខេត្តកណ្តាល | ១៧.០៦.១៣ | រោគាពាធ | ៦៥០២ ក.ណ | ៥៣៩៣ |
